# ស្វែងរកការពិត



◆ ការធូរស្បើយសន្សឹមៗពីការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរដោយសាររបបកម្ពុជាប្រជាធិបតេយ្យ

◆ ១៧ មេសា : ថ្ងៃសោកសៅបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៧៦ ខែមេសា ឆ្នាំ២០០៦

ស្វែងរកការពិត

លេខ៧៦ ខែមេសា ឆ្នាំ២០០៦

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ ការធូរស្បើយសន្សឹមៗពីការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរ ..........១

**ផ្នែកឯកសារ**

◆ ម៉ុល សុវណ្ណ ៖ អ្នកទទួលភ្ញៀវនៅក្នុងវាំង ..........៤
◆ ទូរលេខខ្មែរក្រហម ..........៧
◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្ទេចនៅមន្ទីរ ស-២១ ..........៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រឿងរ៉ាវដែលមិនចេះសាបសូន្យ ..........១០
◆ អតីតអ្នកទោសពីរនាក់នៅគុកព្រៃស ..........១៤
◆ ដំណើរទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ..........១៥
◆ សាក្សី ជនដៃដល់ និងជនរងគ្រោះ ..........១៧

**ផ្នែកច្បាប់**

◆ សំណងសម្រាប់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ..........៣២

**វេទិកាពិភាក្សាសាធារណៈ**

◆ ១៧ មេសា ៖ ថ្ងៃសោកសៅបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជា ..........៤០
◆ យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា ..........៤២
◆ សមមិត្ត នួន ជា ៖ ការកសាងអ្នកដើរតាមមនោគមវិជ្ជាខ្មែរក្រហម ..........៤៨
◆ កាលប្បវត្តិរបស់ ប៉ុល ពត ..........៥៣
◆ កាលប្បវត្តិរបស់ នួន ជា ..........៥៤
◆ ខ្មែរក្រហមក្នុងអតីតកាលនិងបច្ចុប្បន្នកាល ..........៥៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ រកឃើញរូបថតបងស្រីនៅលើទំព័រទស្សនាវដ្តី ..........៥៦
◆ រកឃើញរូបថតប្អូនប្រុសក្នុងដំណើរទស្សនកិច្ច ..........៥៩
◆ រូបថតរំឭកអតីតកាល ..........៦០



ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមវាយដណ្តើមបានទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនចេញពីទីក្រុងទៅកាន់ទីជនបទ

ខែមេសា ឆ្នាំ២០០៦ ជនរងគ្រោះនៃរបបខ្មែរក្រហមចូលទស្សនាទីតាំងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្មេរលេខនេះ** ៖ ប៉ាង ពីរីន, ស៊ុំ សារីណា, វ៉ាន់ថាន់ ពោដារ៉ា, ជី ទេរិទ្ធ, អៀ ម៉េងទ្រី, ញាណ សុជាតិ, ដួង សុភារិទ្ធ, អាឡិច ហ៊ីនតុន, នូសារ៉ា ថៃថាវ៉ាត់ **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ លី សុផល, ណយ សុផារី **អ្នកបកប្រែ** ៖ បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយករង** ៖ សាន់ កល្យាណ **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ** ៖ គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ** ៖ រ័ត្ន ភារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ការធូរស្បើយសន្សឹមៗពីការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរដោយសាររបបកម្ពុជាប្រជាធិបតេយ្យ

ក្នុងឆ្នាំ២០០៤ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានជួបសំណេះសំណាលជាមួយក្រុមគ្រួសាររបស់ ស្រ៊ុនទ្រី (ឈ្មោះហៅក្រៅ) រស់នៅក្នុងភូមិមួយនៅភាគខាងត្បូងទីក្រុងភ្នំពេញដែលត្រូវចំណាយពេលធ្វើដំណើរចំនួនពីរម៉ោង ។ ស្រ៊ុនទ្រី បានចូលរួមជាមួយខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៤ ក្នុងតួនាទីជាយុទ្ធជន ។ ស្រ៊ុនទ្រី នៅមិនទាន់យល់ពីមូលហេតុដែលគាត់ត្រូវខ្មែរក្រហមចាប់ដាក់មន្ទីរឃុំឃាំងបន្ទាប់ពីគាត់ចូលបម្រើរបបនេះបានមួយឆ្នាំ ។ គាត់បាននិយាយថា "ខ្មែរក្រហមចាប់ខ្ញុំដាក់ខ្នោះ ចោទខ្ញុំថារត់គេចពីសមរភូមិ និងជាទាហានលន់នល់ ។ បន្ទាប់មក ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនមកមន្ទីរឃុំឃាំងព្រៃស ។ ខ្ញុំជាមនុស្សល្អ ក៏ប៉ុន្តែប្រធានក្រុមខ្ញុំថាខ្ញុំមិនមែនជាមនុស្សល្អទេ ។ នៅពេលយប់ខ្មែរក្រហមដាក់ខ្នោះដៃជើងខ្ញុំ ហើយបានយកខ្នងពូថៅវាយក្បាលខ្ញុំ និងយកខ្សែភ្លើងឆក់ខ្ញុំ ។ ខ្មែរក្រហមឈ្មោះ ឈួន ចងជើងខ្ញុំបញ្ច្រាសឡើងលើ" ។

"ពេលដែលកងទ័ពវៀតណាមចូលមករំដោះប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៩ ខ្ញុំរត់ទៅលាក់ខ្លួននៅក្នុងព្រៃ ។ ខ្ញុំបានវិលត្រឡប់មកផ្ទះវិញបន្ទាប់ពីចំណាយពេលយ៉ាងយូររស់នៅក្នុងព្រៃដោយគ្មានអាហារបរិភោគនិងគ្មានទឹកផឹករហូតដល់ខ្ញុំត្រូវផឹកទឹកម៉ូត្រខ្លួនឯង ។ បុរសម្នាក់ដែលរស់នៅក្នុងភូមិបានវាយក្បាលខ្ញុំនឹងពូថៅចោទខ្ញុំថាជាខ្មែរក្រហម បន្ទាប់មកគាត់ក៏បើកឡានចេញទៅ" ។

ស្រ៊ុនទ្រី បានប្រាប់អ្នកស្រាវជ្រាវមជ្ឈមណ្ឌលឯកសារកម្ពុជាថា តាំងពីឆ្នាំ១៩៧៩មក ជារៀងរាល់យប់គាត់តែងតែភ្ញាក់ពីដំណេកកណ្តាលយប់ បែកញើសស្រាក់និងស្រែកយ៉ាងរន្ធត់ដោយសារយល់សប្តិអាក្រក់ ។

ស្រ៊ុនទ្រី ជាប្រជាជនម្នាក់ក្នុងចំណោមប្រជាជនកម្ពុជា ៨១ភាគរយដែលធ្លាប់ឆ្លងកាត់អំពើហិង្សាក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្រប់គ្រងប្រទេសកម្ពុជាចន្លោះពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ក្នុងរយៈពេលគ្រប់គ្រងដ៏ខ្លីនេះ ប្រជាជនស្លូតត្រង់ប្រមាណ១,៧លាននាក់ ឬ២៥ភាគរយនៃចំនួនប្រជាជនកម្ពុជាសរុបនាសម័យនោះ បានបាត់បង់ជីវិត ។ សព្វថ្ងៃនេះ កម្ពុជាជាប្រទេសមួយដែលមានចំនួនប្រជាជនសរុបតែប្រមាណ១១,៥លាននាក់ប៉ុណ្ណោះ ប៉ុន្តែប្រជាជនប្រមាណ ៣,៣លាននាក់មានជំងឺបាក់ស្បាត ។ រោគសញ្ញានៃជំងឺនេះគឺពិបាកដេក ពិបាកប្រមូលអារម្មណ៍ ក្រៀមក្រំចិត្ត បាត់ស្មារតី ឈឺក្បាល វិលមុខ ឈឺពោះវៀន យល់សប្តិអាក្រក់ និងមានចរិតឆេវឆាវ ។ ប្រជាជនជិត៦លាននាក់ទៀតរងគ្រោះដោយជំងឺថប់បារម្ភដែលបណ្តាលមកពីបទពិសោធន៍លំបាកខ្លាំងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ក្រុមអ្នកចិត្តសាស្ត្រជាច្រើនជឿជាក់ថា អត្រាខ្ពស់នៃអំពើហិង្សានៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ ព្រមទាំងកង្វះលទ្ធភាពក្នុងការដោះស្រាយបញ្ហាជីវភាព គឺបណ្តាលមកពីការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរដែលធ្វើឲ្យអ្នកភូមិជាច្រើននាក់មិនអាចដោះស្រាយភាពតានតឹងអារម្មណ៍ក្នុងការរស់នៅប្រចាំថ្ងៃ ។

ប្រជាជនកម្ពុជាភាគច្រើនមិនមានឱកាសទទួលការថែទាំសុខភាពផ្លូវចិត្តទេ ហើយប្រទេសកម្ពុជាមានគ្រូពេទ្យចិត្តសាស្ត្រតែ២៦នាក់និងគ្រូពេទ្យទូទៅប្រហែលមួយរយនាក់តែប៉ុណ្ណោះដែលបានទទួលការបណ្តុះបណ្តាលសុខភាពផ្លូវចិត្តក្នុងរយៈពេល១២សប្តាហ៍ ។ ជនរងគ្រោះដោយជំងឺបាក់ស្បាតគ្មានជម្រើសអ្វីក្រៅពីការស្វែងរកការព្យាបាលពីគ្រូផ្សំថ្នាំបុរាណនិងគ្រូទាយ ។ ប្រជាជនតិចតួចណាស់ដែលយល់ពីមូលហេតុនៃបញ្ហារបស់ខ្លួនដោយសារតែមនុស្សជាច្រើននៅក្នុងសហគមន៍របស់ខ្លួនជួបប្រទះព្រឹត្តការណ៍រន្ធត់ស្រដៀងគ្នានេះដែរនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកជំងឺភាគច្រើនដែលរស់នៅក្នុងប្រទេសដែលកាន់ព្រះពុទ្ធសាសនាមួយនេះមានជំនឿថាការឈឺចាប់របស់ខ្លួនគឺបណ្តាលមកពី"បាបកម្ម"កាលពីជាតិមុន ។

ក្នុងឆ្នាំ២០០៧ខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនឹងបើកសវនាការជំនុំជម្រះទោសអតីតមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលនៅរស់រានមានជីវិត ។ បណ្ឌិត ឈឹម សុធារ៉ា នាយកអង្គការចិត្តសង្គមអន្តរវប្បធម៌ និងអ្នកចិត្តវិទ្យាដទៃទៀត គ្មានអ្នកណាអាចដឹងច្បាស់អំពីឥទ្ធិពលដែលការជំនុំជម្រះ

នេះអាចប៉ះពាល់ដល់ជនរងគ្រោះនៃជំងឺបាក់ស្បាតទេ ។ ប្រសិនបើការជំនុំជម្រះនេះប្រព្រឹត្តទៅដោយជោគជ័យ ប្រជាជនកម្ពុជាអាចនឹងទទួលបានការយល់ដឹងថ្មីទាក់ទងនឹងទុក្ខវេទនារបស់ខ្លួន ហើយប្រាកដជាមានអារម្មណ៍ធូរស្បើយពីជំងឺផ្នែកស្មារតី ។ ផ្ទុយទៅវិញ ប្រសិនបើដំណើរការកាត់ទោសនោះមិនបានជោគជ័យការជំនុំជម្រះក្តីមេដឹកនាំនេះ អាចនឹងធ្វើឲ្យស្នាមរបួសចាស់រើឡើងវិញ ហើយនឹងអាចធ្វើឲ្យប្រជាជនដែលខំបំភ្លេចទារុណកម្ម ការភ័យខ្លាច ការអត់អាហារ និងការស្លាប់អស់រយៈពេលជាង ២៥ឆ្នាំមកហើយនោះ នឹងមានការប៉ះពាល់ធ្ងន់ធ្ងរដល់ផ្លូវចិត្តរបស់គាត់ជាថ្មីម្តងទៀតមិនខាន ។

ស៊ីស ឃីហ្វ មកពីស្ថានទូតហូល្លង់ប្រចាំនៅទីក្រុងបាងកក ដែលបានធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងឆ្នាំ ២០០០ បានស្នើសុំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌បង្កើតគម្រោងមួយជួយជនរងគ្រោះដោយជំងឺបាក់ស្បាត ។ នៅពេលនោះខ្ញុំមានចម្ងល់ថា តើប្រជាជនកម្ពុជាទាំងអស់សុទ្ធតែបានទទួលរងនូវការឈឺចាប់ដោយសាររបបកម្ពុជាប្រជាធិបតេយ្យមែនឬ? បើដូចនេះមែន តើនរណាជាអ្នកជួយជនរងគ្រោះទាំងនោះ? ឃីហ្វ តបថា អ្នកដែលមានការប៉ះពាល់ផ្លូវចិត្តបន្តិចបន្តួចត្រូវជួយដល់អ្នកដែលប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរ ។ ជាមួយនឹងដំណោះស្រាយដ៏សាមញ្ញនេះ យើងចាប់ផ្តើមបង្កើតគម្រោងសាកល្បងមួយ គឺគម្រោង"ជួយជនរងគ្រោះដោយអំពើទារុណកម្ម" ក្នុងខែមករាឆ្នាំ២០០៣ ជាមួយនឹងថវិកាប្រាំពីរពាន់ដុល្លារដែលផ្តល់ដោយស្ថានទូតហូល្លង់ ។

បន្ទាប់ពីរយៈពេលមួយឆ្នាំនៃការសិក្សាគោលដៅសំខាន់ៗ ការរៀបចំការសម្ភាសន៍និងការប្រឹក្សាយោបល់ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាយល់ឃើញថា យើងត្រូវការកិច្ចខិតខំប្រឹងប្រែងដែលមានរយៈពេលយូរជាងនេះ និងមធ្យោបាយព្យាបាលសមស្របតាមវប្បធម៌ ក្នុងការជួយដល់ជនរងគ្រោះដោយអំពើទារុណកម្ម ។ ជាមួយនឹងមូលនិធិដែលផ្តល់ដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ "គម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្ម" បានចាប់ផ្តើមដំណើរការជាផ្លូវការក្នុងខែមករា ឆ្នាំ២០០៤ ។

ពីដំបូង អង្គការចិត្តសង្គមអន្តរវប្បធម៌បានបណ្តុះបណ្តាលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីវិធីសាស្ត្រកំណត់អត្តសញ្ញាណជនរងគ្រោះដោយការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរ ។ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរទៅខេត្តចំនួនបី (ក្នុងនោះមានខេត្តពីរដែលអ្នកភូមិភាគច្រើនជាជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងខេត្តមួយទៀតមានអតីតជនដៃដល់ជាច្រើននាក់) និងធ្វើសម្ភាសន៍អំពីជីវភាពរស់នៅរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងជំហានដំបូងនេះ ក្រុមការងាររបស់យើងបានកំណត់រកអ្នកដែលត្រូវការចាំបាច់នូវការព្យាបាលសុខភាពផ្លូវចិត្ត ។

ជារួម មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបសម្ភាសន៍ជាមួយប្រជាជនចំនួន៣០២នាក់ ។ ក្នុងនោះ ២១៤នាក់ជាជនរងគ្រោះដែលមានទទួលរងនូវការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរដោយផ្ទាល់ឬដោយប្រយោល (ឧទាហរណ៍បាត់បង់មនុស្សជាទីស្រលាញ់) និង៨៨នាក់ជាអតីតកម្មាភិបាលខ្មែរក្រហម ។ យើងរកឃើញថា មានប្រជាជន៩៥នាក់មានជំងឺបាក់ស្បាត និងបានប្រគល់អ្នកទាំងនោះទៅឲ្យអង្គការចិត្តសង្គមអន្តរវប្បធម៌ដើម្បីព្យាបាល ។

អង្គការចិត្តសង្គមអន្តរវប្បធម៌បានធ្វើដំណើរពីរដងក្នុងមួយខែទៅតំបន់ដែលត្រូវព្យាបាលប្រជាជន ដើម្បីផ្តល់សេវាប្រឹក្សានិងព្យាបាល ។ ដោយសារតែបុគ្គលិករបស់អង្គការចិត្តសង្គមអន្តរវប្បធម៌មានចំនួនតិច និងតម្រូវការពេលវេលាធ្វើដំណើរទៅកាន់តំបន់ឆ្ងាយៗ ក្រុមការងារអង្គការចិត្តសង្គមអន្តរវប្បធម៌មានលទ្ធភាពព្យាបាលអ្នកជំងឺតែ៦០នាក់ប៉ុណ្ណោះ ។

អ្នកដែលមានរោគសញ្ញាធ្ងន់ធ្ងរបំផុតបានទទួលការព្យាបាលជាលក្ខណៈបុគ្គល ក្នុងនោះមួយចំនួនតូចទទួលបានថ្នាំព្យាបាលផ្លូវចិត្តនិងថ្នាំវីតាមីន ។ ក្រៅពីនោះបានទទួលការព្យាបាលជាក្រុម ។ ភាគច្រើននៃការព្យាបាលនេះផ្តោតជាសំខាន់ទៅលើអាកប្បកិរិយារបស់អ្នកភូមិ ដូចជាការញៀនស្រានិងអំពើហិង្សាក្នុងគ្រួសារជាដើម ដែលបង្កជាផលប៉ះពាល់ខ្លាំងដល់សហគមន៍ ។

គម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្មបានបញ្ចូលបច្ចេកទេសថ្មីមួយចំនួនដែលសមរម្យតាមវប្បធម៌ខ្មែរក្នុងការជួយដល់ប្រជាជនកម្ពុជាឲ្យដោះស្រាយបញ្ហាផ្លូវចិត្ត ។ ជាឧទាហរណ៍

យើងបញ្ចូលបន្ថែមការជួបជុំពិភាក្សារកមធ្យោបាយដោះស្រាយបញ្ហាតានតឹងក្នុងអារម្មណ៍តាមបែបព្រះពុទ្ធសាសនា ពីព្រោះអ្នកចូលរួមក្នុងគម្រោងនេះទាំងអស់សុទ្ធតែជាពុទ្ធសាសនិកជន ។ ម្យ៉ាងទៀត អ្នកដែលចូលរួមត្រូវបានបង្រៀនអំពីវិធីសម្រួលសាច់ដុំនិងវិធីដកដង្ហើមដែលអាចជួយកាត់បន្ថយការថប់បារម្ភនិងសម្រន់កំហឹង ។ ក្រុមអ្នកផ្តល់ប្រឹក្សាក៏យកចិត្តទុកដាក់ទៅលើទស្សនៈបែបព្រះពុទ្ធសាសនាអំពីការពិចារណា ពោលគឺការផ្តោតអារម្មណ៍ទៅលើពេលវេលាបច្ចុប្បន្នដើម្បីការពារកុំឲ្យអ្នកជំងឺមានអារម្មណ៍ចង់គេចវេះពីអ្នកដទៃ ។ វិធីនេះដូចគ្នានឹងវិធីដែលបង្កើតឡើងដើម្បីជួយអ្នកដែលប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរនៅបស្ចិមប្រទេស ។ វិធីនេះជួយកាត់បន្ថយរោគសញ្ញារបស់អ្នកជំងឺបានយ៉ាងច្រើន ។

ចំណុចសំខាន់មួយទៀតក្នុងគម្រោងនេះគឺជួយដោះស្រាយបញ្ហាប្រឈមមុខរបស់សហគមន៍ដែលជនរងគ្រោះនិងជនដៃដល់រស់នៅក្នុងភូមិជាមួយគ្នា ។ ដូច្នេះគម្រោងនេះបានស្វះស្វែងបង្កើតបរិយាកាសមួយដែលជនរងគ្រោះនិងជនដៃដល់អាចទំនាក់ទំនងគ្នានិងស្វែងយល់អារម្មណ៍គ្នាទៅវិញទៅមក ។

នៅចុងឆ្នាំ២០០៥ យើងបាននាំជនរងគ្រោះ២៥នាក់និងជនដៃដល់២៥នាក់ចូលរួមក្នុងដំណើរទស្សនកិច្ចរយៈពេលបីថ្ងៃនៅទីតាំងប្រល័យពូជសាសន៍ និងពិភាក្សាគ្នាអំពីអ្វីដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បើទោះបីជាការអត់ឱនមិនបានកើតឡើងដោយស្រួលក៏ដោយ ក៏ភាគច្រើននៃជនរងគ្រោះបាននិយាយថាគាត់យល់អំពីស្ថានភាពដែលជំរុញជនដៃដល់ឲ្យប្រព្រឹត្តនូវអ្វីដែលជនដៃដល់បានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ប្រទេសកម្ពុជានៅមានការលំបាកជាច្រើនទៀតក្នុងការជួយដល់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ កិច្ចការមួយក្នុងចំណោមកិច្ចការសំខាន់ជាច្រើនទៀត គឺតម្រូវការនៃការផ្តល់ប្រឹក្សាដែលកើតចេញពី“គម្រោងជួយជនរងគ្រោះដោយសារអំពើទារុណកម្ម” ។ មុនពេលដែល ស្រ៊ុនទ្រី ទទួលបានការផ្តល់ប្រឹក្សា គាត់ទទួលបានថ្នាំដែលធ្វើឲ្យគាត់អាចសម្រាកយ៉ាងស្កប់ស្កល់ជាលើកដំបូងបង្អស់ក្នុងរយៈពេល២៥ឆ្នាំ ។ ជាលទ្ធផល អ្នកភូមិដែលរស់នៅក្បែរផ្ទះរបស់គាត់ក៏អាចសម្រាកបានលក់ស្កប់ស្កល់ដែរ ។ ដោយមើលឃើញពីអត្ថប្រយោជន៍នៃការព្យាបាលនេះ អ្នកភូមិទាំងនោះក៏បានស្នើសុំឲ្យគម្រោង “ជួយជនរងគ្រោះដោយអំពើទារុណកម្ម” ជួយព្យាបាលគាត់ដែរ ។

ដោយសារតែអ្នកផ្តល់ប្រឹក្សាមានចំនួនតិចតួចពេកនៅក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែស្វែងរកមធ្យោបាយថ្មីៗដែលមានលក្ខណៈយូរអង្វែងដើម្បីជួយដល់ជនរងគ្រោះដោយជំងឺបាក់ស្បាត ។ ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ យើងមានគម្រោងចុះទៅបណ្តុះបណ្តាលប្រជាជនមូលដ្ឋានឲ្យជួយកំណត់អត្តសញ្ញាណអ្នកដែលមានជំងឺបាក់ស្បាត និងបញ្ជូនមកឲ្យ“គម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្ម”ដើម្បីជួយដោះស្រាយ ។ ម្យ៉ាងវិញទៀត យើងមានបំណងចង់ឲ្យមន្ទីរពេទ្យរបស់រដ្ឋចូលរួមផ្តល់សេវាបែបនេះដែរ ។ បច្ចុប្បន្ននេះ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលក្រីក្របំផុតនៅលើពិភពលោក ។ ភាពក្រីក្រជាមូលហេតុនៃបរាជ័យនិងអំពើហិង្សាក្នុងគ្រួសារដែលប្រជាជនកម្ពុជាជួបប្រទះក្នុងជីវភាពរស់នៅសព្វថ្ងៃ ហើយយើងនឹងជួយធ្វើឲ្យសហគមន៍កើនចំណូលនិងទទួលបានកិត្តិយសដែលគាត់ធ្លាប់មានដូចកាលពីមុនរបបខ្មែរក្រហម ។ យើងមានគម្រោងជួយឲ្យមានការធូរស្បើយដោយសន្សឹមៗ ។

**ឆាំង យុ**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ម៉ិល សុវណ្ណ : អ្នកទទួលភ្ញៀវនៅក្នុងវាំង

ម៉ិល សុវណ្ណ ហៅ នប់ មានស្រុកកំណើតនៅភូមិព្រែកតាទន់ ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ។ សុវណ្ណ បានចាប់ផ្តើមចូលរៀននៅក្នុងសាលាវត្តក្នុងខេត្តបាត់ដំបងនៅអាយុ៩ឆ្នាំ ។ ឆ្នាំ ១៩៦៤ សុវណ្ណ បានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាកម្រិតទី២ ហើយបានមកបន្តការសិក្សានៅទីក្រុងភ្នំពេញនៅមហាវិទ្យាល័យវិទ្យាសាស្ត្រ ។ ហើយនៅឆ្នាំ១៩៦៥ សុវណ្ណ បានប្រឡងចូលរៀននៅមហាវិទ្យាល័យគរុកោសល្យ បានរយៈពេល ៣ខែ សុវណ្ណ បានទទួលអាហារូបករណ៍ទៅសិក្សាផ្នែកវិស្វករនៅសហភាពសូវៀត ។

## ជីវិតសិក្សានៅសហភាពសូវៀត

សុវណ្ណ បានចាកចេញពីប្រទេសកម្ពុជានៅខែវិច្ឆិកា ឆ្នាំ ១៩៦៥ ។

ចាប់តាំងពីពេលទៅដល់សហភាពសូវៀត សុវណ្ណ បានទទួលការស្វាគមន៍ពីនិស្សិតចាស់ៗជាច្រើនមានឈ្មោះ អៀង សីហា, ហាក់ ស៊ាងឡាយនី, គ្រិន លាន, តាន់ នៃហេង, និង ហៃ គឹមស៊ាង ។ មិត្តភក្តិថ្មីទាំងនោះតែងអប់រំនិងពន្យល់ណែនាំ សុវណ្ណ ឲ្យស្រលាញ់និងគាំទ្រនយោបាយរបស់សហភាពសូវៀតក្នុងការវាយយកប្រទេសតូចៗមកដាក់ក្រោមអំណាចនិងមនោគមវិជ្ជារបស់ខ្លួន ។ បន្ទាប់មក សុវណ្ណ ត្រូវបានបញ្ចូលឲ្យរៀនទ្រឹស្តីម៉ាក្ស-លេនីនតាមសៀវភៅរបស់សូវៀតក្នុងក្រុមសម្ងាត់របស់មិត្តភក្តិថ្មីនេះ ។ អ្នកដែល សុវណ្ណ ស្និទ្ធស្នាលបំផុតគឺ គ្រិន លាន ព្រោះអ្នកទាំងពីររស់នៅក្នុងបន្ទប់ជាមួយគ្នានិងរៀននៅសាលាជាមួយគ្នា ។

នៅឆ្នាំ១៩៦៦ គ្រិន លាន បានណែនាំនិងឧទ្ទេសនាម សុវណ្ណ ឲ្យចូលជាសមាជិក កា.ហ្សេ.បេ នៅចំពោះមុខជនជាតិសូវៀតម្នាក់ឈ្មោះ បូរីស ឡាប់សុស ។ សុវណ្ណ ទទួលភារកិច្ចទាក់ទងនិស្សិតកម្ពុជាផ្សេងទៀតឲ្យទៅរៀននៅសូវៀត ដើម្បីពង្រីកកម្លាំង កា.ហ្សេ.បេ ទាក់ទងនិងក្តាប់និន្នាការនយោបាយរបស់សមាគមនិស្សិតកម្ពុជានៅប្រទេសក្រៅផ្សេងៗទៀត ពិសេសនៅអឺរ៉ុបខាងកើត ។

នៅឆ្នាំ១៩៦៧ សុវណ្ណ និង គ្រិន លាន បានធ្វើដំណើរទៅប្រទេសអាល្លឺម៉ង់ខាងកើតនិងប្រទេសឆេកូស្លូវ៉ាគីដើម្បីទាក់ទងនិស្សិតខ្មែរនៅទីនោះនិងស៊ើបពីសភាពការណ៍នៅក្រៅប្រទេស ។

នៅវិស្សមកាលឆ្នាំ១៩៦៨ សុវណ្ណ បានចូលរួមចាត់ចែងការសម្រាករបស់និស្សិតកម្ពុជានៅមាត់សមុទ្រខ្មៅដើម្បីពង្រីកនិងពង្រឹងការទាក់ទងជាមួយនិស្សិតកម្ពុជាទាំងអស់ឲ្យទៅរស់នៅសហភាពសូវៀត ។ ក្រៅពីនេះ សុវណ្ណ ស៊ើបសួរនិងតាមដានពីចលនាតស៊ូរបស់ប្រជាជនកម្ពុជានៅក្នុងប្រទេសនិងនិយាយបង្អាប់ពីរបបរាជានិយមនៅកម្ពុជាប្រាប់ដល់និស្សិតក្រៅប្រទេស ។

ក្រោយរដ្ឋប្រហារទម្លាក់សម្តេចសីហនុនៅឆ្នាំ១៩៧០ សុវណ្ណ ទាក់ទងជិតស្និទ្ធជាមួយ បូរីស ឡាប់សុស ដើម្បីអនុវត្តផែនការប្រឆាំងនឹងបដិវត្តន៍កម្ពុជា ។ សុវណ្ណ ក៏ត្រូវស៊ើបអំពីសភាពការណ៍នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជានៅប៉េកាំងតាមរយៈ ហាក់ ស៊ាងឡាយនី និង គ្រិនលាន ។

នៅចន្លោះឆ្នាំ១៩៧១-៧២ ឡាំ វីរី, អ៊ុក សុក និងសុវណ្ណ បានធ្វើសកម្មភាពឃោសនាបំផ្លើសពីការដែលសូវៀតប្រឆាំងនឹងបដិវត្តន៍កម្ពុជា ថាសូវៀតបានជួយបដិវត្តកម្ពុជាតាមរយៈវៀតណាម និងលើកសសើរពីការគាំទ្ររបស់សូវៀតចំពោះចលនាបដិវត្តន៍កម្ពុជា ។

## សកម្មភាពនៅទីក្រុងប៉េកាំង

នៅខែមេសា ឆ្នាំ១៩៧៣ សុវណ្ណ បានចេញពីទីក្រុងម៉ូស្គូមកទីក្រុងប៉េកាំងដើម្បីចូលរួមក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ។ តាមផែនការកា.ហ្សេ.បេ សុវណ្ណ ត្រូវបំពេញតួនាទីបីនៅទីក្រុងប៉េកាំង ៖ ១)បំបែកបំបាក់ផ្ទៃក្នុងរណសិរ្ស ២)បំបែកសម្តេចសីហនុ ចេញពីរណសិរ្ស ដើម្បីរារាំងដល់ការប្រមូលផ្តុំកម្លាំងរបស់អង្គការបដិវត្តន៍ ៣)ខិតខំសម្របខ្លួនឲ្យចូលជ្រៅក្នុងជួរបដិវត្តន៍ ។

សុវណ្ណ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ហាក់ ស៊ាងឡាយនី ដែលជាអនុរដ្ឋលេខាធិការក្រសួងការបរទេស និងជាសមាជិកគណៈកម្មាធិការរណសិរ្សរួបរួមជាតិកម្ពុជានៅប៉េកាំង ។ ហាក់ ស៊ាងឡាយនី បានពន្យល់ សុវណ្ណ ជាញឹកញាប់អំពីសភាពការណ៍

ផ្ទៃក្នុងរបស់រណសិរ្សដូចជាការលាលែងចេញពីតំណែងប្រធានរណសិរ្សរបស់ សម្តេច សីហនុ និងការបែកបាក់ជាក្រុម សម្តេច សីហនុ, ក្រុមប៉ែន នុត និងក្រុមអ្នកមកពីប្រទេសបារាំង ។ ក្រៅពីនេះ ហាក់ ស៊ាងឡាយនី បានណែនាំ សុវណ្ណ ឲ្យស្គាល់ ជួន ប្រាសិទ្ធ ជារដ្ឋមន្ត្រីក្រសួងសម្របសម្រួល និង សួង ស៊ីគឿន អ្នកយកព័ត៌មាន អា.កា.អ៊ី និងជាសមាជិកគណៈកម្មាធិការរណសិរ្សរួបរួមជាតិកម្ពុជា ។ សុវណ្ណ បានចូលរួមញុះញង់ក្នុងសកម្មភាពជាច្រើនដើម្បីបំពេញតួនាទីរបស់ខ្លួន ហើយដើម្បីសម្រេចនូវគម្រោងការទីបី សុវណ្ណ បានដាក់ពាក្យទៅអង្គការសុំចូលមកក្នុងតំបន់រំដោះនៅកម្ពុជា ។

## ដំណើរត្រឡប់មកប្រទេសកម្ពុជា

នៅខែ៥ឆ្នាំ១៩៧៤ សុវណ្ណ បានទទួលការអនុញ្ញាតពីអង្គការឲ្យមកតំបន់រំដោះជាមួយមនុស្ស៤នាក់ទៀតមាន ហាក់ ស៊ាងឡាយនី, ទុន ជោតស៊ីរិន, សួង ស៊ីគឿន និង អ៊ុក សុក ។ ពេលធ្វើដំណើរមកប្រទេសកម្ពុជា សុវណ្ណ និងអ្នករួមដំណើរទាំង៤នាក់ទៀតបានឈប់នៅទីក្រុងហាណូយប្រទេសវៀតណាមមួយរយៈ ហើយអង្គការបានខទ្ទេសនាមអ្នកទាំង៥ឲ្យធ្វើការនៅមន្ទីរសេ.គេ.៧០ ដែលជាស្ថានីយវិទ្យុផ្សាយសំឡេងសម្ងាត់មួយរបស់រណសិរ្សរួបរួមជាតិកម្ពុជា ។

ពេលមកដល់មន្ទីរសេ.គេ.៧០ សុវណ្ណ បានជួប ប៉ុច មគ្គបូរី, ហេង ពេជ, និង សៀង ហួរឡុង ដែលត្រូវចាកចេញពីមន្ទីរនេះចូលមកតំបន់រំដោះនៅកម្ពុជាដែរ ។ អ្នកទាំងបីបានផ្តាំ សុវណ្ណ ឲ្យខំលត់ដំ និងសម្របខ្លួនក្នុងជួរបដិវត្តន៍ ។ នៅមន្ទីរនេះ សុវណ្ណ មិនទាក់ទងផ្ទាល់ជាមួយវៀតណាមទេ គឺទាក់ទងការងារតែជាមួយឈ្មោះ ស៊ីវ ជាប្រធានមន្ទីរ និង ចាន់ ជាលេខាមន្ទីរប៉ុណ្ណោះ ។ សុវណ្ណ បានរាយការណ៍ឲ្យ ស៊ីវ និង ចាន់ ដឹងអំពីការបែកបាក់បក្ខពួកនៅក្នុងរណសិរ្សថា សម្តេច សីហនុ លែងទុកចិត្តលើចលនាតស៊ូរបស់អ្នកដឹកនាំក្នុងប្រទេសទៀតហើយ ។ ពេលនោះ ស៊ីវ និង ចាន់ បានញុះញង់ឲ្យ សម្តេច សីហនុ លែងទុកចិត្តចំពោះការដឹកនាំចលនាតស៊ូនិងទាញឲ្យមានការចរចាសម្រុះសម្រួល ។ ក្រោយមកអ្នកទាំងពីរបានរត់ចេញពីមន្ទីរ ព្រោះអង្គការបានសម្រេចរំលាយមូលដ្ឋានបដិវត្តន៍កម្ពុជានៅភាគខាងជើងប្រទេសវៀតណាម ។

## ការងារជាអ្នកទទួលភ្ញៀវបរទេស

នៅខែ៥ឆ្នាំ១៩៧៥ សុវណ្ណ បានមកដល់ទីក្រុងភ្នំពេញ ។ សុវណ្ណ បានទទួលភារកិច្ចបម្រើភ្ញៀវចិននៅក្រសួងការពារប្រទេស ។ បន្ទាប់មកអង្គការដក សុវណ្ណ ឲ្យមករៀបចំផ្ទះសម្រាប់ទទួលភ្ញៀវបរទេសដែលនៅជិតវិមានឯករាជ្យ ។ សុវណ្ណ បានរួមដំណើរជាមួយគណៈប្រតិភូរបស់ សម្តេច សីហនុ ទៅធ្វើទស្សនកិច្ចនៅប្រទេសមួយចំនួន ។ ពេលត្រឡប់មកវិញ អង្គការប្រគល់ភារកិច្ចឲ្យ សុវណ្ណ នៅបម្រើ សម្តេច សីហនុ ក្នុងព្រះបរមរាជវាំងនៅទីក្រុងភ្នំពេញ ។

សុវណ្ណ ត្រូវបំពេញភារកិច្ច៥ឲ្យ កា.ហ្វេ.បេ គឺ ១)ចូលឲ្យជ្រៅក្នុងអង្គការចាត់តាំងដឹកនាំដើម្បីក្តាប់មាគ៌ានយោបាយរបស់អង្គការបដិវត្តន៍កម្ពុជា ហើយបំផុសឲ្យមានការបែកបាក់នៅក្នុងជួរបក្ស ២)ពង្រីកកម្លាំងថ្មីក្នុងជួររបស់ខ្លួន ៣)រារាំងនិងបន្ទុចបង្អាក់នយោបាយដណ្តើមកម្លាំងរបស់អង្គការបដិវត្តន៍លើឆាកអន្តរជាតិ ៤)ក្តាប់គោលជំហរនិងយុទ្ធវិធីរបស់អង្គការចំពោះ សម្តេច សីហនុ ពីព្រោះសហភាពសូវៀតនិងវៀតណាមមានគោលដៅអូសទាញ សម្តេច សីហនុ ឲ្យប្រឆាំងនឹងបដិវត្តន៍កម្ពុជា ៥)ស៊ើបរកខ្មែរចាត់តាំងចាស់ៗ ។

ពេលនៅបំពេញភារកិច្ចបម្រើភ្ញៀវចិន សុវណ្ណ បានជួប អៀង សីហា នៅកន្លែងទទួលភ្ញៀវចិន ។ សុវណ្ណ បានសួរនាំ សីហា អំពីមិត្តភក្តិចាស់ៗដែលធ្លាប់រៀននៅសូវៀតនិងធ្លាប់ធ្វើសកម្មភាពក្នុងខ្មែរ កា.ហ្វេ.បេ ជាមួយគ្នា ។ សីហា បានប្រាប់ថាអ្នកទាំងនោះបានបែកផ្លូវគ្នាទៅតំបន់ផ្សេងហើយនៅពេលដែលអង្គការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ។

សុវណ្ណ បានជួប គ្រិន លាន ម្តងទៀតបន្ទាប់ពីការបែកគ្នាអស់មួយរយៈនៅប៉េកាំង ក្នុងខណៈដែល គ្រិន លាន នាំកម្លាំងមកជួយរៀបចំកន្លែងទទួលអ្នកបច្ចេកទេសចិនដែលទើបមកដល់ថ្មីទៀត ។ សុវណ្ណ បានរាយការណ៍ប្រាប់ គ្រិន លាន អំពីឥរិយាបថរបស់ខ្មែរកា.ហ្វេ.បេដែលខ្លួនបានជួបកន្លងមក ។ តាមរយៈ គ្រិន លាន, សុវណ្ណ បានស្គាល់និងយល់អំពីការចាត់តាំងខ្លះៗនៅក្រសួង ប-១ (ក្រសួងការបរទេស) ។ មិនយូរប៉ុន្មានអង្គការបានដក គ្រិន លាន ពីប្រធានមន្ទីរឲ្យទៅធ្វើការនៅផ្នែកបម្រើភ្ញៀវចិនវិញ ពីព្រោះមហាជនមិនពេញចិត្តនឹងការគ្រប់គ្រងរបស់ គ្រិន លាន ។

ក្រោយមកទៀត អង្គការបានដក សុវណ្ណ និង គ្រិន លាន ឲ្យទៅធ្វើការនៅកន្លែងផ្សេង ។ សុវណ្ណ ត្រូវទៅបំពេញភារកិច្ចរៀបចំផ្ទះទទួលភ្ញៀវជាមួយឈ្មោះ ហេង ពេជ, សៀង ហួរឡុង និង ឡុង នរិន្ទ ។ សកម្មភាពសំខាន់ដែល សុវណ្ណ ត្រូវធ្វើគឺតាមដានសកម្មភាពចេញចូលរបស់បរទេស (ពេលនោះមានទូតកូរ៉េនិងវៀតណាម) និងស៊ើបពីដំណើរត្រឡប់មកកម្ពុជាវិញរបស់ សម្តេច សីហនុ ។

នៅដើមខែ៩ឆ្នាំ១៩៧៥ សម្តេច សីហនុ បានយាងចូលមកកម្ពុជាជាមួយសមាជិករណសិរ្សមួយចំនួនទៀត ។ សុវណ្ណ បានទទួលភារកិច្ចតាមបម្រើភេសជ្ជៈគ្រប់ទីកន្លែងដែល សម្តេច សីហនុ ត្រូវទៅទស្សនកិច្ច ។

នៅចុងខែ៩ឆ្នាំ១៩៧៥ សុវណ្ណ បានជួប ហាក់ ស៊ាងឡាយនី ដែលទើបមកដល់ភ្នំពេញ ។ សុវណ្ណ បានរាយការណ៍ប្រាប់ ឡាយនី ពីការងារនិងទីកន្លែងរស់នៅរបស់ក្រុមខ្លួននៅភ្នំពេញ ។

នៅថ្ងៃទី២៩ខែ៩ឆ្នាំ១៩៧៥ សុវណ្ណ បានរួមដំណើរជាមួយគណៈប្រតិភូរបស់ សម្តេច សីហនុ ទៅធ្វើទស្សនកិច្ចនៅទីក្រុងប៉េកាំង ។ សម្តេច សីហនុ និងសមាជិករណសិរ្សមួយចំនួនបានបន្តដំណើរទៅចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិនៅទីក្រុងញូយ៉ក ចំណែក សុវណ្ណ ត្រូវរង់ចាំនៅប៉េកាំងមួយរយៈ ។ សុវណ្ណ បានទៅជួប ព្រំ ភឿន និង ជា ខន និងប្រាប់ពីសភាពការណ៍នៅកម្ពុជាក្រោយពេលរំដោះនិងអំពីការងាររបស់ខ្លួន ។

សុវណ្ណ បានបន្តដំណើរទស្សនកិច្ចទៅប្រទេសយូហ្គោស្លាវី ហើយបានជួបទាក់ទងជាមួយឈ្មោះ គាន់ ឆៃហេង ជាបុគ្គលិកទូតនៅប្រទេសយូហ្គោស្លាវី ។ ក្រោយពីបានរៀបរាប់ពីសភាពការណ៍នៅក្នុងប្រទេសកម្ពុជា សុវណ្ណ បានបញ្ចុះបញ្ចូលឲ្យ គាន់ ឆៃហេង និង ថាច់ សួង ឆាប់ចូលមកកម្ពុជា ។ ក្រៅពីនេះ សុវណ្ណ បានសសេរបណ្ណជូនពរផ្ញើតាមរយៈព្រះអង្គម្ចាស់ នរិន្ទ ដារាពង្ស ទៅ ឡាំ វីរី ដែលរស់នៅសហភាពសូវៀត ។ នៅក្នុងកាត សុវណ្ណ បានសួរសុខទុក្ខ និងប្រាប់អំពីវិធានការរបស់អង្គការក្នុងការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ការបិទផ្សារ និងការបិទមិនឲ្យមានចាយលុយ ។

នៅចុងខែ១២ឆ្នាំ១៩៧៥ សុវណ្ណ បានត្រឡប់មកប្រទេសកម្ពុជាវិញជាមួយ សម្តេច សីហនុ ។

ពេលត្រឡប់មកដល់កម្ពុជា សុវណ្ណ ចាប់ផ្តើមតាមដានអំពីសភាពការណ៍ប្រែប្រួលតាមទីកន្លែងនិងភារកិច្ចបណ្តាញរបស់ខ្លួន ។ សុវណ្ណ បានដឹងថាមានអ្នកខ្លះត្រូវអង្គការបញ្ជូនទៅរស់នៅតាមជនបទ និងអ្នកខ្លះនៅធ្វើការនៅទីក្រុងភ្នំពេញដដែល ។ ចាប់តាំងពីពេលនោះមក សុវណ្ណ អាចទាក់ទងតែជាមួយ ហាក់ ស៊ាងឡាយនី, ហេង ពេជ និង សៀង ហួរឡុង ប៉ុណ្ណោះ ។ ចំពោះការងារសម្ងាត់ទាំងឡាយ ហាក់ ស៊ាងឡាយនី ត្រូវបន្តទៅតាមរយៈទូតវៀតណាម, យូហ្គោស្លាវី និងរ៉ូម៉ានី ដោយប្រើរូបភាពចំហតាមអង្គការចាត់តាំងធ្វើការងារផ្សេងៗ ។

នៅក្នុងអំឡុងពេលរស់នៅក្នុងវាំង សុវណ្ណ បានខិតខំតាមដានសកម្មភាព សម្តេច សីហនុ តាំងពីពេលនៅជាប្រមុខរដ្ឋរហូតដល់ពេលលាលែងពីតំណែង ក្រៅពីនេះ សុវណ្ណ បាននិយាយស្តីនិងបញ្ចេញអាកប្បកិរិយាប៉ះពាល់ដល់នយោបាយរបស់អង្គការចំពោះ សម្តេច សីហនុ ដើម្បីបង្កើនទំនាស់រវាងភាគីទាំងពីរឲ្យកាន់តែខ្លាំងឡើង ។ ព្រមជាមួយគ្នានោះ សុវណ្ណ ខិតខំសម្របខ្លួនក្នុងជួរបដិវត្តន៍ និងអូសទាញមនោសញ្ចេតនាពីអ្នកដទៃទៀត ក្នុងគោលដៅពង្រីកកម្លាំងថ្មី និងបិទបាំងសកម្មភាពរបស់ខ្លួន ។

## ការចាប់ខ្លួននិងសួរចម្លើយ

សុវណ្ណ ត្រូវចាប់មកមន្ទីរស-២១នៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៧ ។ សុវណ្ណ ត្រូវបានសួរចម្លើយដោយ នៅ នី ចំនួន៦លើកនៅមន្ទីរស-២១ ។ សុវណ្ណ ចាប់ផ្តើមសសេរចម្លើយសារភាពនៅថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៧ និងសរសេរចប់នៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៧ ។ សុវណ្ណ បានរៀបរាប់អំពីប្រវត្តិការងារនិងផែនការក្បត់របស់ខ្លួននិងបានបញ្ជាក់ពីប្រវត្តិនិងសកម្មភាពរបស់មនុស្សមួយចំនួនទៀត ដូចជា ជួន ប្រសិទ្ធ, សារិន ឆាក និង សួង ស៊ីគឿន ។ សុវណ្ណ ត្រូវអង្គការកម្ទេចនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំដដែល ។

## ឈ្មោះអ្នកពាក់ព័ន្ធនៅក្នុងចម្លើយសារភាព

◆ ព្រំ ភឿន អតីតនិស្សិតនៅសូវៀត ◆ ជា ខន អតីតនិស្សិតនៅសូវៀត ◆ ហេង ពេជ អតីតនិស្សិតនៅសូវៀត នៅក្រសួងប-១ ផ្នែករៀបចំអគាររដ្ឋ ◆ អ៊ុក សុក នៅក្រសួងសាធារណការ ផ្នែកទំនប់ទឹក ◆ ឡាំ វីរី អតីតនិស្សិតនៅសូវៀត ផ្នែកទំនប់ទឹក ◆ ប៉ុច មគ្គបូរី នៅក្រសួងរ៉ែ ◆ អៀង សីហា នៅ

ក្រសួងទូរគមនាគមន៍ ផ្នែកផ្លូវរថភ្លើង ◆ ហាក់ ស៊ាងឡាយនី អនុរដ្ឋលេខាក្រសួងការបរទេស ផ្នែកពិធីការ ◆ គ្រិន លាន នៅសាលាបច្ចេកទេស ឫស្សីកែវ ◆ បូរីស ឡាប់សុស ជនជាតិសូវៀត ◆ តាន់ ឆៃហេង លេខាទី២ទូតនៅប្រទេសយូហ្គោស្លាវី ◆ ថាច់ សួង បុគ្គលិកទូត នៅប្រទេសយូហ្គោស្លាវី ◆ ហៃ គីមស៊ាង លេខាទី២ទូតនៅប្រទេសគុយបា ◆ ជួន ប្រាសិទ្ធ កម្មាភិបាលនៅក្រសួងការបរទេស ◆ សួង ស៊ីគឿន ក្រសួងការបរទេស ផ្នែកព័ត៌មាន ◆ សៀង ហួរឡុង ក្រសួងការបរទេស ផ្នែកវាលយន្តហោះ ◆ ស៊ីវ អតីតប្រធាន មន្ទីរសេ.គេ.៧០ នៅទីក្រុងហាណូយ ◆ ចាន់ អតីតលេខាមន្ទីរសេ.គេ.៧០ នៅទីក្រុងហាណូយ ◆ ប៉ែន ថុងអាន រស់នៅអាមេរិក ◆ ម៉ែន មុនីវ៉ាម ◆ លី គីមប៉ាក់ ◆ តាន់ ថាញ់ នៅសាលាបច្ចេកទេសខ្មែរ-សូវៀត ◆ មាន ប៊ុនឈួយ នៅក្រសួងកង់ឡានតាខ្មៅ ◆ ជា គីមថាន់ នៅអគ្គិសនីក្រុងភ្នំពេញ ◆ ជុំ សុខាន នៅអគ្គិសនីក្រុងភ្នំពេញ ◆ ឡុង នរិន្ទ នៅក្រសួងការបរទេស ◆ ហាក់ ផាដេទ្ធ នៅមន្ទីរពេទ្យ១៧មេសា ផ្នែកកុមារ ◆ ប៊ូ ឃិន នៅក្រសួងសាធារណការ ◆ អ៊ួក សាគុម នៅក្រសួងឧស្សាហកម្ម ◆ ស្រីច័ន្ទធឿន អតីតនិស្សិតសូវៀត ◆ មៀន កម្មាភិបាលយោធា ◆ សឿន កម្មាភិបាល យោធា ◆ ណៃ កម្មាភិបាលសេដ្ឋកិច្ច ◆ យឹន កម្មាភិបាលសេដ្ឋកិច្ច ◆ សារិន ឆាក នៅក្រសួងការបរទេស ។

**ណាយ សុផារី**

## ទូរលេខខ្មែរក្រហម

ជម្រាបបង សូមជ្រាប

១) ថ្ងៃ១៦-១៧-១៨ខែមេសា ខាងមុខនេះជាថ្ងៃបុណ្យឯករាជ្យផងជាថ្ងៃបុណ្យចូលឆ្នាំប្រពៃណីផង ។ ពេលបីថ្ងៃនេះ ស្នើបងណែនាំឲ្យគ្រប់សហករណ៍គ្រប់ការដ្ឋាន គ្រប់រោងចក្រ ក្រសួងមន្ទីរ សម្រាកការងារទាំងអស់ ទុកពេលវេលាឲ្យបងប្អូនកសិករនិងកម្មករយើងសម្រាកនិងកំសាន្តថ្ងៃបុណ្យ ។ ព្រមជាមួយនេះក៏ស្នើឲ្យរៀបចំរបបពិសេស ទាំងបាយទឹក ម្ហូបអាហារ នំចំណី ក្នុង៣ថ្ងៃនេះផង ។ ក្រៅពីនេះមិនបាច់ធ្វើមិទ្ទីងតាមកន្លែងមួយៗទេ ។ ថ្ងៃដំបូងមានតែពិធីគោរពទង់ជាតិនិងគោរពវិញ្ញាណក្ខន្ធនិងចាត់តាំងរួមគ្នាស្តាប់សេចក្តីថ្លែងការណ៍របស់គណៈប្រធានរដ្ឋតាមវិទ្យុជាតិយើងបានហើយ ។ រួចហើយចាត់តាំងធ្វើសេចក្តីប្តេជ្ញាគោរពពាក្យស្លោកសម្រាប់ ១៧ មេសា ១៩៧៨ ដែលផ្ញើជាប់ជាមួយ ។

២) នៅថ្ងៃ១៦ ខែ៤ វិទ្យុយើងមានកម្មវិធីដូចតទៅ ៖

ម៉ោង៧ព្រឹកគោរពទង់ជាតិ ។ សូមបងប្អូនទាំងអស់រៀបចំជួបជុំគ្នាមុនម៉ោង៧ ។ ដល់ម៉ោង៧ សូមប្រុងប្រៀបគោរពទង់ជាតិតាមបញ្ជារបស់វិទ្យុ ហើយច្រៀងចម្រៀងជាតិតាមវិទ្យុ ។ បន្ទាប់មកគោរពវិញ្ញាណក្ខន្ធតាមរបស់វិទ្យុផង ។ បន្ទាប់មកស្តាប់សេចក្តីថ្លែងការណ៍របស់គណៈប្រធានរដ្ឋ ។ អានពាក្យស្លោកទាំងអស់តាមផ្នែកនិងប្តេជ្ញាតាមពាក្យស្លោកនីមួយៗនោះ ។ ពិធីមានតែប៉ុណ្ណោះទេ ។ ក្រោយមកកំសាន្តនិងសម្រាក ។

ព្រមជាមួយនេះ វិទ្យុយើងនឹងមានចាក់ភ្លេង៣ថ្ងៃ៣យប់ជាប់ ។ សូមកន្លែងមួយៗរៀបចំឲ្យបងប្អូនសម្រាកនិងកំសាន្តនិងបំប៉នម្ហូបអាហារបីថ្ងៃនេះឲ្យបានពេញលេញ ។ ការរៀបចំយ៉ាងនេះនាំឲ្យប្រជាជនយើងកាន់តែផ្សារភ្ជាប់មនោសញ្ចេតនាជាមួយព្រឹត្តិការណ៍នៃចលនាបដិវត្តយើងផង ជាការបំប៉នកម្លាំងពលកម្មប្រជាជនយើងដើម្បីវាយសម្រុកឲ្យកាន់តែខ្លាំងថែមទៀតនៅពេលរួចបុណ្យផង ។

៣) ចំពោះកងទ័ពកម្មវិធីដូចគ្នាខាងលើដែរ តែចាំបាច់ត្រូវតែផ្លាស់វេនគ្នាប្រចាំការប្រយុទ្ធឲ្យម្ចាស់ការខ្លាំងជានិច្ច ។ ព្រមជាមួយនេះត្រូវមានចាត់តាំងផ្តល់នំចំណីជូនដល់សមរភូមិមុខផ្ទាល់ផង ។

៤) ក្នុងឱកាសដែលប្រជាជនយើងទូទាំងប្រទេសត្រៀមរៀបចំធ្វើបុណ្យទទួលអំណរខួបទី៣នៃមហាជ័យជម្នះ១៧មេសា១៩៧៥នេះ ខ្មាំងគ្រប់ប្រភេទក៏វាមមាញឹករកឱកាសដើម្បីប៉ុនប៉ងធ្វើសកម្មភាពបំផ្លាញបដិវត្តយើងលើសឆ្នាំមុនៗទៀត ។

ដូច្នេះក្នុងខែមេសានេះយើងត្រូវលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តឲ្យខ្ពស់ថែមទៀត ដើម្បីម្ចាស់ការគ្រប់យថាហេតុលើខ្មាំងសត្រូវគ្រប់ប្រភេទ ទាំងសមរភូមិមុខ ទាំងសមរភូមិក្រោយ ទាំងការពារក្បាលម៉ាស៊ីនដឹកនាំគ្រប់ថ្នាក់ ទាំងការពារឃ្លាំង ទាំងបង្ការខ្មាំងដាក់ថ្នាំបំពុលក្នុងបាយទឹកម្ហូបអាហារនំចំណីរបស់ប្រជាជនយើង... ។ល ។

ដោយភាតរភាពបដិវត្តយ៉ាងកក់ក្តៅបំផុត ។ ថ្ងៃ១-៤-៧៨, ម.៨៧០, (ឯកសារលេខ D១០៨៧)

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយ : យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៦០១ | ហ៊ីង ម៉ៅ ហៅ សន (ស្រី) | យុទ្ធនារី | កងពល៥០២ | ៦-៥-៧៧ | ១៤-៥-៧៧ |
| ២៦០២ | ថោង សេរីវុធ ហៅ វុន | ប្រធានប៉ុស្តិ៍ | សាធារណការ | ៣១-៣-៧៧ | ១៦-៥-៧៧ |
| ២៦០៣ | ម៉ៅ សុខា ហៅ លំ | ជំនួយការ | កងពល៤៥០ | ១១-១២-៧៦ | ១៦-៥-៧៧ |
| ២៦០៤ | ស្រី ឈាង ហៅ សាង | អនុលេខា | កងពល៩២០ | ២២-១១-៧៦ | ១៦-៥-៧៧ |
| ២៦០៥ | ឡុង ឌី ហៅ អុល | ប្រធានមន្ទីរ | កងពល៣១០ | ២៣-៣-៧៧ | ១៦-៥-៧៧ |
| ២៦០៦ | ពាច ពាង ហៅ ប៊ុន | អនុក្រុម | កងពល៣១០ | ១៤-៥-៧៧ | ២១-៥-៧៧ |
| ២៦០៧ | ស៊ូ ពៅ | យុទ្ធជន | កងពល៤៥០ | ១៤-៥-៧៧ | ២១-៥-៧៧ |
| ២៦០៨ | ដា លី ហៅ ស្រល់ | យុទ្ធជន | កងពល៣១០ | ១៦-៥-៧៧ | ២១-៥-៧៧ |
| ២៦០៩ | ឃឹម ហួន ហៅ ភាព | អនុក្រុម | កងពល៣១០ | ១៩-៥-៧៧ | ២១-៥-៧៧ |
| ២៦១០ | នូ ចិន | យុទ្ធជន | កងពល៣១០ | ១៩-៥-៧៧ | ២១-៥-៧៧ |
| ២៦១១ | សោម សយ ហៅ សេន | យុទ្ធជន | កងពល៣១០ | ១៦-៥-៧៧ | ១០-៦-៧៧ |
| ២៦១២ | បឿង ប៉ិត ហៅ បុល | យុទ្ធជន | កងពល៣១០ | ២៩-៥-៧៦ | ១០-៦-៧៧ |
| ២៦១៣ | ភើ ថន | ប្រធានមន្ទីរ | កងពល៣១០ | ១៧-៥-៧៦ | ១០-៦-៧៧ |
| ២៦១៤ | សាត សឿន ហៅ វឿន | យុទ្ធជនពិការ | កងពល៣១០ | ១៨-៤-៧៧ | ១០-៦-៧៧ |
| ២៦១៥ | គុំ បឿន ហៅ ហាន | យុទ្ធជនពិការ | កងពល៣១០ | ១៨-៤-៧៧ | ១០-៦-៧៧ |
| ២៦១៦ | ទឹម យ៉ា ហៅ សឿន (ស្រី) | មេក្រុម | កងពល៣១០ | ២១-៤-៧៧ | ១០-៦-៧៧ |
| ២៦១៧ | កែវ អឿន (ស្រី) | មេក្រុម | កងពល៣១០ | ២១-៤-៧៧ | ១០-៦-៧៧ |
| ២៦១៨ | នឹម ទី | ប្រធានមន្ទីរ | កងពល៣១០ | ៤-៣-៧៧ | ១០-៦-៧៧ |
| ២៦១៩ | ម៉ក់ យីហឿង ហៅ នឹម | ជំនួយការភ័ស្តុភារ | កងពល៣១០ | ៨-៥-៧៧ | ១០-៦-៧៧ |
| ២៦២០ | ដឹម ប៊ុត ហៅ សែ | យោធាកងធំ | កងពល៣១០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦២១ | ព្រុំ ចេង ហៅ ដាញ | ភ័ស្តុភារ | កងពល៣១០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦២២ | ម៉ី លឹមហ៊ត ហៅ ជិត | អនុនយោបាយ | កងពល៣១០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦២៣ | ព្រុំ សុក ហៅ ប្រុង | ភ័ស្តុភារ | កងពល៣១០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦២៤ | ចាប ឡៃ ហៅ ដាន | យោធាកងធំ | កងពល៣១០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦២៥ | ស៊ឹម ដាត ហៅ នី | លេខាកងធំ | កងពល៣១០ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៦២៦ | អែម អួ ហៅ ឈឿន | លេខាកងធំ | កងពល៣១០ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៦២៧ | ជៀន ចើម ហៅ ភ្វា | យោធាកងធំ | កងពល៣១០ | ២៦-៥-៧៧ | ១០-៦-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៦២៨ | សំ ភាត ហៅ ក្ដី | លេខាកងធំ | កងពល៣១០ | ១៦-៥-៧៧ | ១០-៦-៧៧ |
| ២៦២៩ | គីម ប៊ុន ហៅ ងឹម | លេខាកងធំ | កងពល៣១០ | ១៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៣០ | ព្រុំ ភន ហៅ ខ្មែន | លេខាកងធំ | កងពល៣១០ | ១៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៣១ | សែម តាក់ | លេខាកងធំ | កងពល៣១០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៦៣២ | ឌិត ឃិន ហៅ សឿន | លេខកងធំ | កងពល៣១០ | ២៣-៤-៧៧ | ១០-៦-៧៧ |
| ២៦៣៣ | យួស វឿន ហៅ ធឿន | លេខាកងធំ | កងពល៣១០ | ២៤-៤-៧៧ | ១០-៦-៧៧ |
| ២៦៣៤ | វ៉ែម រី ហៅ វឿង | លេខាកងធំ | កងពល៣១០ | ១២-៥-៧៧ | ១០-៦-៧៧ |
| ២៦៣៥ | ហោះ ហ៊ាន ហៅ រិទ្ធ | លេខាកងធំ | កងពល៣១០ | ១២-៥-៧៧ | ១០-៦-៧៧ |
| ២៦៣៦ | ទេន ញឿន ហៅ ញ៉ិល | លេខាកងធំ | កងពល៣១០ | ១២-៥-៧៧ | ១០-៦-៧៧ |
| ២៦៣៧ | កៅ មន | លេខាកងធំ | កងពល៣១០ | ៦-៣-៧៧ | ១០-៦-៧៧ |
| ២៦៣៨ | ព្រុំ ហោ ហៅ ហាន | អនុកងតូច | កងពល៣១០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៣៩ | ខ្វៃ ឆាក់ | នយោបាយកងតូច | កងពល៣១០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៦៤០ | សំ ឈឿត | យុទ្ធជន | កងពល៣១០ | ១-៦-៧៧ | ១០-៦-៧៧ |
| ២៦៤១ | ព្រុំ ស៊ាប ហៅ សាន | យុទ្ធជន | កងពល៣១០ | ១-៦-៧៧ | ១០-៦-៧៧ |
| ២៦៤២ | សាន់ ម៉េន ហៅ ថាន | យោធាកងតូច | កងពល៣១០ | ១-៦-៧៧ | ១០-៦-៧៧ |
| ២៦៤៣ | ម៉ូវ មី ហៅ វ៉ាត | អនុក្រុម | កងពល៣១០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៤៤ | សួន ហួន ហៅ សិត | មេក្រុម | កងពល៣១០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៦៤៥ | ជួរ តុង ហៅ រុន | មេក្រុមពេទ្យ | កងពល៣១០ | ១-៦-៧៧ | ១០-៦-៧៧ |
| ២៦៤៦ | ឌុប ផាត | យុទ្ធជន | កងពល៣១០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៤៧ | តាំង សំ ហៅ រ៉ុម | យុទ្ធជន | កងពល៣១០ | ២២-៥-៧៧ | ១០-៦-៧៧ |
| ២៦៤៨ | សោម ទូន ហៅ ផន | យុទ្ធជន | កងពល៣១០ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៤៩ | អំ អែម ហៅ អាន | យុទ្ធជន | កងពល៣១០ | ១៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៥០ | ហ៊ុយ រី ហៅ រីន (ស្រី) | យុទ្ធនារី | កងពល៣១០ | ១-៦-៧៧ | ១០-៦-៧៧ |
| ២៦៥១ | បាវ វ៉ាន ហៅ វ៉ាន់ (ស្រី) | យុទ្ធនារី | កងពល៣១០ | ១-៦-៧៧ | ១០-៦-៧៧ |
| ២៦៥២ | វ៉ង គន ហៅ កេន | យុទ្ធជន | កងពល៣១០ | ១-៦-៧៧ | ១០-៦-៧៧ |
| ២៦៥៣ | ប៊ុត ប៊ិន ហៅ ខេន | យុទ្ធជន | កងពល៣១០ | ៤-៦-៧៧ | ១០-៦-៧៧ |
| ២៦៥៤ | នួន ជឿន ហៅ រ៉េន | យុទ្ធជន | កងពល៣១០ | ៤-៦-៧៧ | ១០-៦-៧៧ |
| ២៦៥៥ | រស់ ហាន | យោធាកងធំ | កងពល៣១០ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៦៥៦ | គួយ កឿន ហៅ ឡូន | យុទ្ធជន | កងពល៣១០ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៦៥៧ | កោ លី | អនុក្រុម | កងពល៣១០ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៦៥៨ | មិត ឌីវ៉ាត ហៅ វ៉ាត | យុទ្ធជន | កងពល៤៥០ | ២៩-៥-៧៧ | ១០-៦-៧៧ |

**(នៅមានត)**

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

**ម៉ោង មួន**
**អតីតគិលានុបដ្ឋាកនៅមន្ទីរពេទ្យព្រះកុសុមៈ**
**(ពេទ្យលោកសង្ឃ)**

ឌុច ឆៀម បានបង្ហាញរូបថតមួយសន្លឹករបស់កូនប្រុសគាត់ ឈ្មោះ ម៉ោង មួន ដែលថតតាំងពីមុនឆ្នាំ១៩៧៥ គឺនៅពេល ចូលបម្រើការងារនៅមន្ទីរពេទ្យព្រះកុសុមៈ ។ ឆៀម ទើបតែបាន ឃើញរូបថតនេះនៅពេលដែលរបបខ្មែរក្រហមបញ្ចប់ ។ ពីមុនរូបថត នេះនៅនឹងប្អូនថ្លៃរបស់គាត់ជាអ្នកទុក ហើយគាត់មិនដែលបាន ឃើញរូបថតនេះទេ ។ នេះជារូបថតតែមួយសន្លឹកគត់ ដែលតំណាង ឲ្យ មួន ។ ខាងក្រោមនេះគឺជាអ្វីដែល ឆៀម ចងចាំអំពី មួន ។

ខ្ញុំនិងប្តីខ្ញុំមានស្រុកកំណើតនៅភូមិ ជីរំ ឃុំព្រៃស ស្រុកជង្កោ ។ យើងមានកូន ១០នាក់ ហើយកូន៥នាក់បានស្លាប់នៅ ក្នុងរបបខ្មែរក្រហម ។ កូនទី១ ឈ្មោះ ម៉ោង មួន និងកូនទី២ឈ្មោះ ម៉ោង មុត ត្រូវអង្គការយកទៅសម្លាប់ ។ កូនទី៣ ឈ្មោះ ម៉ោង ទី, កូនទី៤ឈ្មោះ ម៉ោង ច្រឹប និងកូនមួយទៀត ឈ្មោះ ម៉ោង អួន ស្លាប់ដោយខ្វះអាហារ ។ កាលនោះ ម៉ោង អួន ទើបតែមានអាយុមួយឆ្នាំ ។ ខ្ញុំមិនដឹង ទៅរកអាហារនៅកន្លែងណាឲ្យកូនហូបទេ ។ យើងមានតែគល់ត្នោតនិងគល់ឫស្សីប៉ុណ្ណោះ ។



**ម៉ោង មួន មុនឆ្នាំ១៩៧៥**

កូនរបស់ខ្ញុំឈ្មោះ ម៉ោង មួន កើតឆ្នាំម្សាញ់ ។ វាស្លូត ណាស់ ។ វាមានសម្បុរស្រអែម ខ្ពស់ជាងឪពុកវា ហើយមាន ចិត្តល្អណាស់ ។ ជួនកាលវាយកលុយសម្រាប់ទិញនំហូបខ្លួនឯង ទៅដាក់ទានឲ្យអ្នកក្រខ្សត់អស់ ។

កូនខ្ញុំរៀននៅសាលាព្រៃស្តី ឃុំចោមចៅ ។ ឪពុកមារបស់ វាបានហៅវាប្រឡងចូលធ្វើពេទ្យ ។ ខ្ញុំទិញម៉ូតូម៉ូប៊ីឡែតមួយឲ្យវា ជិះទៅធ្វើការ ។

ក្រោយពេលប្រឡងជាប់បានធ្វើពេទ្យហើយ មួន រៀបការ ។ ប្រពន្ធវាឈ្មោះ យិន សុខឃឿន ជាអ្នកភូមិជាមួយគ្នា ។ ពេល រៀបការហើយប្តីប្រពន្ធវារស់នៅផ្ទះខ្ញុំ ។

នៅក្នុងរបបលន់នល់ ភូមិរបស់ខ្ញុំជាចំណុចស៊ីបនៃគ្រាប់ ផ្លោង ។ ក្រៅពីគ្រាប់ផ្លោង យើងភ័យនឹងខ្មែរក្រហមដែលចេះ តែឆ្មក់ចូលមក ។ យើងមិនសូវនៅដេកលើផ្ទះទេ ដេកតែក្នុង លេណដ្ឋាន ។

ពេលបានទទួលជ័យជម្នះ ខ្មែរក្រហមប្រាប់ប្រជាជនថាឲ្យចេញ មួយរយៈសិនដើម្បីអង្គការរៀបចំទីក្រុងភ្នំពេញ ។ យើងត្រូវតែចេញ តាមបញ្ជា ព្រោះកងទ័ពអាវខ្មៅទាំងនោះកាន់កាំភ្លើង ។ បើមានអ្នក ណាម្នាក់រឹងរូសមិនព្រមចេញ កងទ័ពទាំង នោះបាញ់ចោលនៅនឹងមុខយើង ។ យើង បររទេះគោចេញពីផ្ទះ នៅតាមផ្លូវ យើង ឃើញមនុស្សស្លាប់ច្រើនណាស់ ។

ពេលជម្លៀសចេញ ប្រពន្ធរបស់ មួន មានកូនស្រីម្នាក់ចេះអង្គុយ ហើយ កំពុងតែមានផ្ទៃពោះកូនមួយទៀត ។ វា ធ្វើដំណើរទៅជាមួយខ្ញុំដែរ ។ នៅតាមផ្លូវ កងទ័ពខ្មែរក្រហមប្រាប់យើងថានាំយើង ទៅជួបអង្គការ ។ យើងសួរថា តើអង្គការ នៅកន្លែងណា? ខ្មែរក្រហមចេះតែឆ្លើយថា ទៅមុខទៀតនឹងបានជួបអង្គការហើយ ។ យើងបររទេះគោទាំង យប់ទាំងថ្ងៃនៅតែរកអង្គការមិនឃើញ ។ ពេលយើងទៅដល់វត្ត មួយខ្មែរក្រហមប្រាប់ថា អង្គការមិននៅទីនេះទេទៅមុខទៀត ។ យើងទៅដល់វត្តប្រធាតុទើបឈប់សម្រាកនៅទីនោះ ហើយ ខ្មែរក្រហមបែងចែកយើងជាក្រុមៗនិងឲ្យយើងធ្វើខ្ទមសម្រាប់ រស់នៅ ។ ពេលយើងចាកចេញពីផ្ទះ យើងយកបានតែប្រហុក អំបិល អង្ករ និងរបស់របរមានតម្លៃបន្តិចបន្តួចប៉ុណ្ណោះ ។ មាន អ្នកខ្លះយកលុយទៅយ៉ាងច្រើន ប៉ុន្តែលុយនោះ មិនអាចយកទៅ

ទិញទំនិញបានក៏បោះចោលនៅតាមផ្លូវអស់ ។

ខ្មែរក្រហមឲ្យយើងហូបរួម ។ មុនដំបូងយើងហូបបាយ ក្រោយមកហូបបបរ ។ អង្គការស្វែងរកជាងធ្វើកាំបិតពូថៅ ។ ដោយប្តីខ្ញុំប្រកបរបរធ្វើកាំបិតពូថៅតាំងពីមុនរបបខ្មែរក្រហម អង្គការបានជ្រើសរើសប្តីខ្ញុំឲ្យធ្វើការងារនេះ ហើយផ្លាស់គាត់ឲ្យទៅរស់នៅស្ពានថ្ម ។

ក្រុមគ្រួសារមួយចំនួនត្រូវអង្គការហៅឡើងឡានទៅខេត្តបាត់ដំបង ។ ដោយសារនៅទីនេះ យើងគ្មានអាហារគ្រប់គ្រាន់ ខ្ញុំសុំអង្គការទៅបាត់ដំបងដែរ ប៉ុន្តែអង្គការមិនអនុញ្ញាត ។ ខ្ញុំសួរមេក្រុមខ្ញុំឈ្មោះ តាប៉ិច ថា "ហេតុអ្វីបានជាមិនឲ្យក្រុមគ្រួសារខ្ញុំទៅបាត់ដំបងដែរ?" គាត់ឆ្លើយថា "ចង់ទៅរកស្លាប់ឬ?" ។ តាមពិត អ្នកដែលទៅខេត្តបាត់ដំបងទាំងប៉ុន្មានគឺអង្គការយកទៅដាក់នៅគាស់ក្រឡ ហើយស្លាប់នៅទីនោះទាំងអស់ ។ ម្យ៉ាងទៀត អង្គការចង់ទុកប្តីខ្ញុំឲ្យធ្វើកាំបិតពូថៅផង ។

ខ្ញុំមានផ្ទៃពោះតាំងពីពេលជម្លៀសចេញពីភូមិ ។ ពេលខ្ញុំឆ្លងទន្លេ គ្មានពេទ្យត្រឹមត្រូវទេ មានតែអ្នកជិតខាងដែលជម្លៀសទៅជាមួយគ្នាជួយបង្កើតកូនឲ្យ ។ ពេលខ្ញុំឈឺពោះ កូនខ្ញុំរត់ទៅប្រាប់ប្តីខ្ញុំថាខ្ញុំជិតឆ្លងទន្លេហើយ ។ គាត់លួចស្កាត់មកជួបខ្ញុំ ។ ពេលសម្រាលកូនរួច ខ្ញុំអត់មានអីហូបទេ ។ ពេលកូនខ្ញុំអាយុបាន១ឆ្នាំ វាស្លាប់ដោយសារអត់ទឹកដោះជៅ ព្រោះខ្ញុំអត់មានអីហូបគ្រប់គ្រាន់ទើបគ្មានទឹកដោះឲ្យកូនជៅ ។ ពេលខ្ញុំទៅពេទ្យ ពេទ្យឲ្យថ្នាំដែលមានសណ្ឋានដូចអាចម៍ទន្សាយមកខ្ញុំ ។ ពេលយើងឈឺអ្វីក៏ហូបថ្នាំអាចម៍ទន្សាយនេះដែរ ។

អង្គការមិនឲ្យយើងរស់នៅជួបជុំគ្នាទេ ។ កូនៗរបស់ខ្ញុំនៅផ្សេង ប្តីខ្ញុំនៅផ្សេង ខ្ញុំនៅផ្សេង ។ ពេលមួយ ដោយនឹករឭកកូនពេក ខ្ញុំលួចទៅលេងកូនខ្ញុំដែលធ្វើការនៅកងចល័តនារី ។ ខ្ញុំទុកកូនតូចៗឲ្យចាំនៅលើថ្នល់ ហើយខ្ញុំចុះទៅជួបកូនធំ ។ ពេលជួបខ្ញុំ វាយំហើយដើរគេចចេញទៅ ។ ខ្ញុំឆ្ងល់យ៉ាងខ្លាំង ។ រី ជាប្រធានក្រុមរបស់កូនខ្ញុំ ហៅខ្ញុំទៅកសាងថា "យាយឯងដឹងទេ អ្នកខ្លះខ្លាចកូនហូបមិនឆ្អែត យកបាយទៅដាក់នៅលើដើមសង្កែ ពេលម្តាយទៅបាត់ កូនទៅយកបាយពីដើមសង្កែមកស៊ី ។ អង្គការប្រជុំរាល់ថ្ងៃរឿងម្តាយជួបកូនហ្នឹងណា៎" ។

នៅចុងឆ្នាំ១៩៧៥ អង្គការសួរនាំអំពីប្រវត្តិរូបក្រុមគ្រួសារយើង ។ ខ្ញុំប្រាប់តាមត្រង់ថា ប្តីខ្ញុំជាជាងដែក ចំណែកកូនប្រុសខ្ញុំឈ្មោះ មួន ធ្វើពេទ្យនៅពេទ្យព្រះកុសុមៈ ។ កន្លះខែក្រោយមក អង្គការបញ្ជូនកូនខ្ញុំទៅកាប់ឫស្សី ហើយក៏បាត់ដំណឹងរហូត ។ ប្រពន្ធវាមិនដឹងថាប្តីវាត្រូវអង្គការយកទៅសម្លាប់ចោលទេ ។ វាចេះតែរង់ចាំផ្លូវប្តីមិនឃើញមកវិញសោះ ។ ក្រោយមក អង្គការយកកូនប្រសាខ្ញុំទៅដាក់នៅទួលក្រសាំង ។ ចំណែកកូនដែលឈឺអង្គការយកទៅដាក់ចោលនៅមន្ទីរពេទ្យ ហើយមិនឲ្យម្តាយវាទៅថែរក្សាទេ ។ កូននោះស្លាប់នៅមន្ទីរពេទ្យ ចំណែកកូននៅក្នុងពោះកូនប្រសាខ្ញុំក៏ស្លាប់នៅក្នុងពោះតាំងពីមុនអង្គការយកប្តីវាទៅម្ល៉េះ ដោយសារការធ្វើការងារហួសកម្លាំងនិងគ្មានអាហារគ្រប់គ្រាន់ ។

ក្រោយពេលដែលយកកូនខ្ញុំទៅសម្លាប់ហើយ អង្គការចេះតែមកសួរខ្ញុំថាតើខ្ញុំនឹកកូនខ្ញុំទេ? ខ្ញុំឆ្លើយថា ខ្ញុំអត់នឹកទេ ព្រោះកូនខ្ញុំទៅទីនោះមានអង្គការជាអ្នកឧបត្ថម្ភហើយ ។ បើខ្ញុំហ៊ានឆ្លើយថានឹក ខ្ញុំប្រាកដជាត្រូវអង្គការសម្លាប់ ។

មានពេលមួយ ប្តីខ្ញុំធ្វើឲ្យផ្ទុះគ្រាប់ដែលគាត់បម្រុងយកទៅធ្វើកាំបិត ហើយដៃរបស់គាត់មុតនឹងអំបែងគ្រាប់ ។ អង្គការប្រាប់ឲ្យគាត់ទៅយកប្រហុកពីផ្ទះបាយមកបិទដៃ ។ ពេលនោះហើយដែលយើងបានប្រហុកខ្លះគ្រាន់ហូប ។ ក្រោយមក អង្គការចាត់តាំងប្តីខ្ញុំឲ្យទៅធ្វើការនៅរោងជាងដែកក្នុងភូមិព្រោះនៅក្នុងភូមិខ្វះជាងដែក ។

ចុងឆ្នាំ១៩៧៨ អង្គការប្រាប់ឲ្យយើងជីករណ្តៅនៅក្បែរផ្ទះដោយប្រាប់ថាសម្រាប់ចិញ្ចឹមត្រី ។ ជីករួចហើយ អង្គការធ្វើនំបញ្ចុកឲ្យយើងហូប ។ កូនៗរបស់ខ្ញុំពុលនំបញ្ចុកស្ទើរស្លាប់ស្ទើររស់ ចំណែកខ្ញុំមិនបានហូបនំបញ្ចុកទេ ព្រោះកងទ័ពវៀតណាមវាយចូលមករំដោះទាន់ ។ ក្រោយពេលរបបខ្មែរក្រហមដួលរលំ ទើបយើងដឹងថាអង្គការមានបំណងសម្លាប់យើងដោយដាក់ថ្នាំបំពុលក្នុងនំបញ្ចុក ។

ពេលមកដល់ភូមិវិញ ផ្ទះរបស់ខ្ញុំត្រូវរុះរើខ្ទេចខ្ទីអស់ ។ ខ្ញុំបានយករូបថតនេះពីប្អូនថ្លៃរបស់ខ្ញុំមករក្សាទុក ។ ខ្ញុំគិតថានេះប្រហែលជារូបថតតែមួយសន្លឹកគត់ដែល មួន បានថត ។

បច្ចុប្បន្នសុខភាពរបស់ខ្ញុំមិនសូវល្អទេ ដោយសារតែអារម្មណ៍

របស់ខ្ញុំដក់ជាប់តែនឹងកូនៗ ដែលបាត់ខ្លួននិងស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ពេលឃើញរូបថតកូនខ្ញុំម្ដងៗ ខ្ញុំនឹកឃើញការលំបាកវេទនារកអ្វីប្រៀបពុំបាននៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំយល់សប្ដិឃើញកូនខ្ញុំមករកខ្ញុំ ប៉ុន្ដែវាមិននិយាយស្ដីរកខ្ញុំទេ ។ នៅរាល់ថ្ងៃសីលខ្ញុំតែងធ្វើបុណ្យឧទ្ទិសកុសលទៅឲ្យវាជានិច្ច ។ ◆◆◆

## សេក មឿន

## អតីតធាហានអាកាសចរណ៍ស៊ីវិល

*ទៀង ឃួន សព្វថ្ងៃអាយុ៦៥ឆ្នាំ រស់នៅភូមិប្រការ សង្កាត់ព្រែស ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ បង្ហាញភាពរីករាយលាយឡំនឹងការសោកស្ដាយនៅពេលដែលគាត់មើលរូបថតប្ដីរបស់គាត់ ។ ឃួន រំឭកឡើងវិញថា ÷*

រូបថតនេះជារូបរបស់ប្ដីខ្ញុំថតជាមួយមិត្តភក្ដិគាត់ក្នុងសម្លៀកបំពាក់ទាហានអាកាសចរណ៍ ។ រូបនេះថតនៅឆ្នាំ១៩៦៦ ។ ប្ដីខ្ញុំឈរនៅខាងស្ដាំគាត់ ឈ្មោះ សេក មឿន ។ ពេលយើងជម្លៀសចេញនៅឆ្នាំ១៩៧៥ យើងមិនបានយករូបថតនេះទៅជាមួយទេ ដោយសាររូបថតនេះ នៅនឹងម្ដាយក្មេកខ្ញុំនៅឃុំព្រែកអំបិលឯណោះ ។ ហេតុនេះហើយទើបខ្ញុំមិនដែលឃើញរូបថតគាត់សោះរហូតទាល់តែគាត់ទៅយកពីម្ដាយគាត់នៅព្រែកអំបិលក្រោយឆ្នាំ១៩៧៩ ។

ខ្ញុំមានកំណើតនៅស្រុកព្រែកប្បាស ខេត្តតាកែវ ។ ប្ដីខ្ញុំមានកំណើតនៅឃុំព្រែកអំបិល ខេត្តកណ្ដាល ។ ពេលយើងនៅជាគូដណ្ដឹងនឹងគ្នា គាត់ខស្សរាហ៍ចុះឡើងលេងផ្ទះខ្ញុំណាស់ ។ ប្ដីខ្ញុំជាមនុស្សស្លូតបូត ចិត្តល្អ មិនដែលឈ្លោះទាស់ទែងសម្ដីតូចធំជាមួយអ្នកជិតខាងទេ ទោះទៅទីណាក៏មានអ្នកស្រលាញ់រាប់អានគាត់ដែរ ។

ប្ដីខ្ញុំរៀនសូត្របានជ្រៅជ្រះ គាត់ចេះនិយាយទាំងភាសាអង់គ្លេស ភាសាបារាំង និងភាសាចិន ។ គាត់ចូលធ្វើជាទាហានអាកាសចរណ៍តាំងពីមុនរៀបការជាមួយខ្ញុំទៅទៀត ។ គាត់មាននាទីយាមពីសយន្តហោះ ។ ក្រោយរៀបការរួចយើងសង់ផ្ទះមួយនៅជិតបន្ទាយធ្វើការរបស់គាត់ ។ គាត់មានប្រាក់ខែត្រឹមតែ៤០០រៀលប៉ុណ្ណោះ ។ ហេតុដូចនេះ ពេលខ្លះយើងបន្ទំចិត្តលួចសាំងយន្តហោះយកទៅលក់ដើម្បីយកប្រាក់មកបង្គ្រប់ការចំណាយក្នុងគ្រួសារ ។

នៅឆ្នាំ១៩៦០ ប្ដីខ្ញុំបានស្ម័គ្រចិត្តចូលសមរភូមិប្រយុទ្ធតតាំងជាមួយខ្មែរក្រហម ។ គាត់ទៅច្បាំងជាច្រើនកន្លែងដូចជាកំពង់ធំ តាំងគោក ស្គន់ ស្វាយមាស ព្រៃទទឹង ទន្លេបិទ ។ ខ្ញុំនាំកូនទៅតាមគាត់សឹងតែគ្រប់កន្លែងដែលគាត់ផ្លាស់ទៅ ហេតុនេះហើយទើបកូនប្រុសច្បងរបស់ខ្ញុំមិនចេះអក្សររហូតដល់សព្វថ្ងៃដោយសារមិនបានចូលរៀនព្រោះរវល់តែដើរតាមឪពុកទៅច្បាំង ។ ជួនកាលខ្ញុំយាមជំនួសប្ដីខ្ញុំដើម្បីឲ្យគាត់បានសម្រាកខ្លះ ។

នៅឆ្នាំ១៩៧៣ ប្ដីខ្ញុំបានសុំលាលែងពីជួរទាហានរួចមកបើកឡាននៅតាខ្មៅ ។ ម្ដងនេះក៏ខ្ញុំទៅតាមគាត់នៅតាខ្មៅដែរ ។ ក្រោយពីធ្វើការនៅតាខ្មៅបានមួយរយៈ ប្ដីខ្ញុំចូលធ្វើទាហានវិញហើយផ្លាស់មកនៅបន្ទាយវ៉ាំងកាត់ ខ្ញុំក៏មកជាមួយតាមគាត់ទៀត ។ ពេលនោះខ្ញុំកំពុងមានផ្ទៃពោះកូនទីបួន ។ គាត់ត្រូវបញ្ជូនទៅរៀនក្បួនទ័ពនៅប្រទេសវៀតណាម ។ ថ្ងៃដែលប្ដីខ្ញុំឡើងយន្តហោះ ខ្ញុំមានគ្រោះថ្នាក់បណ្ដាលឲ្យស្លាប់កូននៅក្នុងពោះ ។ គាត់ក៏ត្រឡប់មកវិញដឹកខ្ញុំទៅមន្ទីរពេទ្យនិងនៅមើលថែខ្ញុំរហូតទាល់តែខ្ញុំជាសះស្បើយ ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសយើងចេញពីបន្ទាយវ៉ាំងកាត់ ។ យើងធ្វើដំណើរចេញមកជាមួយនឹងចានឆ្នាំងអង្ករ និងសម្លៀកបំពាក់តែពីរបីកំប្លេប៉ុណ្ណោះ ។ ខោអាវទាហានរបស់ប្ដីខ្ញុំក៏ខ្ញុំយកទៅជាមួយដែរ ប៉ុន្ដែយើងបានបោះវាចោលតាមផ្លូវព្រោះខ្លាចខ្មែរក្រហមឆែកឆេររកឃើញ ។ យើងធ្វើដំណើរទៅស្រុកកំណើតរបស់ខ្ញុំនៅខេត្តតាកែវ ។

ពេលដែលយើងទៅដល់តាកែវអ្នកភូមិមិនរាក់ទាក់ស្វាគមន៍យើងទេ ព្រោះយើងជាប្រជាជនជម្លៀស ។ សូម្បីឪពុកម្ដាយបងប្អូនខ្ញុំដែលជាប្រជាជនមូលដ្ឋាននៅទីនោះក៏ត្រូវអង្គការហាមឃាត់មិនឲ្យនិយាយជាមួយយើងដែរ ។ អង្គការចាត់តាំងឲ្យយើងទៅរស់នៅភូមិមួយឆ្ងាយពីភូមិកំណើតរបស់ខ្ញុំ ។ អង្គការឲ្យខ្ញុំធ្វើជាអ្នកវាយកម្ទេចសាលា វិហារ គាស់រំលើងផ្លូវខ្មោចចិន ហើយឲ្យប្ដីខ្ញុំវេញខ្សែនិងឡើងត្នោត ។ ប្ដីខ្ញុំមិនធ្លាប់ធ្វើការងារទាំងអស់នេះពីមុនមកទេ ប៉ុន្ដែគាត់ខំប្រឹងធ្វើដើម្បីកុំឲ្យអង្គការចោទប្រកាន់ថាគាត់ជានាយទុន ។

ជារៀងរាល់យប់ មានរទេះគោពី១៣ទៅ១៧គ្រឿងដឹក

មនុស្សចេញពីភូមិ ។ អ្នកដែលត្រូវដឹកទៅភាគច្រើនជាទាហានលន់នល់ ។ នៅពេលដែលយើងសួរថាដឹកមនុស្សយកទៅណា អង្គការប្រាប់យើងថាដឹកយកទៅលត់ដំ ។ ខ្ញុំសួរអង្គការថា ហេតុអ្វីក៏មិនយកគ្រួសារខ្ញុំទៅផង អង្គការប្រាប់ថាខ្ញុំមិនទាន់ដល់ពេលលត់ដំទេ នៅទីនេះសិនទៅចាំទៅពេលក្រោយ ។ តាមការពិតអង្គការយកមនុស្សទៅសម្លាប់ ព្រោះខ្ញុំឃើញសម្លៀកបំពាក់និងអីវ៉ាន់របស់ប្រជាជនទាំងនោះត្រូវអង្គការដឹកមកវិញ ។


សេក មឿន (រូបខាងស្តាំ) ថតនៅឆ្នាំ១៩៦៦

ក្នុងរដូវភ្ជួរឆ្នាំ១៩៧៥ អង្គការបានបញ្ជូនយើងទៅខេត្តបាត់ដំបង ។ យើងធ្វើដំណើរប្រមាណ៤យប់ទើបទៅដល់សង្កាត់ស្ពានស្រែង ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។ ទៅដល់ស្រុកនោះហើយក៏យើងមិនបានរស់នៅលាយឡំជាមួយប្រជាជនមូលដ្ឋានដែរ អង្គការដាក់យើងឲ្យនៅជាមួយប្រជាជន១៧មេសាដូចគ្នា ។ អង្គការបានចែកបុស្ស៊ីនិងស៊ឹកឲ្យយើងសង់រោងនៅដោយខ្លួនឯង ។ ពេលនោះជារដូវវស្សា ។ ទៅដល់ដំបូង ការរស់នៅនិងហូបចុកមិនសូវតឹងរ៉ឹងពេកទេ ។ យើងនៅមានពេលសម្រាកនិងមានឱកាសចាក់ចម្រៀងពីរបបមុនស្តាប់នៅក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ ។ ប្តីខ្ញុំនៅធ្វើជាអ្នកឡើងត្នោតដដែល ចំណែកខ្ញុំ អង្គការឲ្យស្ទូងស្រូវ ក្រោយមកដោយខ្ញុំខ្លាចឈ្លើងពេកអង្គការឲ្យខ្ញុំទៅកិនស្រូវ ។

ខ្ញុំធ្លាប់ត្រូវអង្គការចាប់ឃុំនៅក្នុងជង្រុកស្រូវចាស់មួយដោយសារអង្គការឆែកឃើញអង្ករមួយក្តាប់ដែលខ្ញុំលាក់នៅក្នុងហោប៉ៅអាវ ។ តាមការពិតអង្ករនោះមិនមែនខ្ញុំមានបំណងលាក់ទុកទេ កូនស្រីខ្ញុំបានយកអង្ករមកដាក់ក្នុងហោប៉ៅអាវខ្ញុំពេលខ្ញុំកំពុងអង្គុយកិនស្រូវទាំងខ្ញុំមិនបានដឹងខ្លួនផង ។ ខ្ញុំជាប់នៅក្នុងឃ្លាំងនោះមិនដល់មួយថ្ងៃទេ អង្គការក៏ដោះលែងខ្ញុំត្រឡប់មកផ្ទះវិញ ។

ពេលកងទ័ពវៀតណាមវាយចូលក្នុងឆ្នាំ១៩៧៩ យើងរត់ទៅសៀមរាបក្នុងគោលបំណងឆ្លងមកស្រុកកំណើតវិញ ។ ម្យ៉ាងទៀតយើងចង់ស្នាក់នៅសៀមរាបជាបណ្តោះអាសន្នសិនព្រោះយើងយល់ថានៅសៀមរាបមិនសូវមានការគំរាមកំហែងពីខ្មែរក្រហម ។ ពេលនោះខ្ញុំកំពុងមានផ្ទៃពោះកូនទី៥ ប្តីខ្ញុំសុខចិត្តហែលទឹកឆ្លងស្ទឹងយកមាសទៅដូរអង្ករនិងម្ហូបមកឲ្យខ្ញុំ ។ ពេលនោះគ្រោះថ្នាក់ខ្លាំងណាស់ គាត់គោងតែធុងមួយហែលឆ្លងស្ទឹងទាំងទៅទាំងមក ។ នៅសៀមរាបមិនយូរប៉ុន្មាន យើងធ្វើដំណើរត្រឡប់មកព្រែកអំបិលដែលជាស្រុកកំណើតរបស់ប្តីខ្ញុំ ។ ទៅដល់នោះយើងគ្មានអង្ករបរិភោគទេ យើងដើរដូរមាសយកក្រមារូច ទើបយកក្រមាទៅដូរយកម្ហូប ។

ថ្វីត្បិតតែប្តីខ្ញុំទើបនឹងស្លាប់នៅសម័យក្រោយនេះ ប៉ុន្តែរូបថតរបស់គាត់នៅតែរឭកពីគ្រាកម្សត់កម្រដែលយើងធ្លាប់ឆ្លងកាត់ជាមួយគ្នា ។ ខ្ញុំបានប្តីម្នាក់នេះសំណាងណាស់ គាត់មិនដែលឲ្យខ្ញុំលំបាកទេ ។ គាត់មិនដែលឲ្យខ្ញុំបោកគក់សម្លៀកបំពាក់ឲ្យគាត់ទេ ។ ពេលខ្ញុំសម្រាលកូន គាត់បម្រើខ្ញុំសព្វគ្រប់ ។ ខ្ញុំអាល័យគាត់ណាស់ ។

**ប៊ាន ពីវ៉ាន់ និង ស៊ុំ សាឌីណា**

# អតីតអ្នកទោសពីរនាក់នៅគុកព្រៃស

ឈឿន ចឹក និង អេង ចក់ ជាអ្នកទោសនៅគុកព្រៃស ដែលបានលួចរត់ចេញពីគុក ប៉ុន្តែត្រូវខ្មែរក្រហមចាប់បានវិញ ហើយបញ្ជូនទៅមន្ទីរស-២១ ។ ឈឿន ចឹក ត្រូវបានចាប់ខ្លួនបន្ទាប់ពីឪពុករបស់គាត់ ឈឿន ត្រូវអង្គការបញ្ជូនឲ្យទៅកាប់ឈើនៅក្រចេះហើយបាត់ខ្លួន ។ ចំណែក អេង ចក់ ត្រូវបានចាប់ខ្លួន ព្រោះតែមានឪពុកជាអតីតទាហានលន់នល់ពាក់សក្តិមួយ ។ អ្នកទាំងពីរត្រូវខ្មែរក្រហមបញ្ជូនមកគុកព្រៃសក្នុងពេលដំណាលគ្នា គឺនៅឆ្នាំ១៩៧៧ ។

គុកព្រៃសគឺជាសាខាមួយក្នុងចំណោមសាខាទាំងប្រាំមួយរបស់មន្ទីរស-២១ (ទួលស្លែង) ដែលជាមន្ទីរសន្តិសុខធំបំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជីវិតរបស់អ្នកទោសនៅព្រៃស មានលក្ខណៈប្រសើរជាងច្រើនបើប្រៀបធៀបទៅហ្នឹងអ្នកទោសនៅទួលស្លែង ។ អ្នកទោសទាំងអស់ត្រូវបានចាត់តាំងធ្វើការងារដូចជាលើកភ្លឺស្រែ គាស់គល់ ដាំបន្លែបង្កា និងធ្វើស្រែ ។ អ្នកទោសមួយចំនួនបានលួចរត់ចេញពីគុក ហើយនៅរស់រានមានជីវិតរហូតសព្វថ្ងៃ ។ មួយចំនួនទៀតត្រូវចាប់បានមកវិញហើយបញ្ជូនមកគុកព្រៃសឬមន្ទីរស-២១ ប្រសិនបើរកឃើញថាមានកំហុសធ្ងន់ធ្ងរ ។


ឈឿន ចឹក នៅក្នុងមន្ទីរស-២១

ឈឿន ចឹក មានអាយុ១២ឆ្នាំ (ឆ្នាំ១៩៧៧) កូនចៅចិន កើតនៅភូមិសំរោង ឃុំសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ ឈឿន ហើយម្តាយឈ្មោះ ខន ។ មុនឆ្នាំ១៩៧៥ ឪពុកម្តាយរបស់ ចឹក ជាអ្នកលក់បន្លែនៅភ្នំពេញ ។

នៅមុនឆ្នាំ១៩៧៥ ចឹក រៀនថ្នាក់ទី១១ ។ ក្រោយឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ ចឹក ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅភូមិរការកោង ឃុំរការកោង ស្រុកមុខកំពូល ខេត្តកណ្តាល ។

នៅខែ៦ ឆ្នាំ១៩៧៥ ស្រ៊ី កម្មាភិបាលរោងចក្រជួសជុលម៉ាស៊ីនព្រែកព្នៅ បានប្រកាសរកអ្នកចេះជួលជុលម៉ាស៊ីន ។ ឪពុករបស់ ចឹក (ឈឿន) ក៏ទៅចុះឈ្មោះ ហើយ ស្រ៊ី បាននាំ ឈឿន ឲ្យទៅធ្វើការនៅកន្លែងជួសជុលម៉ាស៊ីននៅមន្ទីរ១៧ ព្រែកព្នៅ ។ ពេលនោះ ចឹក បានទៅតាមឪពុក ។

ឆ្នាំ១៩៧៦ អង្គការចាត់តាំងឲ្យ ឈឿន ទៅធ្វើកង់នៅភ្នំពេញ ហើយ ចឹក និងម្តាយត្រូវអង្គការចាត់តាំងឲ្យទៅកាប់ព្រៃនៅកោះចិន ។ ធ្វើការនៅភ្នំពេញបានរយៈពេលបីខែ ឈឿន ត្រូវអង្គការចាត់តាំងឲ្យទៅកាប់ឈើនៅខេត្តក្រចេះ ហើយក៏បាត់ដំណឹងរហូត ។ ចំណែក ចឹក និងម្តាយត្រូវអង្គការចាត់តាំងឲ្យមកដាំបន្លែនៅប្រាំងចំរេះវិញ ។

ការចាត់តាំង ឈឿន ឲ្យទៅកាប់ព្រៃនៅក្រចេះអាចជាលេសមួយរបស់ខ្មែរក្រហមក្នុងការយក ឈឿន ទៅសម្លាប់ចោល ។ មុនពេលចូលឆ្នាំខ្មែរឆ្នាំ១៩៧៧ ក្រុមគ្រួសាររបស់ ចឹក ដែលរួមមានម្តាយនិងបងប្អូនបួននាក់ទៀតត្រូវអង្គការបញ្ជូនមកគុកព្រៃសទាំងអស់ ។ អ្នកទាំងប្រាំមួយ ត្រូវបំបែកឲ្យនៅក្រុមផ្សេងគ្នា ហើយគាស់គល់ឈើនិងស្ទូងស្រូវ ។

ចំណែក អេង ចក់ មានអាយុ១២ឆ្នាំដែរ កូនចៅចិន កើតនៅភូមិដីស្រផែ ខេត្តតាកែវ ។ ឪពុកឈ្មោះ អេង ជាអតីតទាហានពាក់សក្តិមួយ ហើយស្លាប់នៅសមរភូមិតាកែវ ។ ម្តាយឈ្មោះ គាត ។ មុនឆ្នាំ១៩៧៥ ចក់ រៀនថ្នាក់ទី១២ ។ នៅឆ្នាំ១៩៧៦ ជ្រុន និង សូ ដែលជាអ្នកទទួលខុសត្រូវកន្លែងជួសជុលម៉ាស៊ីនស្ទឹងមានជ័យបាននាំ ចក់ និងម្តាយ ព្រមទាំងបងប្អូនបួននាក់ទៀត មករស់នៅជាមួយខ្លួននៅភ្នំពេញ ។ បងស្រីរបស់ ចក់ ត្រូវបានដាក់ឲ្យនៅកងនារី ហើយពីរនាក់ទៀត ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើស្រែ ចំណែក ចក់ ស្នាក់នៅអង្គភាព

កុមារស៊ីងមានជ័យ ។ នៅឆ្នាំ១៩៧៧មុនបុណ្យចូលឆ្នាំខ្មែរ ក្រុមគ្រួសាររបស់ ចក់ ត្រូវអង្គការបញ្ជូនទៅគុកព្រៃសឲ្យទៅគាស់គល់ឈើ និងលើកភ្លឺស្រែ ពីព្រោះឪពុក ចក់ ជាអតីតទាហានលន់នល់ពាក់សក្តិមួយ ។

នៅខែ១ ឆ្នាំ១៩៧៨ ញ៉ិល អាយុ១៥ឆ្នាំ បាននិយាយប្រាប់ ចឹក និង ចក់ ថា ៖ "កន្លែងយើងសព្វថ្ងៃរត់បាត់ច្រើនណាស់ តែរកពុំឃើញទេ" ។ ថ្ងៃមួយនៅក្នុងខែដដែល វេលាម៉ោងបួន ចឹក និង ចក់ បានពិភាក្សាគ្នាថា ៖ "យើងរស់នៅទីនេះមិនបានទេ តែនៅគេវាយស្លាប់ហើយ ដូច្នេះយើងរត់ទៅសុំគេនៅត្រើយខាងត្បូងទើបស្រួល" ។ ចឹក និង ចក់ បានឯកភាពគ្នានៅថ្ងៃនោះថានឹងនាំគ្នារត់ ។ នៅវេលាម៉ោង១១យប់ ចឹក មកស៊ើបមើលផ្លូវឃើញអ្នកយាមឈ្មោះមិត្ត អ៊ួក កំពុងដេកលក់ ។ ឆ្លៀតឱកាសល្អនេះ ចឹក និង ចក់ បានរត់ទៅទិសខាងលិចឆ្ពោះស៊ីងមួយ ។ អ្នកទាំងពីរធ្វើដំណើរទាំងយប់ ដោយអស់កម្លាំងពេកក៏សម្រាកនៅក្រោមដើមស្វាយមួយ ព្រឹកឡើងទើបដឹងថាខ្លួនកំពុងតែស្ថិតនៅក្បែរផ្លូវជាតិលេខ៣៨ ហើយក៏បបួលគ្នាដើរតាមផ្លូវជាតិសំដៅទៅទិសខាងជើង ។ ដើរបានប្រហែលមួយរយម៉ែត្រ អ្នកទាំងពីរត្រូវបានកម្មាភិបាលនៅតំបន់នោះចាប់បាន ហើយបញ្ជូនទៅកង ពូឡូត នៅតាខ្មៅ "ឃុំចលនា" ។ នៅកន្លែងនោះ អ្នកទាំងពីរត្រូវបានចាត់តាំងឲ្យបោកស្រូវជាមួយកងចល័ត ។ ធ្វើការនៅទីនោះ បានកន្លះខែ ចឹក និង ចក់ ត្រូវអង្គការបញ្ជូនមកគុកព្រៃសវិញ ។

ចឹក និង ចក់ ត្រូវបានបញ្ជូនចូលមន្ទីរស-២១ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ ។ នៅក្នុងបញ្ជីរាយនាមអ្នកទោសបញ្ជូនមកមន្ទីរស-២១ មានសរសេរថាអ្នកទាំងពីរ "សេរីច្រើន ការងារស្ពឹកស្រពន់" និងចុះហត្ថលេខាដោយ ហ៊ុយ ។ នៅទំព័រទីពីរនៃចម្លើយសារភាពមានចំណាររបស់អ្នកសួរចម្លើយឈ្មោះ ខៃ ថា អេង ចក់ ត្រូវបានចាប់ខ្លួនពីបទឪពុកធ្វើទាហានពាក់សក្តិមួយ ចំណែកមូលហេតុនៃការចាប់ខ្លួនរបស់ ឈឿន ចឹក មិនត្រូវបានបញ្ជាក់ ។ មិនមានឯកសារណាមួយ បញ្ជាក់ថា ឈឿន ចឹក និង អេង ចក់ ស្លាប់ឬក៏រស់ទេ ។

**ឌី ខាំបូលី**

# ដំណើរទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០៦ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាពលរដ្ឋកម្ពុជានៅគ្រប់ខេត្តក្រុងទូទាំងប្រទេសជាមធ្យមពី៤០០ទៅ៥០០នាក់ជារៀងរាល់ខែ មកចូលរួមដំណើរទស្សនកិច្ចទីតាំងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គោលបំណងនៃដំណើរទស្សនកិច្ចនេះគឺដើម្បីផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាបានយល់ដឹងអំពីដំណើរការរបស់អង្គជំនុំជម្រះ និងលើកទឹកចិត្តឲ្យប្រជាជនចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនេះ ។

ក្នុងដំណើរទស្សនកិច្ចមួយលើកៗ ប្រជាពលរដ្ឋបានទៅទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទួលស្លែងដែលជាអតីតមន្ទីរសន្តិសុខធំបំផុតរបស់ខ្មែរក្រហមឈ្មោះ មន្ទីរស-២១ វាលពិឃាតបឹងជើងឯកជាកន្លែងដែលខ្មែរក្រហមយកអ្នកទោសពីមន្ទីរស-២១មកសម្លាប់ ទស្សនាសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ និងជួបសំណេះសំណាលជាមួយមន្ត្រីតាក់តែងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ក្នុងចំណោមអគារទាំងប្រាំរបស់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង អ្នកចូលរួមចាប់អារម្មណ៍ខ្លាំងទៅលើអគារ "ខ" ដាក់តាំងរូបថតអ្នកទោសរាប់ពាន់សន្លឹក ។ អ្នកចូលរួមម្នាក់ៗសម្លឹងមើលរូបថតនីមួយៗយ៉ាងល្អិតល្អន់ អ្នកខ្លះខំរកមើលរូបថតសាច់ញាតិរបស់ខ្លួនដែលបានបាត់ដំណឹងតាំងពីរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកដែលរកឃើញរូបថតសាច់ញាតិបានស្រែកយំរៀបរាប់អំពីបុគ្គលដែលស្លាប់ ។ អ្នកខ្លះពេលបាន

ឃើញរូបថតអ្នកទោសយ៉ាងច្រើនដូច្នេះក៏លាន់មាត់ថា "កូនគេ កូនខ្ញុំ បាត់មិនឃើញមកផ្ទះវិញសោះមិនដឹងទៅណា ស្រាប់តែឃើញនៅកន្លែងនេះទៅវិញ មិនដឹងជាត្រូវទទួលទារុណកម្មបែបណាទេមុននឹងស្លាប់" ។ នៅក្នុងដំណើរទស្សនកិច្ចលើកទី៣ក្នុងខែមេសានេះ ហាន់ យឹម រស់នៅខេត្តកំពង់ធំ បានឃើញរូបថតរបស់ប្អូនប្រុសរបស់គាត់ដែលបាត់ដំណឹងតាំងពីឆ្នាំ១៩៧៦ ។ គាត់រន្ធត់ចិត្តណាស់ ប៉ុន្តែគាត់ក៏បានធូរស្រាលដែរ ព្រោះបានទទួលដំណឹងអំពីប្អូនប្រុសដែលគាត់ខានឃើញអស់រយៈពេល២៧ឆ្នាំមកហើយ ។

វេលារសៀល នៅទីតាំងវាលពិឃាតបឹងជើងឯក អ្នកចូលរួមបានដើរមើលស្លាកស្នាមរណ្តៅសាកសពរួម និងបានអុជធូបនៅចំពោះមុខស្តូបដែលតម្កល់អដ្ឋិធាតុរបស់ជនរងគ្រោះ ។ ដូនជី និងអ្នកចូលរួមបានសូត្រធម៌បង្សុកូលជូនដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលស្លាប់នៅទីនោះ កុំឲ្យនៅវិលវល់តទៅទៀត ។



នៅក្នុងសាលសវនាការនៃអគារអង្គជំនុំជម្រះវិសាមញ្ញ ដែលមានទីតាំងនៅជាយក្រុងភ្នំពេញ អ្នកចូលរួមបានចោទសួរសំណួរជាច្រើនដល់ប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ អំពីដំណើរការរបស់អង្គជំនុំជម្រះនេះ ។ សំណួរដែលយើងតែងតែឮនៅរៀងរាល់ដំណើរទស្សនកិច្ចគឺ "ហេតុអ្វីក៏មិនកាត់ទោសខ្មែរក្រហមឲ្យបានឆាប់ៗ តើពន្យារពេលយូរម្ល៉េះ?" ។ ដូនជីម្នាក់បានទទូចឲ្យអង្គជំនុំជម្រះវិសាមញ្ញបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យបានឆាប់ ដើម្បីគាត់មានឱកាសបានតាមដាននិងចូលរួមក្នុងដំណើរការនេះផង ។

ប្រជាជនដែលបានមកចូលរួមមានការពេញចិត្តនិងដំណើរទស្សនកិច្ចនេះណាស់ ដោយសារតែគាត់បានទទួលចំណេះដឹងអំពីដំណើរការស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា និងបានរៀនសូត្របន្ថែមអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា ។ អ្នកមីង ហាន់ យឹម បានថ្លែងអំណរគុណចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានអញ្ជើញគាត់មកចូលរួមដំណើរទស្សនកិច្ចនេះ ដែលនាំឲ្យគាត់បានឃើញរូបថតប្អូនប្រុសរបស់គាត់ ។

តួលេខប្រជាជនដែលមកចូលរួមក្នុងទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ÷

◆ **លើកទី១** ខែកុម្ភៈ ឆ្នាំ២០០៦ មានអ្នកចូលរួមចំនួន ៤៨០នាក់ មកពីខេត្តកំពង់ចាម កំពង់ឆ្នាំង កំពត កំពង់ធំ ក្រចេះ កណ្តាល ព្រៃវែង កំពង់សោម ស្វាយរៀង ព្រះវិហារ កោះកុង សៀមរាប ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ កំពង់ស្ពឺ និងតាកែវ ។

◆ **លើកទី២** ខែមីនា ឆ្នាំ២០០៦ មានអ្នកចូលរួមចំនួន៨២៤នាក់ មកពីខេត្តបាត់ដំបង តាកែវ កំពត ព្រៃវែង សៀមរាប កំពង់ឆ្នាំង កណ្តាល ក្រចេះ កំពង់ធំ កំពង់ចាម មណ្ឌលគិរី រតនគិរី ស្វាយរៀង ពោធិសាត់ កំពង់ស្ពឺ ព្រះវិហារ ក្រុងព្រះសីហនុ និងរាជធានីភ្នំពេញ ។

◆ **លើកទី៣** ខែមេសា ឆ្នាំ២០០៦ មានអ្នកចូលរួមចំនួន ៥៥១ នាក់ ក្នុងនោះ ÷ ◆ ខេត្តកំពង់ចាម ១៦២នាក់ ◆ ខេត្តកំពង់ស្ពឺ ៧៣នាក់ ◆ ខេត្តកោះកុង ១៦នាក់ ◆ ខេត្តសៀមរាប ២នាក់ ◆ ខេត្តបាត់ដំបង ៤នាក់ ◆ ខេត្តកំពង់ធំ ២៦នាក់ ◆ ខេត្តតាកែវ ៣៥នាក់ ◆ ខេត្តព្រះវិហា ៥នាក់ ◆ ខេត្តពោធិសាត់ ៣នាក់ ◆ ខេត្តព្រៃវែង ៧០នាក់ ◆ ក្រុងព្រះសីហនុ ៥នាក់ ◆ ខេត្តស្វាយរៀង ៨៤នាក់ ◆ ខេត្តកណ្តាល ២៦នាក់ ◆ ខេត្តកំពត ៤៧នាក់ ◆ ខេត្តកំពង់ឆ្នាំង ៧នាក់ ◆ ភ្នំពេញ ៧នាក់ ◆ និស្សិត១៩នាក់ ។

**ញាណ សុជាតិ**

# សាក្សី ជនដៃដល់ និង ជនរងគ្រោះ

នៅក្នុងអត្ថបទកាសែតមួយដែលសរសេរនៅបន្ទាត់ខាងលើថា "ជនដៃដល់នៅកម្ពុជារស់នៅយ៉ាងស្ងៀមស្ងាត់ក្នុងសភាពថោកទាប" អ្នកកាសែតអាមេរិកដ៏ល្បីល្បាញម្នាក់បានរៀបរាប់អំពី តាខន ដែលរស់នៅដោយគ្មានទោសកំហុសជាមួយអ្នកស្រុកអ្នកភូមិដែលគាត់ធ្លាប់ធ្វើបាបកាលពីនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។

អត្ថបទកាសែតនេះបានរៀបរាប់ថា តាខន ធ្លាប់បានសម្លាប់ប្រជាជនអស់ជាច្រើននាក់នៅក្នុងគុកដែលស្ថិតនៅក្រោមបញ្ជារបស់គាត់និងនៅជុំវិញគុកនេះ ។ អ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យបានប្រាប់ឲ្យដឹងថា ជនរងគ្រោះមួយចំនួនត្រូវតាខន ចាប់ចងព្យួរជើងឡើងលើ ហើយវះពោះទម្លាក់ពោះវៀនសំយុងចុះគ្របលើមុខជនរងគ្រោះ បន្ទាប់មកជនរងគ្រោះនោះបាត់បង់ជីវិត ។ តាខន បានស៊ីថ្លើមនិងលេបប្រមាត់របស់ជនរងគ្រោះ ពីព្រោះគាត់មានជំនឿថាការស៊ីថ្លើមនិងលេបប្រមាត់មនុស្សអាចផ្តល់កម្លាំងមាំមួនដល់គាត់ ។

ពិតជាលំបាកក្នុងការរៀបរាប់អំពីភាពសាហាវព្រៃផ្សៃទាំងនេះ ។ ខ្ញុំព្យាយាមស្វែងយល់អំពីសភាពគួរឲ្យរន្ធត់នេះចាប់តាំងពីដើមឆ្នាំ១៩៩៣មកម្ល៉េះ ម្យ៉ាងទៀតនៅពេលនោះខ្ញុំនៅជានិស្សិតផ្នែកនរវិទ្យា និងបានសិក្សាស្រាវជ្រាវអំពីរបបប្រល័យពូជសាសន៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ខ្ញុំនៅតែចង់ដឹងចង់ឮថា ហេតុអ្វីបានជាមានអំពើប្រល័យពូជសាសន៍កើតឡើង? តើអ្វីទៅដែលជំរុញឲ្យជនដៃដល់ហ៊ានសម្លាប់មនុស្ស? តើមនុស្សដូច តាខន អាចសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃបានយ៉ាងដូចម្តេចទៅ?

ដើម្បីស្វែងរកចម្លើយនៃសំណួរខាងលើនេះ ខ្ញុំបានមករស់នៅក្នុងប្រទេសកម្ពុជារយៈពេលមួយឆ្នាំគឺចាប់ពីឆ្នាំ១៩៩៤ដល់ឆ្នាំ១៩៩៥ ។ នៅរដូវក្តៅឆ្នាំ២០០០ ខ្ញុំត្រឡប់មកប្រទេសកម្ពុជាម្តងទៀត ដើម្បីស្រាវជ្រាវបន្ថែមទៅលើអ្វីដែលខ្ញុំបានធ្វើកាលពីពេលមុន ដើម្បីបោះពុម្ពជាសៀវភៅ ។ ពេលនោះហើយដែលខ្ញុំសម្រេចចិត្តស្វែងរក តាខន ដើម្បីសួរគាត់ថា តើហេតុអ្វីបានជាគាត់សម្លាប់មនុស្ស?

**សាក្សី**

នៅចុងបញ្ចប់នៃដំណើរស្រាវជ្រាវរបស់ខ្ញុំនៅក្នុងប្រទេសកម្ពុជា ខ្ញុំរកបានអ្នកកាសែតកម្ពុជាម្នាក់ឲ្យជួយខ្ញុំស្រាវជ្រាវអត្ថបទដែលខ្ញុំអានអំពី តាខន ។ ខ្ញុំហៅអ្នកកាសែតម្នាក់នោះថា "មីង" ។ មីងនិយាយភាសាខ្មែរផងអង់គ្លេសផងប្រាប់ខ្ញុំតាមទូរស័ព្ទថា ការពិតគាត់មិនធ្លាប់សម្ភាសន៍ជាមួយ តាខន ទេ ។

មីងបានពន្យល់ទៀតថា "ខ្ញុំគ្រាន់តែបានជួបនិយាយជាមួយប្រជាជនដែលរស់នៅក្បែរគុកនៅក្នុងអំឡុងពេលនោះប៉ុណ្ណោះ ក៏ប៉ុន្តែខ្ញុំស្គាល់ទីកន្លែងដែល តាខន រស់នៅ ។ យើងអាចបើកឡានទៅផ្ទះរបស់ តាខន និងជួបនិយាយជាមួយគាត់ដោយផ្ទាល់បាន ។ តាខន រស់នៅភាគខាងត្បូងនៃរាជធានីភ្នំពេញ យើងត្រូវចំណាយពេលប្រហែលពីរម៉ោងទើបទៅដល់ផ្ទះគាត់ ។ ខ្ញុំអាចយកឡានរបស់ខ្ញុំទៅបាន ។ បើលោកចង់ទៅ យើងទៅព្រឹកស្អែកនេះតែម្តង" ។

នៅក្នុងប្រទេសកម្ពុជា ការងារគ្រប់យ៉ាងគឺចាប់ផ្តើមពីព្រលឹម ។ មុនថ្ងៃរះ កសិករភ្ញាក់ពីដំណេកនិងបំពេញការងារស្រែចម្ការរបស់ខ្លួនមុនពេលដែលព្រះអាទិត្យជះកម្តៅពេលថ្ងៃត្រង់ ។ ធ្វើកិច្ចការនៅស្រែរួចរាល់ហើយកសិករត្រឡប់មកបរិភោគអាហារនិងសម្រាកនៅផ្ទះនៅម៉ោង១១ថ្ងៃត្រង់ ។

មីងបើកឡានមកទទួលខ្ញុំពីព្រលឹមស្រាងៗ ។ មីងស្លៀកសម្លៀកបំពាក់បែបអឺរ៉ុប គឺអាវពណ៌ខៀវបើកកនិងខោជើងវែងពណ៌កាគី និងចងសក់កន្ទុយសេះ ។ មីងមានអាយុប្រហែលជាង ៣០ឆ្នាំ ទាប ធាត់ និងមានកែវភ្នែកល្អ ។ នៅពេលដែលខ្ញុំចូលទៅអង្គុយក្នុងរថយន្តតូយូតារបស់គាត់ ខ្ញុំឃើញកណ្តឹងមួយតូចព្យួរនៅនឹងកញ្ចក់សម្រាប់មើលក្រោយ ។ កណ្តឹងនេះបញ្ចេញស្នូរនៅពេលដែលឡានធ្លាក់ជង្ហុកម្តងៗ ។

មីងអើតទៅបាំងខាងក្រោយ ហើយនិយាយដោយញញឹម

ថា "លោកឃើញទេ ខ្ញុំយកកាមេរ៉ារបស់ខ្ញុំមកដែរ ។ សម្រាប់ករណីចាំបាច់ប៉ុណ្ណោះ" ។

ខ្ញុំគិតក្នុងចិត្តថា "ករណីចាំបាច់ ។ ករណីចាំបាច់អ្វីទៅ?"

ពេលនោះគឺចំរដូវវស្សា ប៉ុន្តែយើងធ្វើដំណើរក្រោមផ្ទៃមេឃស្រឡះដែលមានពពកតែបន្តិចបន្តួច ។ មីងបើករថយន្តរបស់គាត់យឺតៗប្រជ្រៀតនឹងរថយន្តដឹកទំនិញ រថយន្តតូចៗ ម៉ូតូ កង់ ស៊ីក្លូ និងអ្នកថ្មើរជើងដែលកកកុញពេញផ្លូវនៅក្នុងទីក្រុង ។ នៅពេលមីងជាន់ហ្វ្រាំងម្តងៗ កណ្តឹងទាំងពីរទង្គិចគ្នាបញ្ចេញសូរក្រឹងៗតិចៗ ។

បើទោះបីជាមានការបំពុលដោយផ្សែងរថយន្តនិងម៉ូតូ បំណែកក្រដាស និងគំនរសំរាមនៅលើចិញ្ចើមផ្លូវក៏ដោយ ទីក្រុងភ្នំពេញនៅតែជាទីក្រុងដ៏ស្រស់ស្អាតដែលចម្រុះទៅដោយស្ថាបត្យកម្មតាមម៉ូដបារាំង ដើមត្នោត ផ្ទះវីឡាមានញកជាថ្នាក់ៗ ផ្សារលក់ដូរជាប់ក្បិនបន្លែនិងផ្លែឈើច្រើនមុខ ព្រមទាំងវត្តអារាមធំៗជាច្រើនទៀត ។ មិនគួរឲ្យជឿទេថាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យប្រជាជនទាំងអស់នៅទីក្រុងភ្នំពេញត្រូវខ្មែរក្រហមជម្លៀសចេញ ។ កម្មាភិបាល កងទ័ពខ្មែរក្រហម និងកម្មករ ចំនួនពីរម៉ឺននាក់បានចូលមករស់នៅក្នុងទីក្រុងជំនួសប្រជាជនដែលកើនដល់ប្រហែលពីលាននាក់ក្នុងអំឡុងសង្គ្រាមស៊ីវិល ។ នៅជនបទ ប្រជាជនដែលជម្លៀសពីទីក្រុងត្រូវបានឲ្យឈ្មោះថា "ប្រជាជនថ្មី" និងត្រូវធ្វើបាបធ្ងន់ធ្ងរជាង"ប្រជាជនចាស់" ដែលជាប្រជាជនរស់នៅភូមិភាគនានា ដែលគ្រប់គ្រងដោយខ្មែរក្រហមមុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។

ខណៈពេលយើងបើកជិតដល់ជាយក្រុងភ្នំពេញ មីងបានបត់ឡើងទៅផ្លូវធំនាំយើងឆ្ពោះទៅភាគត្បូងដែលជាមូលដ្ឋានសំខាន់ៗរបស់ខ្មែរក្រហមនៅក្នុងអំឡុងសង្គ្រាមស៊ីវិល ។ ខ្ញុំចាប់ផ្តើមសួរមីងអំពី តាខន ខណៈពេលដែលចរាចរណ៍មានសភាពស្ងប់ស្ងាត់និងមានវាលស្រែអមសងខាងផ្លូវ ។

ខ្ញុំសួរមីងថា "តើ តាខន រស់នៅឯណា? ធ្វើម៉េចយើងរកគាត់ឃើញ?"

"នៅក្នុងភូមិក្បែរភ្នំនេះឯង ។ តាខន មានញាតិសន្តានច្រើនណាស់នៅទីនោះ" ។ មីង បន្ថែមទៀតថា តាខន បានផ្តាច់ខ្លួនចេញពីខ្មែរក្រហមជាមួយ តាម៉ុក ដែលប្រជាជនកម្ពុជាស្គាល់ថាជាឃាតករដ៏សាហាវ ដោយសារតែភាពគ្មានមេត្តារបស់គាត់នៅក្នុងអំឡុងនិងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។

ខ្ញុំចាប់ផ្តើមមានអារម្មណ៍ខ្លាច ព្រោះថាយើងនឹងជួបទាហានខ្មែរក្រហមដែលទើបនឹងផ្តាច់ខ្លួនម្នាក់ដែលបានសម្លាប់ប្រជាជនកាលពីសាមសិបឆ្នាំមុន ។ តាខន រស់នៅភូមិដាច់ស្រយាលមួយដែលពិបាកទាក់ទងជាមួយ ។ ប្រទេសកម្ពុជាអាចជាប្រទេសមួយគួរឲ្យភ័យខ្លាច ជាពិសេសនៅពេលនរណាម្នាក់ធ្វើដំណើរមកកន្លែងដាច់ស្រយាលដើម្បីសាកសួររឿងរ៉ាវអតីតកាលដែលមនុស្សជាច្រើនចង់បំភ្លេចចោល ។ កាំភ្លើងមានគ្រប់ទីកន្លែង ការចាប់ជម្រិតកើតមានជាញឹកញាប់ ការរំលោភបំពានកើតមានជាធម្មតា ។ ខ្ញុំគិតអំពីការត្រឡប់ក្រោយវិញ ។

មីង និយាយថា "ខ្ញុំមានមិត្តភក្តិម្នាក់ឈ្មោះ មុំ រស់នៅតំបន់នោះដែរ ។ មុំ ស្គាល់កន្លែង តាខន រស់នៅ" ។ ពាក្យមួយឃ្លានេះធ្វើឲ្យខ្ញុំអន់ខ្លាច ។ មីង និយាយទៀតថា "ខ្ញុំនឹងនិយាយរឿងរបស់ខ្ញុំប្រាប់លោក យល់ព្រមទេ?" នៅក្នុងប្រទេសកម្ពុជា ជារឿយៗប្រជាជនចាប់ផ្តើមនិយាយឡើងអំពីអ្វីដែលខ្លួនបានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បើទោះបីជាខ្ញុំបានសម្ភាសមនុស្សជាច្រើនអំពីរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ខ្ញុំមិនដែលត្រៀមខ្លួនស្តាប់រឿងទាំងនោះដែរ ។ មីងចាប់ផ្តើមនិយាយញាប់ៗនិងរដាក់រដុបពេលដែលរំឭកដល់ដំណើរទៅកាន់ផ្ទះរបស់តាខន ជាលើកដំបូង ។

ពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ មីង ទើបតែមានអាយុ៨ឆ្នាំប៉ុណ្ណោះ ។ គ្រួសាររបស់មីងមានទ្រព្យសម្បត្តិច្រើនណាស់ ហើយមានប្រវត្តិរូបមិនល្អដែលខ្មែរក្រហមចង់ដកចេញពីសង្គមបដិវត្តន៍របស់ខ្លួន ។ ឪពុករបស់គាត់ដែលជាវិស្វករម្នាក់នៅក្នុងរដ្ឋាភិបាលត្រូវខ្មែរក្រហមចាប់ញាត់ចូលទៅក្នុងរថយន្តហ្ស៊ីបដឹកយកទៅបាត់ ។ មីងនិយាយប្រាប់ខ្ញុំដោយសំឡេងញ័រថា "ខ្ញុំមិនដឹងថាតើខ្មែរក្រហមធ្វើអ្វីខ្លះមកលើឪពុករបស់ខ្ញុំទេ ។ ឪពុកខ្ញុំមានក្បាលពោះធំ ដូច្នេះខ្មែរក្រហមគិតថាគាត់មានបុណ្យស័ក្តិធំ" ។

ដូចនឹងប្រជាជនជម្លៀសដទៃទៀតដែរ ក្រុមគ្រួសាររបស់

មីងត្រូវកងទ័ពខ្មែរក្រហមបញ្ជាឲ្យចាកចេញពីទីក្រុងភ្នំពេញ ព្រោះ "អង្គការ"ត្រូវការបោសសម្អាតទីក្រុង ។ ជួនកាលពាក្យ"អង្គការ" សំដៅទៅលើកម្មាភិបាលថ្នាក់ខ្ពស់ ជួនកាលទៀតពាក្យនេះសំដៅដល់ស្ថាប័នកាន់អំណាចមួយដែលប្រជាជនត្រូវតែស្មោះត្រង់និងគោរពដោយគ្មានលក្ខខណ្ឌ ។ "អង្គការ"មានអំណាចក្នុងការសម្រេចឲ្យអ្នកណារស់និងអ្នកណាស្លាប់ ។ ជនដែលមានប្រវត្តិរូបគួរឲ្យសង្ស័យ ឬជន ដែលក្បត់នឹងរបបថ្មី ត្រូវបញ្ជូនមកឲ្យ"អង្គការ" ហើយភាគច្រើននៃអ្នកទាំងនោះមិនបានវិលត្រឡប់មកវិញឡើយ ។

ម្តាយរបស់ មីង បានប្រាប់កូនៗឲ្យប្រមែប្រមូលសម្លៀកបំពាក់និងម្ហូបអាហារត្រៀមសម្រាប់រយៈពេលពីរបីថ្ងៃ ។ បន្ទាប់មកគ្រួសាររបស់មីងធ្វើដំណើរជាមួយមនុស្សរាប់ម៉ឺននាក់ដែលកកកុញនៅតាមផ្លូវចេញពីទីក្រុងភ្នំពេញក្រោមសីតុណ្ហភាពជិតមួយរយអង្សារ ។ សាកសពទាហានលន់នល់និងជនស៊ីវិលដែលបានស្លាប់ដោយសារស្រេកទឹកនិងដោយកម្តៅថ្ងៃ និងសាកសពដែលស្លាប់ដោយការកាប់សម្លាប់របស់ខ្មែរក្រហមស្ថិតនៅរដូករណែលតាមផ្លូវ ។ មិនយូរប៉ុន្មាន ប្រជាជនជម្លៀសបានដឹងថាខ្មែរក្រហមនឹងមិនអនុញ្ញាតឲ្យខ្លួនវិលត្រឡប់មកទីក្រុងវិញឡើយ ។ ក្រុមគ្រួសាររបស់មីងធ្វើដំណើរទៅទិសខាងត្បូងទៅស្រុកកំណើតរបស់ឪពុកគាត់ដែលនៅក្នុងខេត្តតាកែវ គឺភូមិរបស់ តាខន ។...

រថយន្តរបស់យើងបានចេញផុតពីទីក្រុងភ្នំពេញហើយបើកតាមផ្លូវជាតិដែលមានទំហំល្មមសម្រាប់រថយន្តពីរចៀសគ្នានិងមានជង្ហុកធំៗ ។ យើងឃើញកសិករកំពុងតែដកស្ទូងនៅក្នុងស្រែដែលមានពណ៌បៃតងស្រងាត់ ។ នៅពេលដែលរថយន្តធ្លាក់ជង្ហុកម្តងៗ កណ្តឹងទាំងពីរប៉ះគ្នាបន្លឺស្នូរក្រឹងៗ ។ មីងរៀបរាប់រឿងរ៉ាវរបស់គាត់បន្តទៀត ។

...គ្រួសាររបស់មីងមិនបានទៅដល់ស្រុកកំណើតរបស់ឪពុកមីងឡើយ ព្រោះខ្មែរក្រហមបញ្ជាឲ្យគ្រួសារមីងទៅរស់នៅក្នុងភូមិមួយដែលស្ថិតនៅក្បែរសាលាឃុំដែល តាខន ធ្វើការជាប្រធានឈ្លបតំបន់ ។ គ្រួសាររបស់មីងត្រូវអង្គការសង្ស័យដោយសារតែប្រវត្តិរូបមិនស្អាតស្អំ ហើយម្តាយរបស់មីងឈ្មោះ សុផា មិនចេះធ្វើការងារ ។

"ម្តាយរបស់ខ្ញុំមិនចេះអ្វីទាំងអស់ ។ គាត់មិនចេះដកស្ទូងសូម្បីតែដាំបាយធ្វើម្ហូបក៏គាត់ពុំចេះដែរ ។ ប្អូនស្រីខ្ញុំនិងខ្ញុំរៀនតាម"ប្រជាជនចាស់"បានយ៉ាងឆាប់រហ័ស ចំណែកម្តាយរបស់ខ្ញុំមានបញ្ហាច្រើន ។ ពេលមួយ ខ្មែរក្រហមនាំម្តាយនិងអ៊ំស្រីរបស់ខ្ញុំទៅធ្វើស្រែដើម្បីពិសោធន៍ថាតើគាត់ចេះធ្វើស្រែដែរឬទេ ។ មនុស្សមួយក្រុមឈរមើលគាត់ច្រូត រួមមាន តាខន គណៈភូមិ និងកងឈ្លប ។ ម្តាយខ្ញុំមិនចេះច្រូត ។ តាខន គណៈភូមិ និងកងឈ្លបនិយាយគ្នាថា "មិត្តនេះ (ម្តាយរបស់មីង) មិនចេះធ្វើស្រែទេ" ។ តាំងពីពេលនោះមក តាខន គណៈភូមិ និងកងឈ្លប តាមដានយើងយ៉ាងប្រុងប្រយ័ត្ន" ។...

ក្រោយមកទៀត បងប្រុសរបស់មីងមានជំងឺរាកយ៉ាងធ្ងន់ធ្ងរ ។ មីងអួលដើមកហាក់ដូចជាមានអ្វីមកខ្ទប់មាត់របស់គាត់នៅពេលដែលគាត់នឹកឃើញបងប្រុសរបស់គាត់ដែលស្លាប់ដោយជំងឺ ។ "យើងស្រលាញ់គាត់ខ្លាំងណាស់ គាត់ជាកូនប្រុសតែមួយគត់ក្នុងគ្រួសាររបស់ខ្ញុំ ។ ចាប់ពីតាំងពេលនោះមក ក្នុងគ្រួសាររបស់ខ្ញុំមានតែសមាជិកជាស្ត្រីប៉ុណ្ណោះ" ។ តាមការពិត គ្រួសាររបស់មីងក៏បានជួបសំណាងល្អខ្លះដែរ ។ កាលពីមុនរបបកម្ពុជាប្រជាធិបតេយ្យ ជីតារបស់មីងធ្លាប់បានជួយកសិករម្នាក់ឈ្មោះ ជុំ ដោយបានផ្តល់ស៊ីក្លូមួយគ្រឿងនិងផ្តល់កន្លែងស្នាក់នៅដល់គាត់ដើម្បីឲ្យគាត់រកលុយចិញ្ចឹមជីវិតនៅទីក្រុងភ្នំពេញ ។ ជាសំណាងល្អដែលអ៊ំ ជុំ រស់នៅភូមិជាមួយក្រុមគ្រួសាររបស់មីង និងនៅចងចាំអំពើល្អរបស់ជីតារបស់មីង ។ មីងនិយាយថា "យើងមិនស្គាល់គាត់ទេ ប៉ុន្តែគាត់នៅចំណាំយើង ។ គាត់ទូន្មានយើងឲ្យប្រយ័ត្នខ្លួនមិនត្រូវនិយាយគ្នានៅពេលយប់ និងមិនត្រូវនិយាយអ្វីដែលផ្ទុយពីសង្គមថ្មីនេះឡើយ ។ យើងក៏ធ្វើតាមពាក្យទូន្មានរបស់គាត់" ។

មិនយូរប៉ុន្មាន កម្មាភិបាលឃុំម្នាក់មកស្រាវជ្រាវប្រវត្តិរូបគ្រួសាររបស់មីង ។ ខ្មែរក្រហមស៊ើបសួរប្រវត្តិរូបប្រជាជនយ៉ាងល្អិតល្អន់ ។ ម្តាយរបស់មីងឈ្មោះ សុផា បានប្រាប់ខ្មែរក្រហមតាមត្រង់ ។ មីងបានពន្យល់ថា "ម្តាយខ្ញុំជាមនុស្សស្មោះត្រង់ណាស់ គាត់និយាយប្រាប់អង្គការថាយើងជាអ្នកចេះដឹងនិងចេះភាសាបារាំងថែមទៀត" ។

មីងនិងប្អូនស្រីរបស់គាត់ត្រូវបញ្ជូនឲ្យទៅរៀនសូត្រនៅ

សាលាអប់រំនយោបាយសម្រាប់កុមារ ។ “ខ្មែរក្រហមប្រាប់យើងថា ឪពុកម្តាយរបស់យើងមិនមែនជាអ្នកចិញ្ចឹមយើងទេ គឺអង្គការជាអ្នកផ្តល់អាហារឲ្យយើង ។ ខ្មែរក្រហមបានប្រាប់យើងឲ្យទៅយកការណ៍ពីឪពុកម្តាយរបស់យើង និងរាយការណ៍ជូនអង្គការអំពីអ្វីដែលគាត់កំពុងតែធ្វើ ។ ប្រសិនបើគាត់លួចអាហារយើងត្រូវរាយការណ៍ជូនគណៈភូមិឬអង្គការ ។ អង្គការមានភ្នែកច្រើនដូចម្នាស់ ។ អ្នកណាធ្វើអ្វីក៏អង្គការដឹងដែរ” ។

ថ្ងៃមួយ គ្រូបង្រៀនខ្មែរក្រហមម្នាក់ឈ្មោះ ហន បានហៅមីងនិងប្អូនស្រីរបស់គាត់ទៅសួរ ។ មីងរំឭកថា “គាត់សួរយើងថា “ឯងចេះនិយាយភាសាបារាំងទេ?” ខ្ញុំឆ្លើយថា ខ្ញុំមិនយល់អ្វីដែលមិត្តនិយាយទេ ។ ខ្ញុំមិនចេះអ្វីទាំងអស់ សូម្បីតែអក្សរមួយតួក៏ខ្ញុំមិនចេះដែរ ។ គ្រូសួរទៀតថា ហេតុអ្វីបានជាម្តាយឯងនិយាយថាឯងចេះភាសាបារាំង? ខ្ញុំឆ្លើយថា កុំជឿម្តាយរបស់ខ្ញុំ គាត់គ្រាន់តែចង់អួតប៉ុណ្ណោះ ។ ខ្មែរក្រហមពិសោធន៍យើងដោយឲ្យយើងអានសៀវភៅ ប៉ុន្តែយើងធ្វើពុតជាល្ងង់” ។

មីងបានរាប់អានជាមួយនឹងក្មេងស្រីម្នាក់ឈ្មោះ កាស៊ីន ជាកូនស្រីរបស់ប្រធានភូមិនិងជាក្មួយស្រីរបស់កម្មាភិបាលស្រុក ។ មីងនិយាយថា “ខ្ញុំបានឃើញពីអត្ថប្រយោជន៍នៃការរាប់អានគ្នាជាមួយ កាស៊ីន ។ ក្រោយពីយើងបានក្លាយជាមិត្តនឹងគ្នា ខ្ញុំអាចទៅលេងផ្ទះវានិងញ៉ាំបាយជាមួយក្រុមគ្រួសារវាបាន ហើយខ្ញុំពុំចាំបាច់ធ្វើការងារលំបាកៗទៀតទេ ។ យើងទៅកន្លែងណាក៏បានដែរ ។ យើងបានទៅគុករបស់ តាខន និងជួបនិយាយជាមួយអ្នកទោសបានមួយភ្លែតៗ ។ ឆ្មាំគុកមើលយើងពីចម្ងាយ ក៏ប៉ុន្តែអនុញ្ញាតឲ្យយើងនិយាយជាមួយអ្នកទោស ព្រោះយើងជាកុមារ ហើយ កាស៊ីន ជាកូនកម្មាភិបាល ។ អ្នកទោសទាំងនោះធ្វើការគ្មានទំនេររហូតដល់ថ្ងៃដែលអង្គការយកទៅសម្លាប់ចោល” ។

ការរាប់អានរវាងមីងនិង កាស៊ីន ប្រហែលជាអាចជួយសង្គ្រោះជីវិតរបស់ សុផា ។ ថ្ងៃមួយ បុរសចំណាស់ម្នាក់ដែលស្អប់ សុផា បានចោទប្រកាន់គាត់ថាលួចប្តូរសំណាញ់ ។ នៅពេលថ្ងៃត្រង់ ឈ្លបបានចាប់ខ្លួន សុផា ។ មីង រៀបរាប់ថា “ខ្ញុំយំហើយយំទៀត ព្រោះខ្ញុំដឹងថាអ្នកដែលត្រូវខ្មែរក្រហមយកទៅពិតជាត្រូវសម្លាប់ ។ ខ្ញុំស្រែកទ្រហោយំខ្លាំងៗទាល់តែឮដល់អ្នកភូមិ ។ ខ្ញុំដឹងច្បាស់ថាខ្ញុំនឹងបាត់បង់ម្តាយ ។ ចាប់ពីពេលនេះ ទៅខ្ញុំលែងមានឪពុកម្តាយទៀតហើយ” ។ រៀបរាប់ដល់ត្រង់នេះមីងយំ ។ “ឆ្នាំក្រោយមក ម្តាយរបស់ខ្ញុំប្រាប់ខ្ញុំថា កូនចៅរបស់ តាខន ធ្វើទារុណកម្មគាត់ នាំគាត់ចូលទៅក្នុងព្រៃឲ្យគាត់មើលរណ្តៅដែលនឹងកប់សាកសពរបស់គាត់ ចង្អុលបង្ហាញឧបករណ៍សម្រាប់សម្លាប់គាត់ និងឲ្យគាត់រៀបរាប់ឈ្មោះឧបករណ៍ទាំងនោះម្តងមួយៗ” ។ មីងឈប់មួយភ្លែតហើយបន្តទៀត “ប៉ុន្តែឈ្លបបានដោះលែងគាត់ឲ្យវិលមកផ្ទះវិញ ។ គាត់មកដល់ផ្ទះពេលជិតកណ្តាលអធ្រាត្រ ។ យប់នោះជាយប់ដ៏អស្ចារ្យមួយ ពីព្រោះតាមធម្មតាអ្នកដែលទៅហើយមិនដែលបានត្រឡប់មកវិញទេ” ។ មីងបន្តទាំងខ្សឹកខ្សួលថា “ចិត្តយើងសប្បាយខ្លាំងណាស់ ។ ខ្ញុំមិនដឹងថាមូលហេតុអ្វីបានជាឈ្លបដោះលែងម្តាយខ្ញុំ ។ ប្រហែលជា កាស៊ីន និយាយប្រាប់ឪពុកវាឲ្យដោះលែងម្តាយខ្ញុំក៏មិនដឹង ។ ខ្ញុំយំព្រោះខ្ញុំនៅក្មេងហើយស្ទើរតែបាត់បង់ម្តាយជាទីស្រលាញ់របស់ខ្ញុំ” ។

មីង និយាយប្រាប់ខ្ញុំរឿងមួយទៀត ។ នៅក្នុងឆ្នាំ១៩៧៧ ពេលដែលមីងមានអាយុ១០ឆ្នាំ គាត់បានចូលកងចល័តជាមួយបងស្រីរបស់គាត់ ហើយត្រូវខ្មែរក្រហមបញ្ជូនទៅច្រូតស្រូវនៅក្បែរវត្ត ។ “យើងដើរកាត់តាមគុករបស់ តាខន ។ ខ្ញុំបានឮសំឡេងមនុស្សយំ ។ ខ្ញុំបបួលមិត្តម្នាក់ទៅលបមើលជាមួយគ្នា ដើម្បីឲ្យដឹងថាតើមានរឿងអ្វីកើតឡើង ។ នេះប្រហែលជាមូលហេតុមួយដែលធ្វើឲ្យខ្ញុំក្លាយជាអ្នកកាសែតសព្វថ្ងៃនេះ” ។

មីង និងមិត្តរបស់គាត់បានវារឡើងជណ្តើរវត្ត ។ បង្អួចឈើភាគច្រើនបិទជិត ប៉ុន្តែមានបង្អួចមួយចំហបន្តិច ។ តាមបង្អួចនេះ មីងនិងមិត្តរបស់គាត់បានឃើញរឿងគួរភ័យខ្លាច ។ មនុស្សរបស់ តាខន ជាច្រើននាក់ឈរក្បែរអ្នកទោសម្នាក់ដែលត្រូវចងជើងចងមុខនិងដេកស្តូកនៅលើដី ។ ឆ្មាំគុកម្នាក់យកកាំបិតវះពោះអ្នកទោសនោះ ។ គាត់ស្រែកយ៉ាងខ្លាំង ។ ឈាមបាញ់ចេញមកក្រៅ ហើយហូរហៀរប្រឡាក់គ្រប់ទីកន្លែង ។ អ្នកទោសនោះមិនទាន់ស្លាប់នៅឡើយទេ ខ្លួនរបស់គាត់ញ័រទទ្រើក ។ បន្ទាប់មកឆ្មាំគុកបារពោះវៀនរបស់អ្នកទោស ។ “ពិតជាគួរខ្លាចណាស់ ខ្ញុំញ័ររន្ធត់ ។ រំពេចនោះឆ្មាំគុកពីរបីនាក់ឃើញយើងពីចម្ងាយ យើងក៏រត់គេចទៅចូលជាមួយកុមារដទៃទៀត ។ ជូនកាលខ្ញុំយល់

សប្តិឃើញ រឿងរ៉ាវគួរឲ្យរន្ធត់នេះនៅនឹងភ្នែករបស់ខ្ញុំ ។ ដូច្នេះហើយ ទើបខ្ញុំដឹងថា តាខន ជាមនុស្សអាក្រក់" ។

ខ្ញុំសួរថា "ហេតុបានជាឆ្មាំគុកបាររពោះវៀនអ្នកទោស?"

មីងនិយាយថា "ពីព្រោះឆ្មាំគុកចង់យកថ្លើមឬប្រមាត់របស់អ្នកទោស ។ ក្នុងអំឡុងពេលនោះ ខ្មែរក្រហមស៊ីថ្លើមមនុស្សពីព្រោះខ្មែរក្រហមគិតថាថ្លើមធ្វើឲ្យខ្លួនមានកម្លាំងខ្លាំង ។ ខ្មែរក្រហមប្រើប្រាស់ប្រមាត់មនុស្សធ្វើជាថ្នាំ" ។ នៅក្នុងប្រទេសកម្ពុជា ថ្លើមត្រូវបានចាត់ទុកថាជាកន្លែងផ្ទុកនូវភាពក្លាហាន ។ ការបរិភោគថ្លើមធ្វើឲ្យភ្នែកឡើងពណ៌ក្រហម ។ មីងបន្ថែមទៀតថា "អ្នកភូមិគ្រប់គ្នានិយាយថា តាខន ស៊ីថ្លើមមនុស្សពីព្រោះភ្នែកគាត់ក្រហមជានិច្ច" ។

ពេលដែលមីងបញ្ចប់រឿងនេះ គាត់បើកទ្វារអែបចិញ្ចើមផ្លូវដើម្បីទទួល មុំ ។ បន្ទាប់ពីបានស្តាប់រឿងដែលមីងនិយាយ ខ្ញុំស្ទើរតែភ្លេចទៅហើយថាយើងនឹងធ្វើសម្ភាសន៍ឃាតករខ្មែរក្រហមល្បីល្បាញម្នាក់ ។

មុំ មានសក់សេះនិងបបូរមាត់ធ្លាក់បន្តិច ពាក់អាវពណ៌ទឹកក្រូចនិងក្រហម ។

មុំ នាំយើងទៅតាមផ្លូវធំល្មមមួយដែលមានភក់ជ្រាំ សំដៅទៅភ្នំមួយដែលនៅឆ្ងាយ ។ សងខាងផ្លូវមានវាលស្រែពណ៌បៃតងស្រងាត់ ។ អារម្មណ៍ភ័យខ្លាចរបស់ខ្ញុំកើតមានឡើងជាថ្មីម្តងទៀត ។ តើមានរឿងអ្វីកើតឡើងប្រសិនបើ តាខន ចាប់ជម្រិតយើង? កាលពីពេលដែលខ្ញុំមកស្រាវជ្រាវថ្នាក់បណ្ឌិតនៅក្នុងឆ្នាំ១៩៩៨ មានអ្នកទេសចរមកពីលោកខាងលិចបីនាក់ត្រូវខ្មែរក្រហមចាប់ជម្រិតនិងបញ្ជូនទៅសំបុកលាក់ខ្លួនរបស់ខ្មែរក្រហម ។ ក្រោយមកអ្នកទេសចរទាំងបីនាក់នេះត្រូវខ្មែរក្រហមសម្លាប់ចោល ។

ខ្ញុំសួរមីងថា "តើមីងគិតថាមានសុវត្ថិភាពដែរឬទេ? មីងខ្លាចទេ?"

មីងអាក់បន្តិច ហើយញញឹមទាំងមិនសូវសម "ចាស៎ ខ្លាចតិចៗដែរ" ។ ខ្ញុំអាចស្មានដឹងថា មុំ ដែលអង្គុយនៅខាងក្រោយបញ្ចេញស្នាមញញឹមដូចជាមិនសូវស្រួលសោះ ។

មីងចង្អុលតាមបង្អួច "កន្លែងដែលយើងចង់ទៅគឺនៅម្តុំនោះ" ។ ខ្ញុំក្រឡេកមើលទៅឆ្វេងដៃឃើញព្រះវិហារធំមួយមានដំបូលពណ៌ខៀវលាយទឹកមាស ។ ដើមឈើពីរដើមលេចត្រដែតគ្របពីលើដំបូលវិហារដែលព័ទ្ធជុំវិញទៅដោយបង្កាន់ដៃនាគ ។ ព្រះវិហារនេះខ្ពស់ត្រដែតប៉ុន្តែមានសភាពចាស់ទ្រុឌទ្រោម ។ ក្បាលនាគជាច្រើនបានបាក់បែកនិងបាត់បង់ ។

នៅទូទាំងប្រទេសកម្ពុជា ព្រះវិហារដែលមានលក្ខណៈដូចនេះបានក្លាយទៅជាកន្លែងស្តួរចម្លើយនិងទីតាំងសម្លាប់ ។ នេះគឺជាមធ្យោបាយមួយដែលខ្មែរក្រហមបង្ហាញភាពស្អប់ខ្ពើមរបស់ខ្លួនចំពោះសាសនា ពីព្រោះខ្មែរក្រហមចាត់ទុកសាសនាជាប៉ារាសិតនិងជាថ្នាំញៀននៃមនុស្សមួយក្រុម ។ បើមិនប្រើប្រាស់វត្តអារាមធ្វើជាគុកទេ ខ្មែរក្រហមប្រើប្រាស់ធ្វើជាឃ្លាំងឬវាយបំផ្លាញចោល ។

មីងសួរខ្ញុំថា "លោកចង់ចូលទៅក្នុងទេ?"

ខ្ញុំឆ្លើយភ្លាមថា "បាទខ្ញុំចង់" ព្រោះខ្ញុំចង់ពន្យារពេលដើម្បីរកមធ្យោបាយដែលមានសុវត្ថិភាពក្នុងការជួប តាខន ។ យើងបត់តាមផ្លូវក្រួសទៅដល់បរិវេណវត្តដែលមានស្មៅ រុក្ខជាតិតូចៗនិងភក់ជ្រាំ ។ ព្រះសង្ឃពីរអង្គគង់នៅក្រោមម្លប់ឈើដើម្បីគេចពីកម្តៅថ្ងៃ ។ កុមារបីនាក់កំពុងលេងដីប្រហែល១០០ម៉ែត្រពីយើង ។ ក្រៅពីមនុស្សប៉ុន្មាននាក់នេះ វត្តទាំងមូលមានសភាពស្ងាត់ជ្រងំ ។

មីង និយាយថា "តាមផ្លូវនេះ" រួចហើយក៏ដើរយ៉ាងលឿនទៅកាន់ជញ្ជាំងខាងជើងព្រះវិហារសំដៅទៅបង្អួចឈើខ្ពស់ ដោយមាន មុំ និងខ្ញុំ ដើរតាមក្រោយ ។ មីងចង្អុលកន្លែងមួយដោយនិយាយថា "ទីនេះជាកន្លែងខ្ញុំឃើញឆ្មាំគុកសម្លាប់អ្នកទោសម្នាក់នោះ ។ ខ្ញុំចំទើតមើលតាមបង្អួចចំហព្រោះខ្ញុំនៅក្មេង ។ មើលទៅគួរឲ្យរន្ធត់" ។ មីងចង្អុលទៅវាលស្រែនៅខាងត្បូងវត្ត ហើយនិយាយទៀតថា "ខ្ញុំឮថាមានរណ្តៅសាកសពជាងសាមសិបនៅម្តុំនោះ" ។

ជាញឹកញាប់ កសិករកម្ពុជានាំខ្ញុំដើរតាមវាលស្រែរបស់គាត់ បង្ហាញខ្ញុំទីវាលដែលមានរណ្តៅសាកសពជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជួនកាលពេលគាត់ភ្ជួរស្រែ គាត់ឃើញវត្ថុមួយចំនួននៅក្នុងអាចម៍បំណះ ដូចជា ធ្មេញ ក្រណាត់រហែករយ៉ៃ បំណែកឆ្អឹង ឬបំណែកលលាដ៍ក្បាល ។ គាត់និយាយថា

"គេឲ្យយើងទៅរស់កន្លែងណាទៀតបើយើងមានដីតែប៉ុណ្ណឹង" ។

មុំ ដែលនៅស្ងៀមយូរមកហើយនោះ និយាយថា "ខ្មែរក្រហមសម្លាប់ប្តីខ្ញុំនៅទីនេះ ព្រោះគាត់ជាបញ្ញវន្ត" ។

បើទោះបីជាមេដឹកនាំខ្មែរក្រហមជាច្រើននាក់ជាអតីតគ្រូបង្រៀនក៏ដោយ ជាទូទៅខ្មែរក្រហមមិនសូវជឿទុកចិត្តបញ្ញវន្តឡើយ ហើយគិតថាបញ្ញវន្តមាននិន្នាការបរទេស ។ ការផ្លាស់ប្តូរគំនិតរបស់កុមារនិងប្រជាជនក្រីក្រគឺងាយស្រួលជាង ដូច្នេះខ្មែរក្រហមសម្លាប់បញ្ញវន្តទាំងនោះចោល ពីព្រោះនិន្នាការបរទេសរបស់បញ្ញវន្តទាំងនោះអាចធ្វើឲ្យអន្តរាយសង្គមបដិវត្តន៍បរិសុទ្ធដែលទើបតែកើតថ្មីៗ ។

បន្ទាប់មកទៀត មុំ រៀបរាប់អំពីហេតុការណ៍មួយដែលខ្មែរក្រហមប្រមែប្រមូលអតីតសិស្សនិងគ្រូបង្រៀនចំនួន៣៦នាក់ចេញពីភូមិដែល មុំ រស់នៅ ។ មុំ រៀបរាប់ថា "ប្តីរបស់ខ្ញុំជាសិស្សតាំងពីមុនរបបខ្មែរក្រហម ។ គាត់នៅក្នុងចំណោមសិស្សនិងគ្រូបង្រៀនទាំង៣៦នាក់ដែលត្រូវខ្មែរក្រហមចាប់ចងនិងដឹកចេញទៅបាត់ ។ ខ្ញុំតាមមើលពីចម្ងាយ ។ គ្មាននរណាម្នាក់បានវិលត្រឡប់មកវិញទេ" ។ បន្ទាប់មកទៀត មុំ រៀបរាប់ឈ្មោះញាតិសន្តានរបស់គាត់ដែលបានបាត់បង់ជីវិតក្រោមរបបកម្ពុជាប្រជាធិបតេយ្យមានដូចជា "ដល នារី ដួង ជា..." ។ មុំ ចំណាយយ៉ាងយូរទើបដឹងថានៅក្នុងគ្រួសាររបស់គាត់មានតែមនុស្សបីនាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត ។

### ជនដៃដល់

យើងដើរត្រឡប់ទៅរថយន្តយ៉ាងស្ងៀមស្ងាត់ ។ ខ្ញុំមានអារម្មណ៍ញាប់ញ័រយ៉ាងខ្លាំងដោយសារតែសោកនាដកម្មរបស់មុំ រូបភាពរន្ធត់ដែលមីងឃើញផ្ទាល់នឹងភ្នែក និងលទ្ធភាពនៃការជួបជាមួយ តាខន ដែលមានការពាក់ព័ន្ធនឹងព្រឹត្តិការណ៍ទាំងនេះ ។ ខ្ញុំសុំឲ្យមីងឈប់រថយន្តនៅក្បែរសាលាឃុំដើម្បីពិនិត្យថាតើតំបន់នោះមានសុវត្ថិភាពដែរឬទេ ។

សាលាឃុំនេះធ្វើអំពីឈើយ៉ាងស្អាត ។ មេឃុំបច្ចុប្បន្នឈ្មោះ លួន មានអាយុប្រហែល៦០ឆ្នាំ ។ គាត់ស្វាគមន៍យើងដោយស្នាមញញឹមរាក់ទាក់ និងនិយាយជាមួយខ្ញុំជាភាសាខ្មែរផង បារាំងផង និងភាសាអង់គ្លេសដែលមិនចំអង់គ្លេសផង ។ នៅពេលដែលគាត់ឮថាយើងមានគម្រោងទៅជួប តាខន គាត់សម្តែងទឹកមុខបដិសេធភ្លាម ។ លួន ឲ្យយោបល់យើងបញ្ជូនអ្នករត់ម៉ូតូឌុបទៅមើលថាតើ តាខន នៅផ្ទះឬអត់ និងសុំឲ្យគាត់មកជួបយើងនៅសាលាឃុំ ។ មីងបញ្ចេញទឹកមុខជាសញ្ញាឲ្យខ្ញុំដឹងថា គាត់យល់ស្របថាមធ្យោបាយនេះប្រសើរនិងមានសុវត្ថិភាពជាង ។ យើងបានអរគុណ លួន ចំពោះយោបល់របស់គាត់ និងបានឲ្យអ្នករត់ម៉ូតូឌុបចេញទៅសួរ តាខន ។

ខ្ញុំអង្គុយនៅលើបង់ឈើមួយនៅខាងមុខសាលាឃុំ ។ ធាតុអាកាសព្រឹកនោះគឺក្តៅហើយសើម ។ ខ្ញុំមិនដឹងថាតើ តាខន នឹងមកសាលាឃុំឬអត់ទេ ។ គាត់ប្រហែលជាមិននៅផ្ទះឬប្រហែលជាមិនមកក៏មិនដឹង ។ ខ្ញុំធ្លាប់សម្ភាសជនដៃដល់ជាច្រើននាក់មកហើយក្នុងអំឡុងពេលជាច្រើនឆ្នាំកន្លងទៅ ។ ជនដៃដល់តិចតួចបំផុតបានសារភាពថាខ្លួនបានប្រព្រឹត្តនូវអំពើឃោរឃៅដូចដែលអ្នកដទៃចោទមែន ។ ទោះជាយ៉ាងណា ជនដៃដល់ទាំងនោះនឹងនិយាយគ្បោះគ្បាយជាងប្រសិនបើយើងសួរត្រឹមតែថា តើហេតុអ្វីបានជាជនដៃដល់ដទៃទៀតសម្លាប់មនុស្ស ។ ការចោទសំណួរប្រយោលបែបនេះអាចរក្សាមុខមាត់ឲ្យដល់ជនដៃដល់និងអាចរកឃើញអារម្មណ៍ផ្ទាល់ខ្លួនរបស់គាត់ ។ ជនដៃដល់មួយចំនួនព្យាយាមបង្ហាញថាខ្លួនមានតួនាទីតូចតាចដែលមិនពាក់ព័ន្ធនឹងការកាប់សម្លាប់ទេ ។ កាលពីពីរថ្ងៃមុន ខ្ញុំបានសម្ភាសអ្នកយាមគុកមួយដែលមានប្រជាជនរាប់រយនាក់ស្លាប់ ។ អ្នកយាមគុកម្នាក់នេះបានបដិសេធចំពោះការចោទប្រកាន់ ប៉ុន្តែសារភាពថាគាត់បានសម្លាប់មនុស្ស"ម្នាក់ឬពីរនាក់ដែរ" ។ ជាក់ស្តែងណាស់ចម្លើយមិនច្បាស់លាស់នេះអាចបញ្ជាក់ថាគាត់បានសម្លាប់មនុស្សច្រើនជាងនេះ ។

បន្ទាប់ពីគិតអំពីបទឧក្រិដ្ឋធ្ងន់ធ្ងរនិងភាពល្បីល្បាញរបស់ តាខន ខ្ញុំចាប់ផ្តើមសង្ស័យថា ប្រហែលជា តាខន មិនមកសាលាឃុំទេ ។ ផ្លូវក្រួសបញ្ចេញស្នូរប្រេះប្រស់និងហុយសំពោងខណៈពេលដែលម៉ូតូមួយគ្រឿងបើកមកឈប់ពីមុខសាលាឃុំ ។ លួន បន្លឺសំឡេងតិចៗថា "តាខន មកហើយ" ។ យើងទាំងពីរនាក់ងាកមើលទៅ តាខន ។

អ្វីដែលខ្ញុំកត់សម្គាល់ដំបូងបំផុតនោះគឺភ្នែកដ៏ជ្រៅរបស់

តាខន ។ គាត់សម្លឹងមើលយើងទាំងគ្រោតគ្រាតនិងមិនសប្បាយចិត្ត ។ ចង្ការរបស់គាត់លយចេញ កន្ទុយភ្នែករបស់គាត់មានស្នាមជ្រួញយ៉ាងខ្លាំង ធ្វើឲ្យរូបរាងរបស់គាត់មើលទៅគួរឲ្យខ្លាច ។ មើលទៅទំនងជាគាត់ស្លៀកសម្លៀកបំពាក់ដែលល្អបំផុតរបស់គាត់ដើម្បីមកជួបយើងក៏មិនដឹង គឺអាវសដែលមានឡេវតែបីនៅផ្នែកខាងលើ ខោជើងវែងពណ៌ខ្មៅចំហុរូត និងក្រមាក្រឡា ស-ក្រហម ។

តាខន ជាកសិករក្រីក្រម្នាក់ ។ ជាការពិត ខ្មែរក្រហមផ្តល់អំណាចឲ្យតែអ្នកដែលមានប្រវត្តិរូប"ស្អាតស្អំ"ប៉ុណ្ណោះ ។ តាខនមើលទៅមានវ័យ៦០ឆ្នាំ និងខុសពីជនដៃដល់ដទៃទៀតដែលខ្ញុំធ្លាប់ជួប ។ នៅពេលដែលខ្ញុំក្រោកឈរស្វាគមន៍ តាខន គាត់ក៏រាក់ទាក់ខ្ញុំវិញដែរប៉ុន្តែមិនបានបង្ហាញឲ្យឃើញការរាប់អានចំពោះខ្ញុំទេ ។ ជាធម្មតា ខ្ញុំជួបជាមួយប្រជាជនកម្ពុជាដូចជា តាខន ជាពិសេសជនដៃដល់ ។

លួង អនុញ្ញាតឲ្យយើងប្រើប្រាស់សាលាឃុំដ៏តូចដែលមានកន្លែងបោកគក់ដ៏កខ្វក់ ប៊ីដុងសាំង ចានឆ្នាំង និងតុមួយ ។ យើងអង្គុយនៅលើកៅអីជ័រពណ៌ខៀវ ។ តាខន អង្គុយទល់មុខមីងនិងខ្ញុំឃ្លាតគ្នាប្រហែលមួយម៉ែត្របូមួយម៉ែត្រកន្លះ ។ ពន្លឺព្រះអាទិត្យជះចូលមកក្នុងបន្ទប់ការិយាល័យតាមទ្វារដែលបើកចំហនិងស្នាមប្រហោងនៅនឹងជញ្ជាំងក្តារ ។ ស្រមោលរបស់ តាខន ក្នុងពន្លឺនេះ ធ្វើឲ្យគាត់មើលទៅហាក់ដូចជាមនុស្សគ្រោះថ្នាក់ជាងមុនទៅទៀត ។

ខ្ញុំបានពន្យល់ប្រាប់ តាខន ថាខ្ញុំជាសាស្ត្រាចារ្យម្នាក់ដែលសិក្សាស្រាវជ្រាវនិងសរសេរសៀវភៅអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកទៀត ខ្ញុំប្រាប់គាត់ថា ខ្ញុំកំពុងតែសិក្សាអំពីវប្បធម៌កម្ពុជា ជាពិសេសអំពីចិត្តសាស្ត្ររបស់ខ្មែរក្រហម ។ នៅពេលដែលខ្ញុំសួរទៅគាត់ថាតើខ្ញុំអាចសម្ភាសលោកតាបានដែរឬទេ តាខន សម្លឹងមុខខ្ញុំហើយឆ្លើយតិចៗថា "បាទ! បាន" ។

នៅពេលដែលខ្ញុំសម្ភាសជាមួយជនដៃដល់ ខ្ញុំតែងតែសួរសំណួរទូទៅជាដំបូង បន្ទាប់មកទើបខ្ញុំសួរសំណួរសំខាន់របស់ខ្ញុំថាតើហេតុអ្វីបានជា តាខន ហ៊ានសម្លាប់មនុស្ស ។

"មុនពេលចូលរួមជាមួយខ្មែរក្រហម លោកតាធ្វើអ្វីដែរ?"

"ខ្ញុំជាកសិករ" ។

"លោកតាចូលរួមជាមួយខ្មែរក្រហមនៅពេលណាដែរ?"

"ឆ្នាំ១៩៧០" ។

"លោកតាមានតួនាទីជាអ្វីដែរ?"

"កងទ័ព" ។

"តើនៅពេលនោះលោកតាបានទទួលការអប់រំនយោបាយអ្វីខ្លះ?"

"គ្មានទេ" ។

ខុសពីមីងដែលរៀបរាប់រឿងរ៉ាវយ៉ាងក្បោះក្បាយ តាខនឆ្លើយតែពាក្យមួយម៉ាត់ៗកំបុតៗ ។ ខ្ញុំដកដង្ហើមធំនិងជូតញើសលើមុខ ។

បន្ទាប់ពីសួរ តាខន អស់រយៈពេលដប់ប្រាំនាទី ខ្ញុំអាចយល់បានថា តាខន ចូលបម្រើជាកងទ័ពខ្មែរក្រហមពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៣ ហើយចូលប្រយុទ្ធជាមួយនឹងទាហានលន់នល់នៅខេត្តតាកែវ ។ នៅឆ្នាំ១៩៧៣ តាខន ផ្លាស់មកធ្វើការនៅមន្ទីរឃុំ ។ ជាចុងក្រោយ តាខន និយាយថា គាត់បានចូលរួមវគ្គអប់រំនយោបាយដែលគាត់បានសិក្សាអំពីវណ្ណៈ ការកសាងសតិអារម្មណ៍បដិវត្តន៍ និងការយកជ័យជម្នះលើសត្រូវ ។ នៅពេលដែលខ្ញុំសួរថា តើលោកតាធ្លាប់ពិភាក្សាអំពីទ្រឹស្តីម៉ាក្ស-លេនីនជាមួយអ្នកណាដែរឬទេ? តាខន ឆ្លើយ "ទេ" ដោយបន្ថែមថា គាត់មិនចេះអក្សរ និងមិនយល់ទ្រឹស្តីនេះឡើយ ។

តាមវិធីនេះ តាខន បានពាក់ព័ន្ធដោយប្រយោលជាមួយបញ្ហាសំខាន់របស់ខ្មែរក្រហម ។ ជារឿយៗ កសិករក្រីក្រត្រូវបានផ្តល់អំណាច ក៏ប៉ុន្តែកសិករក្រីក្រទាំងនោះរៀនសូត្របានតិចតួចណាស់ អ្នកខ្លះមិនចេះអក្សរទាល់តែសោះ ម្ល៉ោះហើយមានការលំបាកក្នុងការស្វែងយល់អំពីមនោគមវិជ្ជារបស់ខ្មែរក្រហម និងកាន់តែលំបាកក្នុងការពន្យល់អំពីមនោគមវិជ្ជាទៅកសិករដទៃទៀត ។ ជាលទ្ធផល មនោគមវិជ្ជារបស់ខ្មែរក្រហមមិនដែលជ្រួតជ្រាបស៊ីជម្រៅទៅក្នុងស្រទាប់កសិករ ហើយប្រជាជនកម្ពុជាភាគច្រើនយល់មិនច្បាស់ ។

ខ្ញុំចាប់ផ្តើមសួរសំណួរដែលទាក់ទិននឹងគោលបំណងរបស់ខ្ញុំបន្ទាប់ពីបានយល់អំពីមូលហេតុដែល តាខន ចូលរួមជាមួយខ្មែរក្រហម ។

"តើគុកនេះបើកនៅពេលណា?"

"គុកណា?"

"គឺគុកដែលស្ថិតនៅក្បែរសាលាឃុំនេះ" ។

"នៅទីនេះគ្មានគុកទេ" ។

មីងបើកភ្នែកធំៗ ។

ទាំងអស់គ្នាស្ងាត់ស្ងៀមមួយស្របក់ ។ ដោយមិនដឹងថាត្រូវឆ្លើយតបយ៉ាងដូចម្តេច ខ្ញុំសម្លឹងមើល តាខន គាត់ក៏សម្លឹងមើលខ្ញុំវិញ ។ មុខរបស់គាត់បែរចំពន្លឺព្រះអាទិត្យដែលចាំងតាមប្រហោងជញ្ជាំង ។

ខ្ញុំចាប់ផ្តើមយល់អំពីចេតនាពិតរបស់ តាខន ។ ជនដៃដល់ភាគច្រើនអះអាងថាខ្លួនមានតួនាទីតូចទាប ធ្វើអ្វីតាមតែបញ្ជាថ្នាក់លើ និងមិនធ្លាប់សម្លាប់នរណាម្នាក់ ។ ក៏ប៉ុន្តែ គ្មានជនដៃដល់ណាម្នាក់ដែលខ្ញុំបានធ្វើសម្ភាសន៍ព្យាយាមបដិសេធវត្តមាននៃគុក និងទីតាំងសម្លាប់ឡើយ ។ នេះប្រហែលជាមូលហេតុដែល តាខន មកជួបនឹងខ្ញុំគឺដើម្បីលុបប្រវត្តិសាស្ត្រក៏មិនដឹង ។

ភ្លាមៗនោះ មីង សួរខ្ញុំជាភាសាអង់គ្លេសថា "តើលោកចង់ឲ្យខ្ញុំប្រាប់ តាខន អំពីអ្វីដែលខ្ញុំបានឃើញដែរឬទេ?"

ខ្ញុំឆ្លើយទៅវិញថា "បានប្រសិនបើមីងចង់ធ្វើដូច្នេះ" ។ មីងក៏ត្រឡប់មករក្សាភាពស្ងប់ស្ងាត់ ។ តាខន ដែលមានពាក់ព័ន្ធនឹងការឈឺចាប់របស់មនុស្សជាច្រើន រួមបញ្ចូលទាំងម្តាយរបស់មីងផង បានបដិសេធរឿងរ៉ាវមួយដែលមីងចងចាំមិនអាចបំភ្លេចបាន ។

ខ្ញុំសម្រេចចិត្តសួរ តាខន ពីជ្រុងផ្សេងមួយទៀត ។ តាខនហាក់ដូចជាមានអារម្មណ៍ធូរស្រាលជាងមុន ព្រោះខ្ញុំមិនបាននិយាយប្រឆាំងនឹងគាត់ ។ ចម្លើយរបស់គាត់ក្បោះក្បាយជាងមុនរហូតដល់ឆ្លើយថាពីមុនគាត់ជាប្រធានឈ្លបឃុំ ។ នៅពេលដែលខ្ញុំសួរអំពីខ្សែសង្វាក់បញ្ជារបស់គាត់ តាខន បានប្រាប់ឈ្មោះកម្មាភិបាលថ្នាក់លើរបស់គាត់ដោយគ្មានស្ទាក់ស្ទើរ ។ តាគី ជាអ្នកគ្រប់គ្រងមន្ទីរឃុំ ហើយគណៈស្រុកឈ្មោះ សន ជាសាច់ញាតិរបស់ តាម៉ុក ។

នៅពេលដែលខ្ញុំវិលមកសួរសំណួរទាក់ទិននឹងការសម្លាប់ តាខន ត្រឡប់មកនិយាយមួយម៉ាត់ៗដូចមុន ។

ខ្ញុំសួរថា "តើនៅថ្នាក់ឃុំមានប្រវត្តិរូបប្រជាជនចំនួនប៉ុន្មាននាក់ដែលត្រូវសើុបអង្កេត?"

តាខន ឆ្លើយទាំងមិនច្បាស់លាស់ "ដូចធម្មតាអីចឹង" ។

មីងនិយាយទៅ តាខន ថា "យើងបានឮថានៅក្នុងតំបន់នេះមានការសម្លាប់ប្រជាជនយ៉ាងសាហាវ" ។

តាខន ឆ្លើយភ្លាមៗដោយមានជំនឿទុកចិត្តថា "គ្មានទេ ។ នៅក្នុងឃុំនេះគ្មានការសម្លាប់ទេ ។ ការសម្លាប់មានតែនៅក្នុងឃុំក្បែរនេះប៉ុណ្ណោះ គ្មាននៅក្នុងឃុំនេះទេ ។ ប្រជាជនចូលចិត្តនិយាយតែបែបហ្នឹងឯង" ។

មីងចាប់ផ្តើមរៀបរាប់ "ក៏ប៉ុន្តែប្រជាជននៅក្នុងឃុំនិយាយថា..."

តាខន កាត់ប្រសាសន៍មីងភ្លាម "ទេ គ្មាននរណាម្នាក់ត្រូវសម្លាប់នៅក្នុងតំបន់នេះទេ" ។

មីងសើចចំអក ហើយនិយាយជាមួយខ្ញុំជាភាសាអង់គ្លេសថា "គាត់និយាយកុហក" ។

មីងសម្លឹងមើលកម្រាលឥដ្ឋដែលពេញទៅដោយធូលីដីនិងដែលមីងជឿថាមានសាកសពជនរងគ្រោះរបស់ តាខន នៅទីនេះ ។ ប្រហែលជាមិនអាចទ្រាំទ្រនឹងទឹកមុខរបស់ តាខន មីងនិយាយទាំងមិនមើលមុខគាត់ថា "មនុស្សជាច្រើនបានប្រាប់ខ្ញុំអំពីអ្វីដែលតាបានធ្វើ" ។

តាខន ជ្រួញចិញ្ចើមដាក់មីងហើយនៅតែបន្តបដិសេធ "គ្មាននរណាម្នាក់ត្រូវសម្លាប់នៅក្នុងឃុំនេះទេ ។ ប្រជាជននិយាយបែបនេះ ក៏ប៉ុន្តែខ្ញុំមិនបានធ្វើអ្វីទេ ។ អយុត្តិធម៌ណាស់ ។ គ្មានភ័ស្តុតាងទាល់តែសោះ ។ គុកនោះនៅឯណា? ឯណាភ័ស្តុតាង?" ។

ខ្ញុំនិយាយកាត់ភ្លាមថា "ខ្ញុំគឺជាសាស្ត្រាចារ្យម្នាក់ ។ ខ្ញុំអានសៀវភៅអស់ជាច្រើនក្បាលអំពីរបបប៉ុលពត ហើយខ្ញុំកំពុងតែសរសេរសៀវភៅមួយក្បាល ។ ខ្ញុំបានសម្ភាសន៍ប្រជាជនកម្ពុជាជាច្រើននាក់ រួមមានទាំងអតីតគណៈឈ្លបឃុំដូចលោកតាដែរ ។ តាមរយៈសៀវភៅនិងបទសម្ភាសន៍ទាំងនោះ ខ្ញុំមិនដែលឮថាក្នុងឃុំណាមួយគ្មានមនុស្សស្លាប់នោះទេ ។ មិនដែលទាល់តែសោះ" ។

តាខន អាក់សម្តីបន្តិច ។ យើងសម្លឹងគ្នាទៅវិញទៅមក ។ ទីបំផុត តាខន គេចមុខចេញ ប្រហែលជាគាត់មិនច្បាស់ថា ខ្ញុំ

បានដឹងអ្វីខ្លះ ។ តាខន នៅតែប្រកែក “គ្មាននៅទីនេះទេ ។ គ្មានភ័ស្តុតាង” ។

ខ្ញុំនិយាយបន្ត “នៅក្នុងឃុំជាច្រើន រួមបញ្ចូលទាំងឃុំនេះដែរ ប្រជាជនបានសរសេរញត្តិផ្ញើទៅរដ្ឋាភិបាល រៀបរាប់អំពីសភាពវន្ទត់ដែលគាត់បានជួបនិងបានឃើញ រួមទាំងការស្លាប់សមាជិកគ្រួសារនិងមិត្តភ័ក្តិរបស់គាត់” ។

តាខន ញ្រោចខ្លួន “គ្មាននរណាម្នាក់ត្រូវសម្លាប់នៅទីនេះទេ ។ សូម្បីតែម្នាក់ក៏គ្មានដែរ ។ បើយើងចាប់បានប្រជាជន យើងដោះលែងវិញនៅពេលក្រោយ ។ កុំជឿអ្វីដែលគេប្រាប់ ។ គ្មាននរណាឃើញអ្វីទេ ។ បើមានប្រជាជនត្រូវសម្លាប់មែននោះ គឺអ្នកដែលមកពីមន្ទីរសន្តិសុខស្រុកទេជាអ្នកធ្វើ” ។

មីងនិយាយកាត់ថា “នៅក្នុងសម័យប៉ុលពត ខ្ញុំក៏រស់នៅទីនេះដែរ ។ ខ្ញុំបានឃើញខ្មែរក្រហមសម្លាប់បុរសម្នាក់នៅក្នុងវត្ត” ។

តាខន បង្អោនខ្លួនមកមុខ ហើយនិយាយថា “គ្មាននរណាម្នាក់ត្រូវសម្លាប់ទេ សូម្បីតែមនុស្សម្នាក់ក៏គ្មានដែរ ។ គ្មានភ័ស្តុតាងទេ” ។

មីងស្រែកទាំងកំហឹង “តាឯងកុហក!” ។

តាខន សម្លឹងមីងទាំងបែកញើសស្រោក់លើថ្ងាសរបស់គាត់ ។ ចុងបញ្ចប់ គាត់និយាយខ្សឹបៗថា “គុកគ្រាន់តែជាកន្លែងឃុំឃាំងមនុស្សប៉ុណ្ណោះ ។ គ្មានអ្នកទោសណាម្នាក់ត្រូវសម្លាប់នៅក្នុងគុកទេ ។ មនុស្សមកពីមន្ទីរស្រុកបានមកយកអ្នកទោសទាំងនោះទៅ ។ ខ្ញុំមិនដឹងថាគេយកអ្នកទោសធ្វើអ្វីទេ” ។ តាខន ហាក់ដូចជាព្យាយាមកែប្រែអ្វីដែលគាត់កំពុងតែព្យាយាមលាក់បាំង ។

មីង សើចហើយនិយាយជាភាសាអង់គ្លេសថា “ឥឡូវនេះគាត់សារភាពពីការសម្លាប់ហើយ” ។

នៅពេលដែលខ្ញុំសួរអំពីស្ថានភាពនៅក្នុងគុក តាខន ឆ្លើយបានរហ័សជាងមុន ។ គាត់ពន្យល់ថា ជុំវិញគុកជាតំបន់ហាមឃាត់ ហើយមនុស្សមកពីមន្ទីរសន្តិសុខស្រុកមកយកអ្នកទោសទៅបាត់ ។ តាខន បដិសេធម្តងទៀតថាគ្មានប្រជាជនណាម្នាក់ត្រូវសម្លាប់ទេ ។ តាខន បញ្ជាក់ថា គាត់ក៏ខ្លាចបាត់បង់ជីវិតដូចជាប្រជាជនដទៃទៀតដែរ ជាពិសេសនៅពេលដែលមនុស្សមកពីមន្ទីរសន្តិសុខស្រុកចុះមក ។ តាខន បន្ថែមថា នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ប្រជាជនបានដេញតាមចាប់គាត់រហូតដល់ក្នុងព្រៃ ។ ក្រោយមកគាត់ត្រូវរដ្ឋាភិបាលចាប់ដាក់គុកអស់រយៈពេលមួយឆ្នាំ ។

នៅពេលដែលខ្ញុំសួរថាហេតុអ្វីបានជាប្រជាជនដេញចាប់គាត់ តាខន ឆ្លើយថា “ខ្ញុំមិនដឹងទេ ។ ប្រជាជនទាំងនោះយល់ច្រឡំ” ។

ក្រដាសមួយសន្លឹករអិលចេញពីសៀវភៅរបស់ខ្ញុំធ្លាក់នៅក្បែរកៅអីដែល តាខន អង្គុយ ។ នោះគឺជាបញ្ជីសំណួរនិងប្រធានបទនៃបទសម្ភាសន៍របស់ខ្ញុំ ។ តាខន ឱនរើសក្រដាសនោះ ហើយប្រគល់ឲ្យខ្ញុំវិញ ។ ពេលដែលខ្ញុំទទួលក្រដាស ដៃរបស់ខ្ញុំបានប៉ះដៃរបស់ តាខន ។ ពេលនោះខ្ញុំមានអារម្មណ៍ថាស្បែករបស់គាត់ក្រិនដោយសារការធ្វើពលកម្មអស់រយៈពេលជាយូរ ។ បន្ទាប់ពីរបបខ្មែរក្រហមបានបញ្ចប់ តាខន បានក្លាយជាកសិករដូចប្រជាជនកម្ពុជាដទៃទៀតដែរ ។

ខ្ញុំបានសួរថា “តើលោកតានិយាយថាម៉េចប្រសិនបើមានអ្នកទោសណាម្នាក់ដែលតាធ្លាប់បានចាប់ហើយ នៅរស់រានមានជីវិត?”

ម្តងនេះ តាខន មិនបានបដិសេធភ្លាមៗឡើយ ។ គាត់បែកញើសស្រោក់ ។ “ខ្ញុំពិតជាសប្បាយចិត្ត ហើយខ្ញុំនឹងឱនគោរពគាត់ដើម្បីសុំទោសគាត់” ។

“តានឹងនិយាយថា សុំទោស?”

តាខន ឆ្លើយថា “ប្រាកដណាស់” ។ តើចុងបញ្ចប់ តាខន ដឹងពីអំពើសាហាវព្រៃផ្សៃរបស់គាត់ដែរឬទេ? ឬក៏គាត់មិនយល់សំណួរដែលខ្ញុំចង់មានន័យថាគាត់មានទោសកំហុសទេ?

យើងជជែកគ្នាអស់រយៈពេលជាងមួយម៉ោង ហើយការសម្ភាសន៍នេះកំពុងតែឈានមកដល់ទីបញ្ចប់ ។ ក៏ប៉ុន្តែ មីង ត្រៀមខ្លួនជាស្រេចមិនឲ្យ តាខន វិលត្រឡប់ទៅផ្ទះទេ ។ មីង សួរគាត់ថា “តើតាគិតថាគួរតែមានតុលាការដែរឬទេ?” ។ ក្នុងពេលដែលយើងកំពុងតែជួបនិយាយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិកំពុងតែចរចាគ្នាក្នុងការនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោស ។ ហេតុដូច្នេះហើយ អតីតកម្មាភិបាល

ខ្មែរក្រហមមានការព្រួយបារម្ភខ្លាចតុលាការចោទប្រកាន់លើរូបខ្លួន បើទោះបីជាមន្ត្រីខាងតុលាការផ្សេងៗបានសន្យាថានឹងកាត់ទោសតែមេដឹកនាំខ្មែរក្រហមកំពូលក៏ដោយ ។

តាខន ឆ្លើយថា "ប្រាកដហើយ ហេតុអ្វីក៏ថាមិនគួរ? ខ្ញុំមិនខ្លាចអ្វីទេ ។ ខ្ញុំមិនបានធ្វើអ្វីដែលគួរឲ្យខ្លាចទេ ។ ខ្ញុំធ្វើទៅតាមបញ្ជាថ្នាក់លើតែប៉ុណ្ណោះ" ។ មើលទៅ តាខន នៅតែមិនមានអារម្មណ៍ល្អដដែល ។ ប្រហែលជាគាត់ខ្លាចក្រសែភ្នែករបស់មីងក៏មិនដឹង ។

មីង ឆ្លើយទាំងខឹងថា "ប៉ុន្តែតាមានតួនាទីជាគណៈឈ្លបឃុំ ។ តាបញ្ជាមនុស្សឲ្យធ្វើ" ។

"ខ្ញុំធ្វើតាមតែបញ្ជាទេ" ។

"កាលនោះអ្នកភូមិគ្រប់ៗគ្នាខ្លាចតា ។ ខ្ញុំឮអ្នកភូមិនិយាយគ្នាថា ឲ្យតែតាសម្លឹងមើលនរណាម្នាក់សូម្បីតែមួយភ្លែត អ្នកនោះនឹងបាត់ខ្លួននៅថ្ងៃបន្ទាប់" ។

"គ្មានទេ ។ អ្នកភូមិទាំងនោះចេះតែនិយាយថាខ្ញុំសាហាវ ប៉ុន្តែមិនពិតទេ ។ ផ្ទុយទៅវិញ ខ្ញុំបានជួយគាត់ទៅវិញទេ ។ បើគាត់ឃ្លាន ខ្ញុំយកអាហារទៅឲ្យគាត់" ។

បុរសម្នាក់បានដើរចូលមកក្នុងបន្ទប់ដើម្បីប្រមូលចានឆ្នាំង ។ តាខន ក្រឡេកមើលបុរសនោះ បន្ទាប់មកមើលមកយើងវិញ ។ តាខន និយាយថា ដល់ពេលដែលគាត់ត្រូវត្រឡប់ទៅផ្ទះវិញហើយ ។

ខ្ញុំមានសំណួរចុងក្រោយមួយចំនួនទៀតសម្រាប់សួរ តាខន ។ "តើមានឈ្លបប៉ុន្មាននាក់ធ្វើការឲ្យតា?"

"ប្រហែលជា៤០នាក់" ។

"អ្នកទាំងនោះឈ្មោះអ្វីខ្លះ?"

"គ្មាននរណាម្នាក់នៅរស់ទេ" ។ តាខន ខកស្ពោះលើកម្រាលឥដ្ឋ ។ គាត់ដឹងថាខ្ញុំចង់និយាយជាមួយអ្នកផ្សេងទៀតនិងសួរអ្នកនោះអំពីគុក ។

"ក៏ប៉ុន្តែតើឈ្លបទាំងនោះមានឈ្មោះអ្វីខ្លះ?"

តាខន ប្រាប់ឈ្មោះមនុស្សមួយចំនួនដែលគាត់អះអាងថាបានស្លាប់បាត់ទៅហើយ ។ ខ្ញុំបានព្យាយាមអូសទាញគាត់ "ក្នុងចំណោមមនុស្ស៤០នាក់ពិតជាមានមនុស្សម្នាក់នៅរស់មែនទេ?"

"អ្នកខ្លះស្លាប់ ហើយខ្លះទៀតទៅរស់នៅឆ្ងាយបាត់ទៅហើយ ។ ខ្ញុំមិនដឹងថាអ្នកទាំងនោះនៅទីណាទេ" ។

ខ្ញុំសួរ តាខន ទៀត "ចុះឈ្មោះរបស់គាត់ទាំងអស់គ្នា?"

តាខន ឈប់មួយភ្លែតទើបនិយាយ "មានបុរសម្នាក់ឈ្មោះ សំរុង ធ្លាប់ធ្វើការជាមួយខ្ញុំនៅក្នុងកងឈ្លប ។ គាត់រស់នៅក្នុងភូមិជាមួយខ្ញុំដែរ" ។

មីងសួរ តាខន ភ្លាម "អ្នកណាជាអ្នកចាប់ខ្លួន លឹម សុផា?"

"លឹម សុផា" តាខន និយាយឈ្មោះនេះម្តងទៀតហាក់ដូចជាធ្លាប់ស្គាល់ "គ្មាននរណាចាប់ខ្លួនគាត់ទេ" ។

មីងខឹងយ៉ាងខ្លាំង "នេះជាឈ្មោះម្តាយរបស់ខ្ញុំ ។ គាត់ត្រូវខ្មែរក្រហមនាំមកសម្លាប់នៅរណ្តៅមួយ ខ្មែរក្រហមប្រាប់ថានោះគឺជារណ្តៅសម្រាប់កប់ខ្មោចគាត់ហើយ" ។

"ទេ" ។

"ឈប់កុហកខ្ញុំទៅ" ។

"ខ្ញុំមិនកុហកក្មួយទេ" ។

"ឥឡូវនេះខ្ញុំខឹងនឹងតាឯងហើយ ព្រោះតាឯងកំពុងតែព្យាយាមប្រាប់ខ្ញុំថាគ្មាននរណាចាប់ខ្លួនម្តាយរបស់ខ្ញុំ ។ អ្នកដែលតាឯងកំពុងតែនិយាយនេះគឺជាម្តាយរបស់ខ្ញុំ ។ ខ្ញុំក៏នៅទីនោះដែរ អ៊ីចឹងហើយទើបខ្ញុំដឹង" ។

តាខន និយាយពាក្យដដែល "ទេ" ហើយបន្ថែមថា "ដល់ពេលខ្ញុំទៅហូបបាយទឹកហើយ ។ ខ្ញុំត្រូវទៅជួបអ្នកផ្សេងទៀត" ។

កិច្ចសម្ភាសន៍ត្រូវបានបញ្ចប់ យើងបីនាក់ក្រោកឈរដើរចេញមកខាងក្រៅ ។ ពេលដែលយើងចេញពីទីងងឹតមកទីភ្លឺ ភ្នែករបស់យើងចាំងនឹងពន្លឺថ្ងៃ ។ មីងនៅតែមានអារម្មណ៍ខឹង ប៉ុន្តែគាត់បានឲ្យ តាខន នូវបារីខ្លះនិងស្ករពីរកំប៉ុងជាសគុណចំពោះការចំណាយពេលវេលារបស់គាត់មកជួបយើង ។ បន្ទាប់មក មីងសួរ តាខន ថាតើយើងអាចថតរូបគាត់បានដែរឬទេ ។ តាខន យល់ព្រមឲ្យថត ។ តាខន សម្លឹងមើលកាមេរ៉ារបស់យើងដោយអត់ធ្មត់ ។

យើងបានឲ្យម៉ូតូឌុបជូន តាខន ត្រឡប់ទៅភូមិរបស់គាត់វិញ ។ ម្ចាស់ម៉ូតូបញ្ឆេះម៉ាស៊ីន ហើយ តាខន ឡើងជិះពីក្រោយ ។ ខណៈដែលកង់ម៉ូតូបក់ បោកធូលីដីដែលមានសាកសពអ្នកទោស

របស់ តាខន ត្រូវកប់នៅទីនោះ តាខន ក្រឡេកមើលមកយើង ដោយជ្រួញចិញ្ចើម ។ ស្នូរម៉ាស៊ីនម៉ូតូកាន់តែតិចទៅៗ រួចក៏បាត់ឈឹង ។

**ជនរងគ្រោះ**

មីងនិងខ្ញុំដើរមកគុបាយ ។ ថ្ងៃជ្រេបន្តិចទៅហើយ ហើយយើងទាំងពីរនាក់ឃ្លានខ្លាំងណាស់ ។ មីង យកសណ្តែកដីពីរកញ្ចប់ចេញពីក្នុងកាបូប ។ យើងញាំបណ្តើរជជែកគ្នាបណ្តើររហូតដល់គំនរសំបកសណ្តែកដីកាន់តែធំឡើងៗ ។

ខ្ញុំសួរ លួង ថាតើ តាខន ធ្លាប់ត្រូវអ្នកភូមិដេញចាប់ដែរឬទេ?

"អ្នកភូមិខឹងតាខន ខ្លាំងណាស់ ពីព្រោះ តាខន បានសម្លាប់ញាតិសន្តានរបស់គាត់ ។ ពេលនោះខ្ញុំទើបតែចូលកាន់មុខតំណែង ហើយរដ្ឋាភិបាលកំពុងតែជំរុញឲ្យមានការបង្រួបបង្រួមជាតិ ដូច្នេះខ្ញុំត្រូវតែការពារ តាខន ។ តាខន រស់នៅក្នុងភូមិនេះអស់រយៈពេលជិតពីរខែ ។ អ្នកស្រុកអ្នកភូមិតែងតែមកផ្ទះរបស់ខ្ញុំ ទាមទារឲ្យខ្ញុំប្រគល់ តាខន ទៅឲ្យគាត់ ។ អ្នកស្រុកអ្នកភូមិចង់សម្លាប់គាត់ដើម្បីសងសឹក" ។

ខ្ញុំនិយាយថា "ក៏ប៉ុន្តែ តាខន បាននិយាយថាគ្មានគុកនៅទីនេះទេ" ។

លួង អស់សំណើចក្នុងភាពស្ងប់ខ្ពើម "តាខន ជាមនុស្សល្ងង់ខ្លៅនិងជាមនុស្សកុហក ។ គាត់មិនចេះអាននិងមិនចេះសរសេរ ។ គាត់មិនដែលបានរៀនសូត្រទេ ។ ហេតុដូច្នេះហើយបានជាគាត់មិនដឹងអ៊ីលូអ៊ីអាក្រក់ ។ ខ្មែរក្រហមត្រូវការមនុស្សដូចគាត់ ។ ពេលដែលខ្ញុំមកដល់ទីនេះ ខ្ញុំឃើញសុទ្ធតែឆ្អឹងនៅគ្រប់ទីកន្លែង ។ កាលពីមុនទីនេះមានក្លិនស្អុយខ្លាំងណាស់ ។ ក្រោយមកទើបរដ្ឋាភិបាលស្នើឲ្យយើងប្រមែប្រមូលឆ្អឹងនិងកសាងស្តូបសម្រាប់រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ" ។

"តើមានឆ្អឹងចំនួនប៉ុន្មាននៅទីនោះ?"

"រាប់រយរាប់ពាន់ ច្រើនណាស់មិនរាប់អស់ ។ តាខន និងគ្នាគាត់សម្លាប់មនុស្សរាប់រយនាក់ ហើយបានស៊ីថ្លើមនិងលេបប្រមាត់របស់ជនរងគ្រោះទៀត ។ តាខន និងគ្នាគាត់ជាឃាតករដែលសាហាវណាស់ ។ គាត់ធ្វើកិច្ចការរបស់គាត់យ៉ាងសម្ងាត់" ។

"តើលោកពូខ្លាច តាខន ដែរឬទេ?"

លួង សើច "ពីមុនខ្ញុំខ្លាច តាខន ប៉ុន្តែឥឡូវនេះខ្ញុំលែងខ្លាចគាត់ហើយ" ។

ស្មៀនរបស់ លួង ប្រាប់យើងថា មានអ៊ំប្រុសម្នាក់ឈ្មោះ ផន ដឹងរឿងរ៉ាវដែលបានកើតឡើងនៅក្នុងគុក ។ នៅក្នុងឆ្នាំ ១៩៧៥ ផន ត្រូវខ្មែរក្រហមចាប់ដាក់គុកអស់រយៈពេលជិតមួយឆ្នាំពីបទខុសសីលធម៌ ។ ឥឡូវនេះ ផន ជាអាចារ្យវត្តដែលនៅមិនឆ្ងាយប៉ុន្មានពីទីកន្លែងនេះទេ ។ យើងបានឲ្យអ្នករត់ម៉ូតូឌុបទៅសួរ ផន តើគាត់ព្រមមកជួបយើងដែរឬទេ ។

ផ្ទៃមេឃចាប់ផ្តើមងងឹតបន្តិចម្តងៗ ។ ខ្យល់បក់បោកខ្លាំងជាងមុន ។ ពេលនេះគឺជារសៀល នៅក្នុងរដូវវស្សាជាពេលដែលទឹកភ្លៀងមូសុងធ្លាក់ស្រោចស្រពលើដីដែលហុយសំពោងឲ្យក្លាយជាភក់ជ្រាំ ។ នៅក្នុងតំបន់នោះ ទឹកភ្លៀងស្រោចស្រពលើរណ្តៅសាកសព ។

យើងម្នាក់ៗមានអារម្មណ៍អស់កម្លាំង ។ លួង និយាយថា "ខ្ញុំសង្ស័យតែ អ៊ំផន មិនមកទេ ព្រោះគាត់ជាអាចារ្យ គាត់មិននិយាយរឿងនយោបាយទេ" ។

ផន បានមកដល់ខណៈពេលដែលខ្ញុំកំពុងតែសម្លឹងដីសញ្ជឹងគិតអំពីអារម្មណ៍ភ័យខ្លាចរបស់ជនរងគ្រោះពេលដែលត្រូវនាំទៅមាត់រណ្តៅ ។ ផន ស្លៀកពាក់ស្អាតបាតជាង តាខន ។ គាត់ពាក់អាវអាចារ្យ ខោជើងវែងពណ៌ខ្មៅ និងបង់កក្រមាពណ៌ខៀវ ។ ផ្ទៃមុខគាត់ជ្រីវជ្រួញដោយសារពន្លឺថ្ងៃ ភ្លៀង ធូលីដី និងប្រហែលជាដោយសារគុករបស់ តាខន ដែរ ។

ផន ញញឹមរាក់ទាក់ខណៈដែលគាត់លើកដៃសំពះយើង "ជម្រាបសួរ ក្មួយៗសុខសប្បាយជាទេ" ។

ក្រោយពីខ្ញុំពន្យល់យ៉ាងសង្ខេបអំពីមូលហេតុដែលខ្ញុំចង់ជួបនិយាយជាមួយគាត់ ខ្ញុំបានអញ្ជើញគាត់ចូលទៅក្នុងបន្ទប់ខាងក្រោយជាមួយខ្ញុំ ។ ផន មិនបានដើរចូលទៅក្នុងទេ ផ្ទុយទៅវិញគាត់ដើរចេញទៅខាងក្រៅដោយនិយាយថា "មិនអីទេ ។ ខ្ញុំចូលចិត្តនិយាយនៅខាងក្រៅបែបនេះ" ។ ខ្ញុំឆ្ងល់ថាតើគាត់កំពុងតែគិតអំពីរយៈពេលដែលគាត់ជាប់នៅក្នុងគុកមែនទេ ។

យើងអង្គុយនៅតុដែលពន្រាយទៅដោយសំបកសណ្តែកដី

ដបទឹក កំប៉ុងស្ងួជា និងកញ្ចប់នំទទេ ។ មីងនិងខ្ញុំអង្គុយទល់មុខ ផន ហើយ លួង និង មុំ អង្គុយកៅអីក្បែរនោះ ។ ទាំងអស់គ្នានិយាយជាមួយ ផន ដោយការគោរព ។ ផន ហាក់ដូចជាមានអារម្មណ៍ធូរស្រាល ហើយឆ្លើយដោយគ្មានស្ទាក់ស្ទើរ ។ គាត់និយាយមួយៗ ហើយបញ្ចេញសំឡេងស្រាលៗនៅពេលសង្កត់ន័យម្តងៗ ។

មុនពេលដែលខ្មែរក្រហមចូលកាន់កាប់តំបន់នេះ ផន ជាកសិករ ។ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ គាត់ត្រូវបានទុកជាប្រជាជនចាស់ ។

ខ្ញុំសួរគាត់ថា "តើខ្មែរក្រហមចាប់ខ្លួនអ៊ំនៅពេលណា?"

"ឆ្នាំ១៩៧៥ ។ ខ្មែរក្រហមចោទប្រកាន់ខ្ញុំពីបទខុសសីលធម៌ និងនិយាយលេងសើចជាមួយប្អូនស្រីថ្លៃរបស់ខ្ញុំ ។ ខ្ញុំគ្រាន់តែនិយាយលេងសើចជាមួយនាងប៉ុណ្ណោះ គ្មានអ្វីក្រៅពីនេះទេ ។ ប្រហែលជាមានការពាក់ព័ន្ធនឹងការប្រច័ណ្ឌក៏មិនដឹង ។ ទោះជាយ៉ាងណាខ្មែរក្រហមមកចាប់ខ្ញុំដដែល ។ តើឲ្យខ្ញុំធ្វើម៉េច? នៅពេលនោះយើងគ្មានសិទ្ធិតវ៉ាទេ ។ យើងត្រូវតែធ្វើតាមបញ្ជាមួយរយភាគរយ ។ ខ្មែរក្រហមចាប់ខ្ញុំដាក់គុកអស់រយៈពេលប្រាំបួនខែនិងប្រាំពីរថ្ងៃទើបដោះលែងខ្ញុំ" ។

ទោះបីជាប្រជាជនជាច្រើនត្រូវខ្មែរក្រហមចាប់ដាក់គុក ដោយចោទប្រកាន់ថាជាសត្រូវឬជាជនក្បត់ក៏ដោយ ប៉ុន្តែក៏មានប្រជាជនមួយចំនួនត្រូវចាប់ដាក់គុកដោយសារបទឧក្រិដ្ឋតូចតាចដែរ ។ តាមពិត អ្នកទោសទាំងនោះនៅតែប្រឈមមុខនឹងគ្រោះថ្នាក់ដដែល ពីព្រោះបទឧក្រិដ្ឋតូចតាចមួយក៏អាចត្រូវបានចាត់ទុកថាជាអំពើក្បត់ដូចគ្នា ។

"តើនរណាខ្លះចាប់ខ្លួនអ៊ំ?"

"ឈ្មោះ ទ្រូង និងដៃស្តាំរបស់គាត់ឈ្មោះ ខន ។ ទ្រូង ជាប្រធានគុក ហើយ តាខន ជាអនុប្រធានគុក ។ ថ្ងៃមួយឈ្លបពីរបីនាក់មកស្នើឲ្យខ្ញុំទៅជួយរើផ្ទុងសាំងនៅសាលាឃុំ ។ ឈ្លបទាំងនោះមិនបានចងឬវាយខ្ញុំទេ គ្រាន់តែនាំខ្ញុំទៅដល់គុកហើយចាប់ខ្ញុំ ប៉ុន្តែខ្ញុំនៅតែភ័យខ្លាច ។ ខ្ញុំមិនដឹងតើឈ្លបទាំងនោះនឹងធ្វើអ្វីខ្ញុំទេ" ។

"តើនៅក្នុងគុកមានសភាពយ៉ាងម៉េច?"

"គួរឲ្យខ្លាចណាស់ ។ ក្នុងរយៈពេលប្រាំបួនខែនិងប្រាំពីរថ្ងៃក្នុងចំណោមអ្នកទោសនៅទីនោះខ្ញុំគឺជាមនុស្សតែម្នាក់គត់ដែលនៅរស់ ។ ខ្មែរក្រហមយកមនុស្សទៅរៀនសូត្រ ប៉ុន្តែគ្មាននរណាម្នាក់ត្រឡប់មកវិញឡើយ ។ ខ្ញុំមិនដឹងថាហេតុអ្វីបានជាខ្មែរក្រហមមិនយកខ្ញុំទៅ ។ ប្រហែលជាខ្ញុំមានវ័យចាស់ ហើយមានទោសស្រាលក៏មិនដឹង" ។ ផន អាក់បន្តិចដើម្បីគិត បន្ទាប់មកគាត់និយាយថា "ខ្ញុំមិនដឹងថាហេតុអ្វីទេ" ។

"តើជីវិតនៅក្នុងគុកយ៉ាងម៉េចដែរ?"

"ពិបាកណាស់ ។ មានអ្នកទោសប្រហែលពីដប់ប្រាំទៅម្ភៃនាក់ជាប់គុកកាលនោះ ។ ពេលមួយនោះ ឈ្លបបានយកក្មេងជំទង់ដែលឈ្លោះប្រកែកវាយតប់គ្នាដណ្តើមអាហារ ។ ក្មេងៗទាំងនោះបាត់ខ្លួនអស់នៅសល់តែខ្ញុំ" ។ ផន ស្ទាក់ស្ទើរម្តងទៀតមុននឹងរៀបរាប់បន្តថា "ឆ្មាំគុកគឺជាមនុស្សអាក្រក់និងកាចសាហាវណាស់ ។ ឆ្មាំគុកវាយទាត់ធាក់យើងសូម្បីតែយើងធ្វើខុសបន្តិចបន្តួចក៏ដោយ ។ យើងមិនអាចរត់គេចបានទេ ព្រោះជើងរបស់យើងជាប់ខ្នោះ ។ នេះជាវាសនារបស់យើង ។ យើងត្រូវហៅឆ្មាំគុកថា "តា" "តាទ្រូង" "តាខន" ។ សូម្បីតែក្មេងដែលយាមយើងក៏យើងត្រូវហៅថា "តា" ដែរ ។ ឆ្មាំគុកយាមយើងគ្រប់ពេលវេលា ។ យើងត្រូវបង្ខំឲ្យធ្វើការងារលំបាកៗចាប់ពីម៉ោងប្រាំមួយព្រឹករហូតដល់ម៉ោងប្រាំបីឬប្រាំបួនយប់ ។ បន្ទាប់ពីការងារលំបាកទាំងនេះយើងស្រេកឃ្លានយ៉ាងខ្លាំង ព្រោះយើងបានទទួលរបបបាយតិចតួចបំផុត ។ យើងហូបបាយទាំងជាប់ខ្នោះច្រវ៉ាក់ ។ យើងរស់ដូចសត្វធាតុ គ្មានអាហារគ្រប់គ្រាន់ ត្រូវវាយដំតាមអំពើចិត្ត និងរស់ក្នុងសភាពភ័យខ្លាច" ។

"តើខ្មែរក្រហមទុកអ្នកទោសនៅក្នុងគុកក្នុងរយៈពេលយូរប៉ុនណា?"

"ពុំមានពេលកំណត់ទេ ។ មួយខែឬពីរខែបន្ទាប់មកអ្នកទោសត្រូវបាននាំយកទៅរៀនសូត្រ ។ កាលនោះខ្ញុំនៅទីនោះ មនុស្សពីហុកសិបទៅចិតសិបនាក់ឆ្លងកាត់ដំណាក់កាលនេះ ។ អ្នកទោសត្រូវចាប់ខ្លួនមក ហើយត្រូវនាំយកទៅបាត់ គឺចូលចេញៗ ។ នៅពេលឮឆ្មាំគុកប្រាប់ថាទៅរៀនសូត្រ អ្នកទោសប្រែទឹកមុខមាំនិងស្លេក ។ គាត់ដឹងថាគាត់នឹងត្រូវយកទៅសម្លាប់ចោល ។ ពាក្យថា "រៀនសូត្រ" មានន័យថា "ស្លាប់" ។ យើងទាំងអស់គ្នាដឹងច្បាស់ពាក្យនេះ ក៏ប៉ុន្តែតើយើងអាចធ្វើបាន? ខ្ញុំជាមនុស្សមានសំណាង ។ ខ្ញុំគឺជា

មនុស្សតែម្នាក់គត់ដែលនៅរស់រានមានជីវិត ។ អ្នកដទៃទៀតត្រូវយកទៅសម្លាប់ទាំងអស់គ្មានសល់" ។

"តើអ្នកទោសទាំងនោះត្រូវខ្មែរក្រហមយកទៅព្រះវិហារវត្តដែរឬទេ?"

"មានគុកមួយផ្សេងទៀតសម្រាប់ដាក់អ្នកទោសសំខាន់ៗ ។ ខ្ញុំមិនដឹងថាមានរឿងកើតឡើងនៅទីនោះទេ ប៉ុន្តែខ្ញុំដឹងថាអ្នកទោសទាំងនោះត្រូវយកសម្លាប់នៅក្បែរព្រះវិហារនិងនៅក្នុងព្រៃ ។ យើងទាំងអស់គ្នាដឹងអំពីរឿងនេះ ប៉ុន្តែតើយើងអាចធ្វើអ្វីបាន? យើងមិនអាចធ្វើអ្វីបានឡើយ ។ យើងគ្មានលទ្ធភាពជួយគ្នាទេ" ។

មីងសួរ "ចុះ តាខន និង តាទ្រុង? តើអ្នកទាំងពីរនេះយ៉ាងម៉េចដែរ?"

"តាមដែលខ្ញុំឃើញ អ្នកទាំងពីរនេះមិនដូចគ្នាទេ ។ តាទ្រុងមានអំណាចជាង ក៏ប៉ុន្តែ តាខន សាហាវជាង ។ តាខន មិនឲ្យប្រជាជនដឹងអ្វីដែលគាត់កំពុងតែធ្វើទេ ។ គាត់ធ្វើអ្វីៗយ៉ាងសម្ងាត់ ។ គាត់បញ្ជាឲ្យអ្នកដទៃធ្វើ ។ ក្មួយដឹងទេ គាត់មិនចេះអក្សរទេ ក៏ប៉ុន្តែគាត់មានអំណាចគួរឲ្យខ្លាច ។ អ្នកស្រុកអ្នកភូមិនិយាយថាស្បែករបស់គាត់បាញ់មិនមុតទេ ។ គាត់ថែមទាំងអាចបំបែកឈើដោយប្រើដៃរបស់គាត់ទៀតផង ។ នៅពេលគាត់ខឹងម្តងៗគាត់វាយរបស់របរបែកខ្ទាយ ។ កាលនោះអ្នកស្រុកអ្នកភូមិខ្លាចណាស់នៅពេលឮឈ្មោះ តាខន សូម្បីតែក្មេងតូចៗក៏ខ្លាចដែរ ។ គាត់មានអំណាចដែលមិនគួរឲ្យជឿ ។ គ្មាននរណាម្នាក់ហ៊ានមើលមុខគាត់ទេ" ។

ខ្ញុំសួរថា "តើអ៊ំគិតថា តាខន សម្លាប់មនុស្ស?"

"ពិបាកដឹងណាស់ ។ ខ្មែរក្រហមផ្តល់អំណាចយ៉ាងធំសម្បើមដល់មនុស្សល្ងង់ ។ អ្នកទាំងនោះពិតជាហ៊ានសម្លាប់មនុស្សដើម្បីមុខមាត់និងតំណែង ព្រោះពីមុនអ្នកទាំងនោះគ្មានតួនាទីអ្វីទាំងអស់ ។ អ្នកខ្លះមានកំហឹងវណ្ណៈ ។ ពិបាកនិយាយណាស់ ។ អ្វីដែលខ្ញុំដឹងច្បាស់នោះគឺយើងទទួលរងការឈឺចាប់ហួសពីការគិតនៅក្នុងរយៈកាលបីឆ្នាំប្រាំបីខែនិងម្ភៃថ្ងៃ ។ ឥឡូវនេះខ្ញុំចង់តែបំភ្លេចរឿងនេះចោលទាំងអស់ ។ ហេតុនេះហើយបានជាខ្ញុំធ្វើជាអាចារ្យរស់នៅជាមួយព្រះសង្ឃ ។

ពាក្យពេចន៍ទាំងនេះបង្ហាញថា ផន ចង់បញ្ចប់បទសម្ភាសន៍ ។ គាត់ច្រត់ដៃលើគុដើម្បីក្រោកឈរ ។ គាត់ឱនទៅមុខបន្តិច ហើយនិយាយថា "នៅក្នុងទ្រឹស្តីព្រះពុទ្ធសាសនា ធ្វើអំពើល្អបានទទួលផលល្អ ធ្វើអំពើអាក្រក់នឹងបានទទួលផលអាក្រក់" ។

ខ្ញុំនឹកក្នុងចិត្តចង់ឲ្យពាក្យទាំងនេះឮដល់ តាខន ។

ដល់ពេលដែលយើងទាំងអស់គ្នាត្រូវត្រឡប់ទៅវិញ ។ ពេលល្ងាចបានចូលមកដល់ ។ បន្ទាប់ពីលា ផន មីងនិងខ្ញុំបានអរគុណ លួង ចំពោះការជួយនិងការផ្តល់កន្លែងសម្ភាសន៍ ។ លួងញញឹមហើយទទូចឲ្យយើងមកលេងនឹងគាត់ម្តងទៀត ។ លួងនិយាយនៅពេលដែលមីងនិងខ្ញុំចូលក្នុងរថយន្តថា "ខ្ញុំគិតថាពិតជាមានគុកនៅទីនេះ" ។ គាត់ក្រឡេកមើលមេឃហើយនិយាយទៀតថា "សូមបើកឡានប្រយ័ត្នប្រយែង" ។

ខណៈដែលមីងបើករថយន្តចេញតាមផ្លូវដីកខ្វក់ ខ្ញុំងាកក្រោយមើលសាលាឃុំនិងព្រះវិហារ ព្យាយាមផ្តិតយកទិដ្ឋភាពនេះទុកក្នុងអារម្មណ៍របស់ខ្ញុំ ។ កន្លងយូរមកហើយ មានគុកចំនួនពីរកន្លែង រណ្តៅសាកសព និងមនុស្សជាច្រើន នៅលើដីដ៏កខ្វក់នេះ ។ លួង គ្រវីដៃលា រូបភាពរបស់គាត់កាន់តែឆ្ងាយទៅៗ ។ អ្វីដែលខ្ញុំឃើញចុងក្រោយបំផុតគឺចុងដើមឈើពីរដើមដែលបង្អោនលើដំបូលព្រះវិហារ ហាក់ដូចជាសំយុងចុះដោយទម្ងន់នៃការចងចាំ ។

**អាឡិច ហ៊ិនតុន**

## ពាក្យស្លោកខ្មែរក្រហម

- ពង្រឹងពង្រីករបបសមូហភាព សង្គមនិយម ឱ្យបានកាន់តែណែនល្អនៅតាមសហករណ៍ រោងចក្រ ការដ្ឋាន មន្ទីរទាំងអស់ ទាំងនយោបាយ សតិអារម្មណ៍ ចាត់តាំងខ្ជាប់ជានិច្ច។
- ពង្រឹងពង្រីករបបផ្តាច់ការ វណ្ណៈអធន ឱ្យកាន់តែរឹងប៉ឹងល្អ នៅតាមសហករណ៍ រោងចក្រការដ្ឋាន ក្រសួង មន្ទីរទាំងអស់ ទាំងនយោបាយ សតិអារម្មណ៍ និងចាត់តាំងខ្ជាប់ជានិច្ច។
- ផ្អែកឱ្យរឹងមាំលើវណ្ណៈអធន តាមសម្ព័ន្ធភាពកម្មករ កសិករ សាមគ្គីយ៉ាងជិតស្និទ្ធ ជាមួយកម្លាំងទាំងអស់ ធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេស។
- អនុវត្តឱ្យបានដាច់ខាតរបបស្បៀងអាហារដែលបក្សកំណត់ពីដើមដល់ចុងឆ្នាំ។

*(សៀវភៅកំណត់ហេតុលេខ០៧៦)*

# ពិធីប្រកាសជ័យលាភីក្នុង "វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ" លើកទី២

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៦ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរបានរៀបចំពិធីប្រកាសជ័យលាភីក្នុង "វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ" ដោយមានការចូលរួមពីម្ចាស់អត្ថបទប្រជាជនកម្ពុជាដែលជាជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ និងសិស្សនិស្សិតប្រមាណជាង១០០នាក់ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត រស់ ចន្ត្រាបុត្រ ។

ជ័យលាភីនៃវេទិកានេះបានដល់បេក្ខជនចំនួន៤រូបគឺ ៖ ១) លោកស្រី ទេព ស៊ុយអ៊ាង ម្ចាស់អត្ថបទ "បំភ្លេចមិនបាន" ២) លោកស្រី អ៊ុំ សារ៉េត ម្ចាស់អត្ថបទ "ទឹកភ្នែកម៉ែ" ៣) លោក វេជ្ជបណ្ឌិត ហ៊ិន ឈុនលី ម្ចាស់អត្ថបទ "ជីវិតគ្រូពេទ្យម្នាក់ក្នុងរបបខ្មែរក្រហម" និង ៤) លោកស្រី ឈន ឡា ម្ចាស់អត្ថបទ "ជីវិតខ្ញុំក្នុងរបបប៉ុលពត" ។



លោក យូ បូ ប្រធានសមាគមអ្នកនិពន្ធខ្មែរជូនរង្វាន់ដល់លោកស្រី អ៊ុំ សារ៉េត ជ័យលាភីលេខ២

ការបង្កើត "វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ"មានគោលបំណងបួនគឺ ១) លើកទឹកចិត្តឲ្យប្រជាជនកម្ពុជាចូលរួមចំណែកថែរក្សាប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងឮនិងសិក្សារៀនសូត្រ ២) គឺជាវិធីមួយក្នុងការរំងាប់អារម្មណ៍ដោយសារការយកហេតុការណ៍នៃសេចក្តីទុក្ខនិងការខឹងគុំគួនមកតម្កល់ជាឯកសារប្រវត្តិសាស្ត្រសម្រាប់បម្រើឲ្យការសិក្សាស្រាវជ្រាវ ៣) បង្ហាញថាការចងចាំគឺជាវិធីសាស្ត្រអហិង្សាក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀត និង៤) ជំរុញឲ្យមានការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាដែលបានបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងជំរុញឲ្យលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

វេទិកានេះត្រូវបានរៀបចំឡើងនៅឆ្នាំ២០០៣ ក្រោមកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសមាគមអ្នកនិពន្ធខ្មែរ ដោយបានអំពាវនាវឲ្យប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលកំពុងតែរស់នៅទាំងក្នុងនិងក្រៅប្រទេស ចូលរួមសរសេរអត្ថបទអំពីរឿងរ៉ាវផ្ទាល់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬរឿងរ៉ាវរបស់ញាតិមិត្តដែលអ្នកនិពន្ធបានឃើញផ្ទាល់ភ្នែក និងអំពីទស្សនៈផ្ទាល់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនេះឲ្យកាន់តែពិស្តារថែមទៀត ។

ជ័យលាភីនៅក្នុង"វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ"លើកទី១ត្រូវបានប្រកាសកាលពីខែមេសា ឆ្នាំ២០០៤ ។ អត្ថបទដែលបានផ្ញើមកចូលរួមក្នុងវេទិកានេះនឹងត្រូវបានចុះផ្សាយក្នុងទស្សនាវដ្តីស្វែងរកការពិត និងតម្កល់ទុកជាឯកសារប្រវត្តិសាស្ត្រ សម្រាប់បម្រើឲ្យការស្រាវជ្រាវនិងការអប់រំនៅពេលអនាគត ។ វេទិកានេះគឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីជាច្រើនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបង្កើតឡើងដើម្បីការចងចាំនិងយុត្តិធម៌ចំពោះប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ ។

**ឌួង សុភារិទ្ធ**

# ស្វែងរករូបថតជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្តាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ FM102MHz ទីក្រុងភ្នំពេញ វិទ្យុ FM93.25MHz ខេត្តកំពត វិទ្យុ FM99MHz ខេត្តព្រះវិហារ និងវិទ្យុFM ១០៣.២៥MHz ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះយើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួនតែប៉ុណ្ណោះ ។ រូបថតទាំងនោះចាំបាច់ ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នកបន្ទាប់មក នឹងប្រគល់ រូបថតដើមជូនទៅលោកអ្នកវិញ ។



រូបថតរៀបអាពាហ៍ពិពាហ៍ សំ ស៊ីនថៃ និង ហួត ផាន់ណារី ក្នុងឆ្នាំ១៩៦៨

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញឬទាក់ទងតាមអ៊ីមែល truthpivoine@dccam.org ។

សូមអរគុណ ។

# សំណងសម្រាប់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ក្របខណ្ឌលិខិតូបករណ៍និងស្ថាប័ននានា

(តចប់)

### ខ) ស្ថាប័នអន្តរជាតិតាមតំបន់

### ខ១) ប្រព័ន្ធសិទ្ធិមនុស្សនៅអ៊ឺរ៉ុប

បញ្ហាសិទ្ធិមនុស្សនៅក្នុងដែនដីអឺរ៉ុបជាទូទៅប្រហែលជាដកស្រង់ចេញពីភាសាច្បាប់ដែលមានចែងក្នុងមាត្រា៣នៃលក្ខន្តិកៈក្រុមប្រឹក្សាអឺរ៉ុបថា "គ្រប់សមាជិកនៃក្រុមប្រឹក្សាអឺរ៉ុបត្រូវតែទទួលស្គាល់គោលការណ៍នីតិរដ្ឋនិងគោលការណ៍នៃការទទួលបានការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានរបស់បុគ្គលក្នុងទឹកដីដែលបុគ្គលនោះរស់នៅ..." ។ មួយឆ្នាំក្រោយបន្ទាប់ពីការបង្កើតក្រុមប្រឹក្សាអឺរ៉ុបក្នុងឆ្នាំ១៩៥០ អនុសញ្ញាស្តីអំពីការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន (អនុសញ្ញាអឺរ៉ុប) ត្រូវបានអនុម័តនិងធ្វើវិសោធនកម្មលើពិធីសារបន្ថែមទី១១នៃអនុសញ្ញានេះជាបន្តបន្ទាប់ ។

អនុសញ្ញាអឺរ៉ុបនេះបានបង្កើតឲ្យមានស្ថាប័នធំពីរដំបូងគឺគណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប និងតុលាការសិទ្ធិមនុស្សអឺរ៉ុប ។ ក្រោយមក អនុសញ្ញាអឺរ៉ុបត្រូវបានជំនួសដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប (តុលាការអឺរ៉ុប) ក្នុងការបំពេញការងារជាអចិន្ត្រៃយ៍ដោយមានចៅក្រមធ្វើការពេញម៉ោងប្រចាំនៅទីក្រុងស្ត្រាស្បួកនៃប្រទេសបារាំងក្នុងការ"ធានាលើការឃ្លាំមើលការប្រតិបត្តិអនុសញ្ញានិងពិធីសារបន្ថែមរបស់ភាគីក្នុងអនុសញ្ញាអឺរ៉ុបនិងពិធីសារបន្ថែម"នោះ ។

តុលាការអឺរ៉ុបដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមមាត្រា១៩នៃអនុសញ្ញាអឺរ៉ុបដែលត្រូវបានធ្វើវិសោធនកម្មដោយពិធីសារបន្ថែមទី១១ (អនុសញ្ញាដែលធ្វើវិសោធនកម្មរួច) ត្រូវបានចាត់ទុកថាជា"យន្តការគ្រប់គ្រងមួយ" ដូចដែលអាចដោះស្រាយបញ្ហារំលោភលើសិទ្ធិដែលមានចែងក្នុងអនុសញ្ញានិងពិធីសារបន្ថែមនានា ។ តុលាការអឺរ៉ុបត្រូវបំពេញកិច្ចការជាក្រុមៗរួមមាន "តុលាការពេញអង្គ" "គណៈកម្មាធិការ" "សភាផ្នែកៗ" និង "សភាជាន់ខ្ពស់" ។ "គណៈកម្មាធិការរដ្ឋមន្ត្រី"គឺជាស្ថាប័នមួយស្ថិតក្រោមអនុសញ្ញាអឺរ៉ុបថ្មីដែលមានតួនាទីអនុវត្តសាលក្រមរបស់តុលាការអឺរ៉ុប ។

មុនបំពេញការងាររបស់ខ្លួន ដូចមានចែងក្នុងមាត្រា៣៤នៃអនុសញ្ញាអឺរ៉ុបថ្មី តុលាការសិទ្ធិមនុស្សអឺរ៉ុបមានដែនសមត្ថកិច្ចទទួលបណ្តឹងជាបុគ្គល (ដែលរៀបចំឡើងដោយបុគ្គលណាម្នាក់អង្គការក្រៅរដ្ឋាភិបាល ឬក្រុមណាមួយ) ដែលប្តឹងភាគីរដ្ឋជាសមាជិកនៃអនុសញ្ញាអឺរ៉ុបអំពីការរំលោភបំពានសិទ្ធិដែលមានចែងក្នុងអនុសញ្ញាចាប់ពីមាត្រា២ដល់មាត្រា១៨និងក្នុងពិធីសារបន្ថែម ។ ជារឿយៗ ភាគីហត្ថលេខីនៃអនុសញ្ញាក៏អាចរៀបចំពាក្យបណ្តឹងទៅតុលាការអំពីការចោទប្រកាន់ការរំលោភបំពានណាមួយទៅលើបទបញ្ញត្តិនានានៃអនុសញ្ញាអឺរ៉ុប និងពិធីសារបន្ថែមទាំងឡាយដោយភាគីមួយផ្សេងទៀត ។

អាស្រ័យដូចនេះ សិទ្ធិទទួលបានការជួសជុលសំណងដ៏មានប្រសិទ្ធភាព ដែលនាំឲ្យមានសំណងសម្រាប់ជនរងគ្រោះដោយសារការរំលោភបំពានសិទ្ធិមនុស្សក្រោមអនុសញ្ញាអឺរ៉ុបត្រូវបានតុលាការចាត់ទុកតាមច្បាប់ថាជាទម្រង់នៃ"ការសុខចិត្តប្រកបដោយយុត្តិធម៌" ។ មាត្រា៤១នៃអនុសញ្ញាចែងថា "ប្រសិនបើតុលាការរកឃើញថាមានការរំលោភបំពានលើអនុសញ្ញាឬពិធីសារបន្ថែម ហើយប្រសិនបើច្បាប់ក្នុងស្រុករបស់ភាគីជាន់ខ្ពស់នៃអនុសញ្ញាអនុញ្ញាតឲ្យមានសំណងត្រឹមតែផ្នែកណាមួយមែននោះ តុលាការត្រូវផ្តល់សំណងជាការសុខចិត្តប្រកបដោយយុត្តិធម៌ដល់ភាគីរងគ្រោះ" ។ ហេតុដូច្នេះហើយ មុននឹងសម្រេចបានមាត្រាស្តីពីសំណងជាទម្រង់នៃ"ការសុខចិត្តប្រកបដោយយុត្តិធម៌" គឺត្រូវការឲ្យមានដំណើរការវែកញែកនិងពិភាក្សាយ៉ាងយូរ ព្រមទាំងបានការដកស្រង់នូវប្រភពមុនៗក្នុងអំឡុងពេលធ្វើសេចក្តីព្រាងអនុសញ្ញាអឺរ៉ុបជាច្រើន ។

ដូចនេះ ក្រៅពីអ្វីដែលចែងក្នុងអនុសញ្ញាវិសោធនកម្មនេះ តុលាការអាចរកដំណោះស្រាយជាមិត្តភាពមួយរវាងភាគីនៃរឿងក្តីក្រោមមាត្រា៣៨(១)(ខ) ប្រសិនបើតុលាការប្រកាសថារឿង

ក្ដីមួយអាចត្រូវបានទទួលយកមកដោះស្រាយបាន ។ ដំណោះស្រាយជាមិត្តភាពនេះត្រូវតែធានាឈរលើមូលដ្ឋាននៃ"ការគោរពសិទ្ធិមនុស្សដូចបានកំណត់ក្នុងអនុសញ្ញានិងពិធីសារបន្ថែម" ដោយដោះស្រាយតាមនីតិវិធីដែលធ្វើឡើងជាសម្ងាត់ ។

មុននឹងបញ្ជូនទៅឲ្យតុលាការ ដំណោះស្រាយជាមិត្តភាពនេះជាបន្ទុករបស់គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុបដែលធ្វើជាអាជ្ញាកណ្ដាលពីព្រោះ "ដើម្បីដោះស្រាយបញ្ហាមិនត្រឹមតែរវាងជនរងគ្រោះនិងភាគីរដ្ឋក្នុងជម្លោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោះស្រាយដោយគោរពតាមគោលការណ៍ដែលមានចែងក្នុងអនុសញ្ញា និងអត្ថប្រយោជន៍សាធារណៈ"ផង ។ រដ្ឋាភិបាលមួយចំនួនជាអ្នកផ្ដល់សំណងជាមិត្តភាពបើខ្លួនជាភាគីក្នុងជម្លោះ ។ ហេតុដូច្នេះ សំណងបែបនេះបង្ហាញឲ្យឃើញនូវ "ប្រព័ន្ធច្បាប់សិទ្ធិមនុស្សដែលអឺរ៉ុបទាំងមូលជួយបន្ថែមលើការផ្ដល់សំណងដល់ជនរងគ្រោះម្នាក់ៗ" ។ នៅពេលដែលសម្រេចបានសំណងជាមិត្តភាព "តុលាការត្រូវដកសំណុំរឿងក្ដីនេះចេញពីបញ្ជីរបស់ខ្លួនដោយធ្វើសេចក្ដីសម្រេចដែលមានបង្ហាញអំពីព័ត៌មានសង្ខេបលើអង្គហេតុនិងដំណោះស្រាយផង" ។ សេចក្ដីសម្រេចបែបនេះ រួមទាំងសាលក្រមរបស់តុលាការគឺមានអនុភាពស្របច្បាប់ដែលតម្រូវឲ្យភាគីក្នុងជម្លោះត្រូវគោរពតាម ហើយត្រូវបានបញ្ជូនទៅគណៈកម្មាធិការរដ្ឋមន្ត្រីសម្រាប់យកទៅអនុវត្ត ។

បញ្ហាសំខាន់ដែលជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សត្រូវចងចាំនោះគឺបណ្ដឹងរបស់ខ្លួនដែលដាក់ជូនតុលាការសិទ្ធិមនុស្សអឺរ៉ុបអាចទទួលយក ល្កុកណា"រាល់ការដោះស្រាយក្នុងស្រុកត្រូវបានធ្វើឡើងអស់ពីលទ្ធភាពរួចហើយម្យ៉ាងវិញទៀតអង្គហេតុនៅក្នុងបណ្ដឹងនេះមិនទាន់បានប្ដឹងឲ្យមានការស៊ើបអង្កេតជាអន្តជាតិដោយតុលាការផ្សេងទៀតឬឲ្យដោះស្រាយជាអន្តរជាតិដោយតុលាការផ្សេងនៅឡើយ ហើយបណ្ដឹងនោះមានព័ត៌មានថ្មីថែមទៀតផង" ។ ទាក់ទិននឹងសំណងដែលមានចែងក្នុងមាត្រា៤១ ដែលជាមាត្រា៥០ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុបពីមុន លោកស្រីសាស្ត្រាចារ្យ សែលតុន បានកត់សម្គាល់ឃើញថា ÷

"ជាអកុសលដើមចោទនិងមេធាវីដើមចោទមិនអាចជួយអ្វីបាននោះទេ នៅពេលស្នើសុំឲ្យមានការដោះស្រាយច្រើនផ្នែកដោយគ្មានការផ្ដល់ព័ត៌មានសង្ខេបអំពីអំណាចរបស់តុលាការឬមិនបានផ្ដល់នូវមូលហេតុសមរម្យឬអ្វីដែលយើងសំអាងលើក្នុងការប៉ាន់ប្រមាណលើការខូចខាតឬសំអាងផ្សេងទៀតដែលនឹងត្រូវផ្ដល់ជូន ។ ហេតុដូចនេះ តុលាការអាចដំណើរការកាត់ក្ដីរបស់ខ្លួនដោយពុំចាំបាច់មានជំនួយពីសំណាក់ជនទាំងនេះនៅចំពោះមុខតុលាការនោះ" ។

"សំណងជាការសុខចិត្តប្រកបដោយយុត្តិធម៌" ដែលជាទម្រង់មួយនៃសំណងការខូចខាតចំពោះជនរងគ្រោះដោយសារការរំលោភបំពានលើសិទ្ធិមនុស្ស នៃអនុសញ្ញាអឺរ៉ុបដែលបានធ្វើ ។ វិសោធនកម្មត្រូវបានតុលាការចាត់ទុកថា តាមដែនសមត្ថកិច្ចរបស់ខ្លួនចែងក្នុងមាត្រា៤១ ជាហេតុផលសម្រាប់ផ្ដល់ជាសំណងរូចខាតជាប្រាក់កាសនិងមិនមែនប្រាក់កាស ។ សំណងបែបនេះជួនកាលរាប់បញ្ចូលទាំងថ្លៃចំណាយផ្សេងៗនិងចំណាយលើជំនួយផ្នែកច្បាប់ទៀតផង ។ ករណីសំណងក្រោយនេះ ម្ចាស់បណ្ដឹងអាចទទួលបានពីក្រុមប្រឹក្សាអឺរ៉ុប ។

ចំពោះសំណួរដែលសួរថាតើតុលាការសិទ្ធិមនុស្សអឺរ៉ុបផ្អែកលើមូលដ្ឋានអ្វី ហើយដូចដែលលោកស្រីសាស្ត្រាចារ្យ សែលតុន បានចង្អុលបង្ហាញ យ៉ាងសមហេតុផលក្នុងសៀវភៅរបស់លោកស្រីដែលមានចំណងជើងថា "ដោះស្រាយសំណងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ" ដោយបានដកស្រង់ចេញពីយកសំណុំរឿងឈ្មោះ វ៉ាខ្វិនស៊ី ដែលអ្នកស្រីបានចាត់ទុកជាការវិនិច្ឆ័យលើកដំបូងលើ"សំណងជាការសុខចិត្តប្រកបដោយយុត្តិធម៌" តុលាការអឺរ៉ុបបានកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ផ្ដល់សំណងបែបនេះដូចខាងក្រោម ៖

(១) តុលាការអឺរ៉ុបត្រូវតែរកឲ្យបាននូវសេចក្ដីសម្រេចមួយឬវិធានការដែលចាត់ការរដ្ឋអំណាចនៃរដ្ឋហត្ថលេខីនៅក្នុងទំនាស់ដោយប្រៀបធៀបទៅនឹងកាតព្វកិច្ចដែលកើតចេញពីអនុសញ្ញាអឺរ៉ុប ។ (២) ត្រូវមានភាគីជាជនរងគ្រោះនៅក្នុងការខូចខាតជាសម្ភារឬខាងផ្លូវចិត្ត ។ (៣) ល្កុកណាតុលាការគិតថារឿងនេះជាការចាំបាច់ត្រូវតែផ្ដល់នូវសំណងខូចខាតប្រកបដោយយុត្តិធម៌ ។

មានហេតុផលច្បាស់លាស់ក្នុងការអះអាងថា ការផ្ដល់សំណងជំងឺចិត្តដល់ជនរងគ្រោះដោយការរំលោភលើសិទ្ធិមនុស្ស

ដែលមានចែងក្នុងអនុសញ្ញាការពារសិទ្ធិមនុស្សនិងសិទ្ធិសេរីភាពជាមូលដ្ឋានដូចដែលបានធ្វើវិសោធនកម្មក្នុងពិធីសារបន្ថែមទី១១ និងពិធីសារបន្ថែមជាច្រើនទៀត គឺអាស្រ័យលើអំណាចផ្តាច់មុខរបស់តុលាការ ដូចដែលអ្នកស្រីសាស្ត្រាចារ្យ សែលតុន បានកត់សម្គាល់នោះគឺថា "ពេលខ្លះតុលាការហាក់ដូចជាអនុវត្តនូវសំណងខូចខាតស្មានៗ ខណៈដែលក្នុងចំណាត់ការដទៃទៀតខ្លួនបានបដិសេធមិនផ្តល់សំណងដោយផ្អែកលើកង្វះភ័ស្តុតាងរវាងការបង្កខូចខាតនិងការរំលោភបំពាន" ។

## ១៣) ប្រព័ន្ធសិទ្ធិមនុស្សអន្តរអាមេរិក

ការជំរុញនិងការការពារសិទ្ធិមនុស្សបែបលោកខាងលិចតាមរយៈប្រព័ន្ធអន្តរអាមេរិកមានការវិវត្តន៍ចាប់តាំងពីការបង្កើតធម្មនុញ្ញនៃអង្គការឧបទ្វីបអាមេរិកឆ្នាំ១៩៤៨ ដែលត្រូវបានអនុម័តនៅឯសន្និសីទបូហ្គោតានៃឧបទ្វីបអាមេរិក ។

ក្នុងនោះ អង្គការឧបទ្វីបអាមេរិកបានអនុម័តលើសេចក្តីប្រកាសអាមេរិកស្តីអំពីសិទ្ធិនិងករណីយកិច្ចរបស់ពលរដ្ឋនៅខែឧសភា ឆ្នាំ១៩៤៨ និងអនុម័តលើអនុសញ្ញាអាមេរិកស្តីអំពីសិទ្ធិមនុស្ស (អនុសញ្ញាអាមេរិក) នៅខែវិច្ឆិកា ឆ្នាំ១៩៦៩ ។ លិខិតូបករណ៍ទាំងពីរមានសារៈសំខាន់បំផុតផ្នែកច្បាប់ក្នុងការគ្រប់គ្រងបញ្ហាសិទ្ធិមនុស្សនៅក្នុងតំបន់ ។ សេចក្តីប្រកាសអាមេរិកស្តីអំពីសិទ្ធិនិងករណីយកិច្ចរបស់ពលរដ្ឋមិនបង្កើតនូវកាតព្វកិច្ចខាងផ្លូវច្បាប់សម្រាប់ប្រទេសជាសមាជិកត្រូវតែអនុវត្តទេ ហេតុដូចនេះហើយទើបសេចក្តីប្រកាសនេះខ្វះនូវ "លក្ខណៈជាច្បាប់សារជាតិវិជ្ជមាន" ។ ចំណែកឯអនុសញ្ញាអាមេរិករួមជាមួយនឹងពិធីសារបន្ថែម បូនីសអៃរ ឆ្នាំ១៩៦៧នៃវិសោធនកម្មនៅទីក្រុង លើធម្មនុញ្ញអង្គការឧបទ្វីបអាមេរិកដែលចូលជាធរមាននៅឆ្នាំ១៩៧០ បង្កើតបានជាយន្តការបណ្តឹងជាបុគ្គលម្នាក់ៗដែលគេស្គាល់យ៉ាងច្បាស់ទាក់ទិននិងការរំលោភសិទ្ធិមនុស្សដែលកើតឡើងលើទឹកដីរដ្ឋជាសមាជិក ។

ក្រោយមកទៀត ការពិនិត្យលើការអនុវត្តន៍លិខិតឧបករណ៍សិទ្ធិមនុស្សនៅក្នុងប្រព័ន្ធអន្តរអាមេរិកត្រូវផ្តល់ឲ្យដល់ស្ថាប័នសំខាន់ពីរគឺគណៈកម្មការសិទ្ធិមនុស្សអន្តរអាមេរិកនិងតុលាការសិទ្ធិមនុស្សអន្តរអាមេរិក ។ គណៈកម្មការសិទ្ធិមនុស្សអន្តរអាមេរិក ត្រូវបានបង្កើតក្នុងឆ្នាំ១៩៥៩ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីការបរទេសនៃអង្គការឧបទ្វីអាមេរិកលើកទី៥ ។ គណៈកម្មការនេះមានមុខងារសំខាន់ក្នុងការដោះស្រាយបណ្តឹងផ្សេងៗ រៀបចំរបាយការណ៍ស្តីអំពីស្ថានភាពសិទ្ធិមនុស្សរបស់រដ្ឋជាសមាជិកនិងគ្រប់គ្រងសំណើវិធានការក្នុងការលើកកម្ពស់បង្កើនការគោរពសិទ្ធិមនុស្សនៅក្នុងតំបន់ ។ ដោយឡែកតុលាការអន្តរអាមេរិកអំពីសិទ្ធិមនុស្សត្រូវបានបង្កើតឡើងដោយអនុលោមតាមអនុសញ្ញាអាមេរិកស្តីអំពីសិទ្ធិមនុស្សដែលចូលជាធរមាននៅឆ្នាំ១៩៧៨ ហើយមានមុខងារក្នុងការអនុវត្តនិងបកស្រាយលើអនុសញ្ញាអាមេរិក ព្រមទាំងមានមុខងារអនុវត្តដែនយុត្តាធិការជម្លោះលើបណ្តឹងប្រឆាំងនឹងប្រទេសដែលទទួលស្គាល់ដែនសមត្ថកិច្ចរបស់តុលាការនិងលើការផ្តល់យោបល់ផ្សេងៗ ។

ទាក់ទិននឹងបញ្ហាសំណងចំពោះការរំលោភសិទ្ធិមនុស្ស នៅក្នុងបរិបទប្រព័ន្ធអន្តរអាមេរិក គឺជាដំណើរការអាចធ្វើឡើងបានអាស្រ័យលើសមត្ថកិច្ចឈប់គណៈកម្មការអន្តរអាមេរិកស្តីអំពីសិទ្ធិមនុស្ស បន្ទាប់ពីគណៈកម្មការនេះសម្រេចថាបណ្តឹងអាចទទួលយកបានហើយ ។ បន្ទាប់មកទៀត ដំណើរការរបស់គណៈកម្មការនេះអាចឈានទៅដល់ការសម្រេច ។ ស្ថិតក្នុងដំណាក់កាលលើអង្គសេចក្តីរវាងការយល់ព្រមទទួលយករឿងក្តី និងការសម្រេចលើអង្គសេចក្តីរបស់គណៈកម្មការនេះ ក្នុងនាមជាអាជ្ញាកណ្តាលនៃកិច្ចជំនួបគ្នា ដើម្បីជួយសម្រួលដល់កិច្ចព្រមព្រៀងលើដំណោះស្រាយមិត្តភាពរវាងភាគីជាប់ពាក់ព័ន្ធក្នុងបណ្តឹងនោះ ដែលអនុសញ្ញាអាមេរិកឲ្យអំណាចទៅគណៈកម្មការនេះធ្វើ ។

ក្នុងដំណាក់ដោះស្រាយជាមិត្តភាព ដោយផ្អែកលើការគោរពសិទ្ធិមនុស្សដែលមានចែងក្នុងអនុសញ្ញានេះ សំណងការខូចខាតដល់ជនរងគ្រោះអាចសម្រេចនូវដំណោះស្រាយប្រភេទនេះចំពោះការរំលោភសិទ្ធិដូចដែលបានពោលខាងលើក្នុងល័ក្ខខ័ណ្ឌដែលភាគីរដ្ឋ ដែលបានរំលោភបំពាននោះយល់ព្រមធ្វើដូច្នោះដោយសុខចិត្តទទួលយកការទាមទារសំណងពីជនរងគ្រោះ ។ លើសពីនេះទៀត ដំណោះស្រាយជាមិត្តភាពអាចធ្វើឡើងបានតែចំពោះបណ្តឹងប្រឆាំងនឹងភាគីរដ្ឋនៃអនុសញ្ញាប៉ុណ្ណោះ ។

តាមនីតិវិធីនៃគណៈកម្មការនេះ ហេតុផលមួយទៀតដើម្បីសម្រេចបានសំណងការខូចខាតនេះ គឺតាមរយៈសេចក្តីសម្រេច

និងអនុសាសន៍របស់គណៈកម្មការនៅក្នុងដំណាក់ការដែលគណៈកម្មការនេះធ្វើការពិចារណាអង្គសេចក្តីនៃបណ្តឹង ល្គឹកណាប្រសិនបើដំណោះស្រាយជាមិត្តភាពដែលបាននិយាយខាងលើមិនទាន់យល់ព្រមគ្នានៅឡើយ ។ ទាក់ទិននឹងការសម្រេចរបស់គណៈកម្មការលើ បញ្ហាសំណងការខូចខាត អ្នកស្រីសាស្ត្រាចារ្យ សែលតុន ដកស្រង់យកអំណះអំណាងចេញពីរឿងក្តីលេខ១១.១៨៧ ប្រឆាំង នឹងប្រទេសកូឡុំប៊ីដែលថា ៖

ជាធម្មតា គណៈកម្មការណែនាំថា ភាគីរដ្ឋដែលត្រូវបានរកឃើញថាបានរំលោភសិទ្ធិមនុស្ស ត្រូវសងសំណងជាប្រាក់កាក់ចំពោះជនរងគ្រោះឬថាក្នុងករណីស្លាប់ ឬបាត់ខ្លួនត្រូវសងសំណងជូនដល់សមាជិកគ្រួសារនៃជនរងគ្រោះ ។ គណៈកម្មការនេះបានបញ្ជាក់ទៀតថា នៅពេលដែលអនុសាសន៍នេះត្រូវបានធ្វើឡើងករណីយកិច្ចក្នុងការផ្តល់សំណងក្លាយទៅជាកាតព្វកិច្ចអន្តរជាតិខាងផ្លូវច្បាប់ដែលមិនអាចកំណត់ដោយច្បាប់ជាតិបានឡើយ ។

ជំហានមួយទៀត ដែលសំខាន់បំផុតក្នុងការស្វែងរកសំណងនៅក្នុងប្រព័ន្ធសិទ្ធិមនុស្សអន្តរអាមេរិក គឺប្តឹងទៅតុលាការសិទ្ធិមនុស្សអន្តរអាមេរិក ដោយអនុលោមតាមមាត្រាទី៦១ដល់៦៥ នៃអនុសញ្ញាអាមេរិក បន្ទាប់ពីបញ្ចប់នីតិវិធីទាំងឡាយនៅចំពោះមុខគណៈកម្មការអន្តរអាមេរិកស្តីអំពីសិទ្ធិមនុស្ស ។ ចូរចាំថាមានតែគណៈកម្មការ និងភាគីរដ្ឋជាសមាជិកនៃអនុសញ្ញាដែលទទួលស្គាល់នូវដែនសមត្ថកិច្ចរបស់តុលាការតែប៉ុណ្ណោះទើបអាចបញ្ជូនសំណុំរឿងទៅតុលាការនេះបាន ។ នៅចំពោះមុខតុលាការ គណៈកម្មការអន្តរអាមេរិកស្តីអំពីសិទ្ធិមនុស្សដើរតួនាទីក្នុងនាមជនរងគ្រោះពីព្រោះជនរងគ្រោះមិនអាចលើកឡើងអំពីដែនសមត្ថកិច្ចរបស់តុលាការបានទេ ក៏ប៉ុន្តែក្រោយពីមានវិសោធនកម្មវិធានរបស់តុលាការមកជនរងគ្រោះអាចចូលរួមក្នុងដំណាក់កាលនៃសំណងការខូចខាតក្នុងរឿងក្តីទីមួយ ។

តុលាការសិទ្ធិមនុស្សអន្តរអាមេរិក (តុលាការ) ត្រូវបានផ្តល់អំណាចក្នុងការផ្តល់សំណងការខូចខាតដល់ជនរងគ្រោះដោយសារការរំលោភបំពានសិទ្ធិមនុស្សនៃអនុសញ្ញាអាមេរិក និងឧបករណ៍ច្បាប់សិទ្ធិមនុស្សដទៃក្នុងប្រព័ន្ធច្បាប់អន្តរអាមេរិកដោយអនុលោមតាមមាត្រាទី៦៣(១) នៃអនុសញ្ញានេះ ។ មាត្រានេះចែងថា ÷

"បើសិនតុលាការរកឃើញថាមានការរំលោភបំពានលើសិទ្ធិ និងសេរីភាពដែលការពារដោយអនុសញ្ញានេះ តុលាការត្រូវតែសម្រេចថា ភាគីរងគ្រោះមានសិទ្ធិទទួលបាននូវការការពារយ៉ាងពេញទំហឹងនូវសិទ្ធិនិងសេរីភាពរបស់គាត់ដែលត្រូវបានរំលោភបំពាន ។ ប្រសិនបើចាំបាច់ តុលាការក៏ត្រូវសម្រេចថា ផលវិបាកនៃវិធានការឬស្ថានភាពដែលបង្កឲ្យមានការរំលោភបំពានលើសិទ្ធិ និងសេរីភាពបែបនេះត្រូវតែជួសជុលសងឡើងវិញ ហើយថាសំណងខូចខាតប្រកបដោយយុត្តិធម៌ត្រូវផ្តល់ជូនភាគីដែលរងគ្រោះ" ។

ទម្រាំតុលាការទទួលបានអំណាចដូចដែលឃើញក្នុងមាត្រាខាងលើក្នុងការដាក់បទបញ្ជាឲ្យមានសំណងការខូចខាតដល់ជនរងគ្រោះមានសំណើដែលពាក់ព័ន្ធជាច្រើន ធ្វើឡើងដោយរដ្ឋជាសមាជិកនៃអង្គការឧបទ្វីបអាមេរិកដូចជា ប្រទេសឈីលី ហ្កាតេម៉ាឡា និង អ៊ុយរ៉ាហ្កាយ ដោយរាប់បញ្ចូលទាំងគណៈកម្មាធិការនៃគណៈកម្មការអន្តរអាមេរិកត្រូវបានបង្ហាញឲ្យដឹងក្នុងពេលធ្វើសេចក្តីព្រៀងច្បាប់អនុសញ្ញានេះ ។

ដូចដែលលោកស្រីសាស្ត្រាចារ្យ សែលតុន វិភាគលើភាសាដែលប្រើប្រាស់ក្នុងមាត្រាខាងលើដែលថា "ភាសាចំៗនេះបង្ហាញពីអំណាចរបស់តុលាការក្នុងការចេញបទបញ្ជាឲ្យមានវិធានការជួសជុលសំណងខូចខាតជាងឲ្យមានសំណងជំងឺចិត្តជាប្រភេទអ្វីមួយ" ។ ក្នុងសំណេរមួយផ្នែករបស់ ចូ អេម ប៉ាសហ្កាលុស៊ី គាត់បានរកឃើញនូវប្រភពបន្ថែមទៀតថា"ក្រុមធ្វើសេចក្តីព្រៀងអនុសញ្ញាអាមេរិក មានបំណងលើកកម្ពស់ការការពារសិទ្ធិមនុស្សនៅក្នុងស្ថានភាពពិសេសរបស់លោកខាងលិច" ដែលអំណាចរបស់តុលាការដែលទាក់ទិននឹងរឿងនេះត្រូវបានរីកធំឡើង ។ យោងតាមអ្នកនិពន្ធទាំងពីរ សែលតុន និង ប៉ាសហ្កាលុស៊ី អំណាចរបស់តុលាការក្នុងការផ្តល់សំណងការខូចខាតដល់ជនរងគ្រោះដោយសារការរំលោភបំពានសិទ្ធិមនុស្សនៅក្នុងប្រព័ន្ធអន្តរអាមេរិកមានលក្ខណៈទូលាយជាងនៅក្នុងប្រព័ន្ធសិទ្ធិមនុស្សអឺរ៉ុប ។

គួរឲ្យជឿបានថាមានការសិក្សាយ៉ាងលំអិតលើសំណងសម្រាប់ជនរងគ្រោះដោយសារការរំលោភបំពានលើសិទ្ធិមនុស្សនៅក្នុងតុលាការសិទ្ធិមនុស្សអន្តរអាមេរិក ដូចដែលមាតិកាបង្ហាញស្រាប់ "សំណងជនរងគ្រោះក្នុងប្រព័ន្ធសិទ្ធិមនុស្សអន្តរអាមេរិក ៖ ការវាយ

តម្លៃយ៉ាងជិតដល់ លើការអនុវត្ត និងនីតិវិធីបច្ចុប្បន្ន” ដែលអាចឲ្យយើងមិនចាំបាច់សិក្សាបន្ថែមឡើយ ។ ក៏ប៉ុន្តែយោងតាមឯកសារដែលចែកជូនក្នុងថ្នាក់របស់លោកសាស្ត្រាចារ្យ ហ្សង់ មែនដេហ្ស អំពីការការពារសិទ្ធិមនុស្សតាមតំបន់សំណាងដែលមានចែងក្នុងមាត្រាទី៦៣(១) នៃអនុសញ្ញាអាមេរិកត្រូវបានសម្រេចក្នុងភាសាយ៉ាងច្បាស់លាស់ថា ÷

“តុលាការអន្តរអាមេរិកប្រកាសឲ្យមាត្រានេះក្លាយជាច្បាប់ទំនៀមទម្លាប់ ដែលច្បាប់នេះជាគោលការណ៍មូលដ្ឋានមួយនៃច្បាប់អន្តរជាតិ ។ កាតព្វកិច្ចឲ្យមានសំណង ត្រូវបានគ្រប់គ្រងដោយច្បាប់អន្តរជាតិក្នុងគ្រប់ទិដ្ឋភាព ដោយរាប់បញ្ចូលទាំងវិសាលភាព ចរិត លក្ខណៈ និងផលប្រយោជន៍ ហើយនិងមិនអាចកែប្រែឬព្យួរចោលដោយភាគីរដ្ឋតាមរយៈការលើកយកច្បាប់ក្នុងស្រុក ។

ជំហានចុងក្រោយ គឺសារសំខាន់អំពីថាតើសំណងនឹងត្រូវសម្រេចឲ្យដល់ជនរងគ្រោះតាមរបៀបណា ។ បញ្ហានេះគឺស្ថិតលើការពិនិត្យសម្រេចរបស់តុលាការ ។ ដូចមាននិយាយក្នុងរឿងក្តី វ៉ិឡាហ្គេស រ៉ូឌីហ្គេស (ការបំផ្លិចបំផ្លាញ សាលក្រមចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៨៩) “តុលាការត្រូវពិនិត្យការអនុវត្តការផ្តល់សំណងខូចខាតគ្រប់ដំណាក់កាលទាំងអស់ ។ រឿងក្តីនេះនឹងត្រូវបិទនៅពេលដែលរដ្ឋាភិបាលអនុវត្តយ៉ាងពេញលេញតាមសាលក្រមរបស់តុលាការ” ។ ជាងនេះទៀត ក្នុងរឿងក្តី អាឡូបូទូ (សាលក្រមចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៣) តុលាការចេញបទបញ្ជាឲ្យបង្កើតមូលនិធិមួយ និងសង្កត់ធ្ងន់លើការពិនិត្យការអនុវត្តតាមសាលក្រមដោយចែងថា “តុលាការត្រូវពិនិត្យមើលការអនុវត្តតាមសំណងខូចខាតដែលដាក់បញ្ជាដោយតុលាការមុនឈានដល់បញ្ចប់សំណុំរឿងក្តីនេះ” ។

### ១៣) ប្រព័ន្ធសិទ្ធិមនុស្សនៅអាហ្វ្រិក

ដោយទទួលស្គាល់ជាស្ថាប័ននៃអង្គការឯកភាពអាហ្វ្រិក គណៈកម្មការអាហ្វ្រិកស្តីអំពីមនុស្សជាតិ និងសិទ្ធិប្រជាជន ត្រូវបានបង្កើតឡើងតាមមាត្រា៣០នៃធម្មនុញ្ញអាហ្វ្រិកស្តីអំពីមនុស្សជាតិនិងសិទ្ធិប្រជាជន ដែលត្រូវបានអនុម័តក្នុងឆ្នាំ១៩៨១ ដោយអង្គការបង្កើតគោលនយោបាយសំខាន់នៃអង្គការឯកភាពអាហ្វ្រិក និងសភានៃប្រមុខរដ្ឋ និងរដ្ឋាភិបាល ។ គោលបំណងបង្កើតគណៈកម្មការអាហ្វ្រិកនេះ “គឺដើម្បីលើកខ្ពស់មនុស្សជាតិ និងសិទ្ធិប្រជាជន និងធានានូវការការពារសិទ្ធិក្នុងដែនដីអាហ្វ្រិក” ជាមួយនឹងភារកិច្ចយ៉ាងទូលំទូលាយ រួមមានការបកស្រាយខទាំងឡាយក្នុងធម្មនុញ្ញអាហ្វ្រិក និងបំពេញការងារផ្សេងៗដែលប្រគល់ឲ្យដោយសភានៃប្រមុខរដ្ឋនិងរដ្ឋាភិបាល ។ ដោយអនុវត្តតាមអំណាចរបស់ខ្លួនដែលមានចែងក្នុងធម្មនុញ្ញអាហ្វ្រិក គណៈកម្មការអាហ្វ្រិកអាចដោះស្រាយបណ្តឹងពីភាគី រដ្ឋជាសមាជិករបស់ធម្មនុញ្ញអាហ្វ្រិកប្រឆាំងនឹងភាគីរដ្ឋមួយទៀត ដែលបានបំពានលើខក្នុងធម្មនុញ្ញ ។ ក៏ប៉ុន្តែរហូតដល់ឆ្នាំ១៩៩៨ទើបបណ្តឹងបែបនេះបានដាក់ជូនគណៈកម្មការអាហ្វ្រិកដើម្បីដោះស្រាយ ។

បន្ថែមលើអំណាចនេះ គណៈកម្មការអាហ្វ្រិកដែលមានសមាជិក១១រូប ដែលត្រូវបានទទួលស្គាល់ថាមានសីលធម៌ខ្ពស់ សច្ចភាព ភាពមិនលម្អៀង និងសមត្ថភាពក្នុងបញ្ហាមនុស្សជាតិនិងសិទ្ធិប្រជាជនអាចទទួលយកបណ្តឹងពីបុគ្គល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមដទៃទៀត ដូចដែលបែងចែកយ៉ាងច្បាស់ក្នុងបណ្តឹងដោយធម្មនុញ្ញអាហ្វ្រិក ។ ក្នុងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ និងធានាដល់ការការពារមនុស្សជាតិនិងសិទ្ធិប្រជាជននៅក្នុងទ្វីបអាហ្វ្រិកទាំងមូល គណៈកម្មការអាហ្វ្រិកត្រូវបានធម្មនុញ្ញនេះអនុញ្ញាតឲ្យដកស្រង់គំនិតពីប្រភពផ្សេងៗនៅក្នុងលិខិតតូបករណ៍សិទ្ធិមនុស្សអន្តរជាតិ រួមទាំងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស និងលិខិតតូបករណ៍ដទៃៗទៀតដែលអនុម័តដោយអង្គការសហប្រជាជាតិ ។

ទាក់ទិននឹងបញ្ហាសំណងការខូចខាតក្នុងប្រព័ន្ធសិទ្ធិមនុស្សដែលមានវ័យក្មេងជាងគេ វាហាក់ដូចជាមិនបានផ្តល់នូវក្តីសង្ឃឹមច្រើនសោះ ដោយសារតែការខ្វះខាតលើខច្បាប់ដែលដោះស្រាយបញ្ហានេះ គឺថាមានតែកថាខណ្ឌមួយគត់ក្នុងមាត្រាទី២១ ចែងថា “ក្នុងករណីដកហូតទ្រព្យសម្បត្តិជាកម្មសិទ្ធិស្របច្បាប់ ជនដែលត្រូវបានគេដកហូតទ្រព្យសម្បត្តិនោះ មានសិទ្ធិទទួលបាននូវសំណងត្រឡប់មកវិញដោយពេញច្បាប់ ព្រមទាំងសំណងជំងឺចិត្តគ្រប់គ្រាន់ទៀតផង” ។ គឺរហូតដល់ខែមិថុនា ឆ្នាំ១៩៩៨ ដែលពិធីសារបន្ថែមលើធម្មនុញ្ញអាហ្វ្រិកស្តីអំពីមនុស្សជាតិនិងសិទ្ធិប្រជាជនបង្កើតឲ្យមានតុលាការអាហ្វ្រិកអំពីមនុស្សជាតិនិងសិទ្ធិប្រជាជន ដែន

តុលាការនេះមានសិទ្ធិអំណាចចេញបទបញ្ជាតាមការយល់ឃើញ ដើម្បីដោះស្រាយការរំលោភបំពាននានា ដោយរាប់បញ្ចូលទាំងការបង់ថ្លៃលើសំណងជំងឺចិត្តត្រឹមត្រូវ សំណងខូចខាតផ្សេងៗផង” ។ ដូច្នេះហើយ តុលាការថ្មីនេះនឹងបំពេញការងារក្នុងពេលឆាប់ៗ ក្រោយពីការអនុម័តឧបករណ៍ច្បាប់ទី១៥នៃពិធីសារបន្ថែមនេះ ដោយសហភាពកូម៉ូរូស ក្នុងការដោះស្រាយនូវបញ្ហាផ្សេងៗដែលដាក់ជូនដោយគណៈកម្មការដូចបានកំណត់សម្គាល់ខាងក្រោមនេះ ។

កន្លងមកយោងតាមមាត្រាទី ៧.១(ក) និង(ឃ) នៃធម្មនុញ្ញអាហ្វ្រិកគណៈកម្មការអាហ្វ្រិក មានសិទ្ធិសម្រេចលើបញ្ហាសំណងជូនម្ចាស់បណ្ដឹងដែលសិទ្ធិរបស់គាត់ត្រូវបានរំលោភបំពាននោះ ។ ដូចមានក្នុងរឿងក្ដីរបស់លោក អេមបា មេកុង ហ្គាល្លីស ដែលជាម្ចាស់បណ្ដឹងលើកឡើងអំពីសិទ្ធិកម្មសិទ្ធិលើដីធ្លី និងការរឹបអូសទ្រព្យសម្បត្តិប្រពន្ធរបស់ខ្លួន ដោយរដ្ឋអំណាចនៃប្រទេសកាមីរូន ប៉ុន្តែគណៈកម្មការអាហ្វ្រិកពុំបានសម្រេចលើរឿងក្ដី ដែលទាក់ទិននឹងបញ្ហាសំណងឡើយ ។ ផ្ទុយទៅវិញ គណៈកម្មការអាហ្វ្រិកសម្រេចចំពោះសំណងលើការខូចខាតដែលលោក មេកុងហ្គា ទទួលរងដោយការរំលោភបំពានសិទ្ធិដែលមាត្រានេះចែងថា ÷ “សិទ្ធិឲ្យអ្នកដទៃដឹងពីរឿងក្ដីរបស់ខ្លួន” (មាត្រាទី៧.១.ក) និង“សិទ្ធិទទួលបានការកាត់ទោសនៅក្នុងពេលវេលាដ៏សមគួរមួយ” (មាត្រាទី៧.១.ឃ) ។

ដោយសារតែ គណៈកម្មការអាហ្វ្រិកស្ដីអំពីមនុស្សជាតិនិងសិទ្ធិប្រជាជនទទួលបណ្ដឹងអំពីសំណងខូចខាតជាលើកទី១ ហើយចំពេលដែលតុលាការអាហ្វ្រិកពុំទាន់បង្កើតឡើងទៀតជាមិនបានបន្សល់ទុកប្រភពសម្រាប់យកធ្វើសំអាងនាពេលអនាគតឡើយ ។ លើសពីនេះទៀត ខុសពីប្រព័ន្ធច្បាប់សិទ្ធិមនុស្សអន្តរអាមេរិកនិងអឺរ៉ុប ដែលស្នើសុំឲ្យមានការអនុវត្តន៍តាមច្បាប់អន្តរជាតិ គណៈកម្មការអាហ្វ្រិកបានប្រគល់ឲ្យរដ្ឋអំណាចកាមីរ៉ូនមានសិទ្ធិសម្រេចលើតម្លៃនៃចំនួនសំណង បើទោះបីជាគណៈកម្មការអាហ្វ្រិក បានរកឃើញថា រដ្ឋាភិបាលកាមីរ៉ូនគ្មានឆន្ទៈដោះស្រាយរឿងក្ដីនេះក៏ដោយ ។

## សេចក្ដីសន្និដ្ឋាន

លិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិរបស់អង្គការសហប្រជាជាតិ មិនបានបញ្ជាក់ឲ្យច្បាស់នៅឡើយទេ ថាតើសំណងរបៀបណា និងប្រភេទណាដែលជនរងគ្រោះដោយសារការរំលោភបំពានលើសិទ្ធិមនុស្សអាចទទួលយកបាននោះ ។ លើសពីនេះទៀត បញ្ហាសំណង និងការសងជំងឺចិត្តសម្រាប់ជនរងគ្រោះ ដែលត្រូវបានសម្រេចជាចុងក្រោយតាមរយៈយន្តការច្បាប់អន្តរជាតិបានបន្សល់ចន្លោះប្រហោងឲ្យភាគីរដ្ឋដែលជាប់ចោទជ្រើសរើសយកវិធានការដោយខ្លួនឯងក្នុងការអនុវត្តសេចក្ដីសម្រេចដោយអនុលោមតាមច្បាប់ក្នុងស្រុកដែលតាមរយៈច្បាប់ក្នុងស្រុកហ្នឹងហើយដែលការរំលោភបំពានសិទ្ធិមនុស្សបានកើតឡើង ។

ខុសពីប្រព័ន្ធច្បាប់សិទ្ធិមនុស្សកម្រិតតំបន់អំពីសំណង និងការសងជំងឺចិត្តសម្រាប់ជនរងគ្រោះ តុលាការអន្តរអាមេរិក និងអឺរ៉ុបបែរជាស្នើឲ្យរដ្ឋជាសមាជិកអនុវត្តតាមច្បាប់អន្តរជាតិចំពោះការទទួលខុសត្រូវបែបនេះ និងជួនកាលតុលាការទាំងមិនព្រមអនុវត្តតាមច្បាប់ក្នុងស្រុកឡើយ ។ បើទោះបីជាគ្មានបទដ្ឋានវាយតម្លៃលើចំនួនដែលត្រូវសងនៅក្នុងប្រព័ន្ធច្បាប់កម្រិតតំបន់ក៏ដោយ ជនរងគ្រោះធ្លាប់ទទួលបានសំណងលើការខូចខាតនិងការសងជំងឺចិត្តដោយប្រយោលនិងដោយផ្ទាល់ ។

ផលវិបាកនៃសំណង និងការសងជំងឺចិត្តលើការរំលោភបំពានសិទ្ធិមនុស្សនឹងត្រូវធ្លាក់ទៅលើជនរងគ្រោះដោយសារតែរដ្ឋដែលរដ្ឋទាំងនោះនៅក្នុងតំបន់ដែលពុំមានយន្តការច្បាប់កម្រិតតំបន់ការពារសិទ្ធិមនុស្សសម្រាប់ជនរងគ្រោះ ។ នេះជាបញ្ហាហើយ បញ្ហានេះនៅតែបន្តរហូតដរាបណាមានការផ្ដល់ក្ដីសង្ឃឹមណាមួយត្រូវបានធ្វើឡើងនោះ ។ **(ចប់)**

**ម៉ាន់ថាន់ ពៅដារ៉ា**



ដូនជីទស្សនារណ្ដៅសាកសពរួមនៅវាលពិឃាតបឹងជើងឯក


កងទ័ពខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ

# ខែមេសា ឆ្នាំ១៩៧៥


ប្រជាជនត្រូវជម្លៀសចេញពីទីក្រុងទៅកាន់ទីជនបទ
និងត្រូវបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ


ក្រដាសប្រាក់និងទីផ្សារត្រូវបានលុបចំបាត់ចោល
គ្រប់ហេដ្ឋារចនាសម្ព័ន្ធសង្គមត្រូវបំផ្លាញ



ប្រជាជនជាង៥០០នាក់មកពីគ្រប់ខេត្តក្រុងទូទាំងប្រទេសចូលទស្សនាទីតាំងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា និងស្តាប់ការពន្យល់របស់មន្ត្រីអង្គជំនុំជម្រះវិសាមញ្ញ

# ខែមេសា ឆ្នាំ២០០៦



ដូនជីបង្សុកូលឧទ្ទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះ នៅវាលពិឃាតបឹងជើងឯក



ប្រជាជនទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (អតីតមន្ទីរសន្តិសុខស-២១)

# ១៧ មេសា : ថ្ងៃសោកសៅបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជា

សម្រាប់ប្រជាជនកម្ពុជា ខែមេសាគឺជាខែដ៏ពិសេសបំផុត ។ អំឡុងពេលនេះជាពេលដែលគ្រប់ក្រុមគ្រួសារជួបជុំគ្នាដើម្បីប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ។ ក៏ប៉ុន្តែ ខែមេសានៅក្នុងឆ្នាំ១៩៧៥ បែរជាមានអត្ថន័យផ្ទុយស្រឡះទៅវិញ ។ ជំនួសឲ្យការលេងល្បែងប្រជាប្រិយ ការសម្រាកពីការងារ និងការជួបជុំក្រុមគ្រួសារ ប្រជាជនកម្ពុជាបែរជាស្វែងរកកន្លែងលាក់ខ្លួនដើម្បីគេចពីគ្រាប់កាំភ្លើងរបស់ខ្មែរក្រហមដែលបើកការវាយប្រហារចុងក្រោយ រហូតដល់ដណ្ដើមបានរដ្ឋធានីភ្នំពេញ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពោលគឺឆ្នាំថ្មីទើបតែចាប់ផ្ដើមបានមួយថ្ងៃប៉ុណ្ណោះ ខ្មែរក្រហមដណ្ដើមបានអំណាចគ្រប់គ្រងលើប្រទេសកម្ពុជាទាំងមូល ។

គឺថ្ងៃនេះហើយដែលកងទ័ពរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរចុះចាញ់កងទ័ពខ្មែរក្រហម ហើយថ្ងៃនេះក៏ជាថ្ងៃដែរដែលកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ។ ប្រជាជនកម្ពុជាទាំងក្មេងចាស់ប្រុសស្រី សប្បាយរីករាយយ៉ាងខ្លាំង ព្រោះគិតថាខ្លួនត្រូវបានរំដោះ ប្រទេសកម្ពុជាប្រាកដជាលែងមានសង្គ្រាមទៀតហើយ ។ ប្រជាជនស្វាគមន៍កងទ័ពខ្មែរក្រហមដោយទះដៃនិងស្រែកជយឃោសយ៉ាងកងរំពង ។

ក៏ប៉ុន្តែ ភាពសប្បាយរីករាយនេះបានរលត់ទៅវិញយ៉ាងឆាប់រហ័ស ។ តែប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីចូលមកដល់ទីក្រុងភ្នំពេញ ខ្មែរក្រហមបានបញ្ជាឲ្យជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងឲ្យទៅធ្វើស្រែចម្ការនៅទីជនបទ ។ ខ្មែរក្រហមបានចាត់ទុកថ្ងៃ១៧ មេសា ថាជាថ្ងៃដែលខ្លួនទទួលបានជោគជ័យលើចក្រពត្តិអាមេរិក ជាថ្ងៃដែលប្រទេសកម្ពុជាទទួលបានឯករាជ្យ និងជាថ្ងៃបុណ្យជាតិសំខាន់បំផុត ។ ផ្ទុយទៅវិញ ខ្មែរក្រហមបែរជាយកពាក្យ "១៧មេសា" មកដាក់ប្រើប្រាស់ដើម្បីហៅប្រជាជនជម្លៀសដែលជាទូទៅបានទទួលរងគ្រោះធ្ងន់ធ្ងរជាងប្រជាជនមូលដ្ឋាន ថែមទាំងកំណត់ប្រជាជន១៧មេសានេះថាជាសត្រូវរបស់បដិវត្តន៍ទៀតផង ។

ខ្មែរក្រហមចង់បង្កើតសង្គមកុម្មុយនិស្តជឿនលឿនមួយដែលគ្មានអ្នកមានគ្មានអ្នកក្រ គ្មានវណ្ណៈជិះជាន់ គ្មានវណ្ណៈដែលត្រូវគេជិះជាន់ ក៏ប៉ុន្តែនៅចុងបញ្ចប់នៃរបបនេះ ប្រទេសកម្ពុជាមានសុទ្ធតែអ្នកក្រដែលទទួលរងនូវការជិះជាន់ធ្វើបាបពីសំណាក់មនុស្សមួយក្រុមតូច ។ ប្រជាជនប្រមាណ២៥ភាគរយនៃប្រជាជនទាំងអស់បានបាត់បង់ជីវិត ប្រទេសកម្ពុជានៅពេលនោះមាននៅសល់រចនាសម្ព័ន្ធតិចតួចប៉ុណ្ណោះ ហើយសេដ្ឋកិច្ចរបស់ប្រទេសត្រូវខ្ទេចខ្ទាំទាំងស្រុង ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៩ ព្រឹត្តិការណ៍ដ៏សោកសៅមួយទៀតបានកើតឡើងនោះ គឺពិធីបើកជាផ្លូវការនូវសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ទួលស្លែងជាមន្ទីរឃុំឃាំងសម្ងាត់របស់ខ្មែរក្រហមដែលមានមនុស្សប្រមាណមួយម៉ឺនបួនពាន់នាក់បាត់បង់ជីវិតនៅទីនេះ ។ ថ្ងៃនោះជាលើកទីមួយដែលសាធារណជនបានចូលមើលអ្វីដែលបដិវត្តន៍ខ្មែរក្រហមសម្រេចបាន ។

ពីរថ្ងៃមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៨ ប៉ុល ពត ដែលជាមេដឹកនាំកំពូលរបស់របបកម្ពុជាប្រជាធិបតេយ្យបានស្លាប់នៅព្រំដែនថៃដោយមិនទាន់បានទទួលការកាត់ទោសតាមផ្លូវច្បាប់នៅឡើយ ។ "បានតិចតួចប្រសើរជាងមិនបានសោះ" គឺជាអ្វីដែលប្រជាជនកម្ពុជាភាគច្រើនបានគិតនៅពេលនោះ ។ បើទោះបីជា "បងធំទី១" បានបាត់បង់ជីវិតទៅហើយក៏ដោយ ក៏អ្នកកាន់តំណែងខ្ពស់បន្ទាប់ៗជាច្រើននាក់កំពុងតែមានជីវិតនៅឡើយ ហើយអ្នកទាំងនោះត្រូវតែទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅថ្ងៃដដែលនេះ ពោលគឺ២៧ឆ្នាំបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ មេដឹកនាំខ្មែរក្រហមទាំងអស់នៅតែរស់នៅក្នុងសភាពនិទណ្ឌភាពនៅឡើយ ។ បើទោះបីជាយឺតបន្តិចក៏ដោយ ក៏នៅតែមានពេលវេលាសេសសល់ដើម្បីនាំយកមេដឹកនាំទាំងនោះទៅប្រឈមមុខនឹងយុត្តិធម៌និងដើម្បីលើកកម្ពស់នីតិរដ្ឋនៅកម្ពុជា

ដែរ ។ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាកំពុងតែស្ថិតនៅក្នុងដំណាក់កាលរៀបចំសាលាជំនុំជម្រះក្តីមួយដើម្បីបញ្ចប់និទណ្ឌភាពនេះ ។ បើទោះបីជាមេដឹកនាំខ្មែរក្រហមដូចជា នួន ជា ជាដើម បាននិយាយថា ខ្លួនស្ម័គ្រចិត្តប្រឈមមុខនៅក្នុងតុលាការក៏ដោយ ក៏មេដឹកនាំខ្មែរក្រហមទាំងនោះភាគច្រើនមានវ័យ៧០ ឬ៨០ឆ្នាំទៅហើយ និងកំពុងតែញាំញីដោយជំងឺទៀតផង ។ យើងមិនប្រាកដថាតើមេដឹកនាំខ្មែរក្រហមទាំងនោះអាចរស់រហូតដល់ដើមឆ្នាំ២០០៧ជាពេលដែលសវនាការដំបូងចាប់ផ្តើមដំណើរការឬក៏អត់ទេ ។

ការស្លាប់របស់ ស្លូបូដាន មីឡូសេវិក ក្នុងអាយុ៦៤ឆ្នាំ នៅពេលថ្មីៗនេះ បានបង្ហាញឲ្យឃើញពីភាពបន្ទាន់មួយក្នុងការចាត់វិធានការនាំយកមេដឹកនាំខ្មែរក្រហមដែលនៅរស់ទៅប្រឈមមុខនឹងយុត្តិធម៌ ។ ប្រសិនបើវិធានការនេះមិនត្រូវបានធ្វើឡើងជាបន្ទាន់ទេ ប្រជាជនកម្ពុជានឹងបាត់បង់ឱកាសជារៀងរហូតក្នុងការស្តាប់ការពន្យល់របស់មេដឹកនាំខ្មែរក្រហមទាំងនោះនៅក្នុងតុលាការអំពីមូលហេតុដែលធ្វើឲ្យប្រជាជនកម្ពុជាជាច្រើននាក់បាត់បង់ជីវិត ។

**ឌី ខេមរិទ្ធិ**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

“ការិយាល័យព័ត៌មានសាធារណៈ” មានផ្តល់ជូននូវសេវា៤យ៉ាង ÷

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អែម សុខឃីម តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា

**(តចប់)**

### ក) ព្រះពុទ្ធសាសនានិងការផ្សះផ្សាបង្រួបបង្រួមជាតិ

មុនពេលព្រះពុទ្ធយាងទៅសាងផ្នួសដើម្បីស្វែងយល់អំពីព្រះធម៌ ព្រះអង្គមានឱកាសត្រេកត្រអាលនឹងគ្រឿងអបាយមុខជាច្រើនប្រភេទ ប៉ុន្តែព្រះអង្គពុំដែលទទួលបានសេចក្តីសុខអំពីការសប្បាយនោះឡើយ ។ ក្នុងរយៈពេលសាងផ្នួសនៅក្នុងព្រៃ ព្រះអង្គបានធ្វើទុក្ករកិរិយាបង្អត់អាហារខ្លួនឯងជាច្រើនថ្ងៃ ។ ពេលនោះព្រះអង្គមិនត្រឹមតែមិនបានទទួលសេចក្តីសុខប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្លាក់ខ្លួនមានជំងឺនិងឈឺចាប់វេទនាថែមទៀត ។ ទីបំផុតព្រះអង្គស្វែងយល់ថា សេចក្តីសប្បាយនិងសេចក្តីលំបាកដ៏ជ្រុលហួសហេតុពុំមែនជាផ្លូវទៅរកសេចក្តីសុខរបស់មនុស្សលោកឡើយ ។ សម្តេចព្រះមហាឃោសានន្ទ បានបកស្រាយថា ÷

*ផ្លូវកណ្តាលគឺជាផ្លូវឆ្ពោះទៅរកសេចក្តីសុខពិតប្រាកដ ។ ផ្លូវកណ្តាលមានលក្ខណៈនឹងនរ មិនតឹងនិងមិនធូរជ្រុល ។ ការធ្វើដំណើរតាមផ្លូវកណ្តាលតែងតែមានសុវត្ថិភាពនិងងាយស្រួល ហើយរមែងមានសេចក្តីសុខជានិច្ច ។*

ប្រជាជនកម្ពុជានិយមប្រើប្រាស់ផ្លូវកណ្តាលដើម្បីដោះស្រាយបញ្ហា ។ សម្តេចព្រះមហាសុមេធាធិបតី ទេព វង្ស ព្រះសង្ឃរាជគណៈមហានិកាយមានសង្ឃដីកាបញ្ជាក់ថា ការប្រើប្រាស់វិធីសាស្ត្រកណ្តាលសម្រាប់ដោះស្រាយជម្លោះអាចបញ្ចប់ការគុំគួនគ្នាបាន ។ ព្រះភិក្ខុ យស់ ហ៊ុត ខេមចារោ រំឭកអំពីរឿងព្រេងខ្មែរដែលទាក់ទងដល់ការប្រើប្រាស់ផ្លូវកណ្តាលថា "ព្រះពុទ្ធបានប្រើប្រាស់ផ្លូវកណ្តាលដើម្បីដោះស្រាយជាមួយសត្រូវរបស់ទ្រង់ (នៅក្នុងរឿងព្រះវេស្សន្តរ) ។ កាលនោះព្រះអង្គមិនបានសម្លាប់សត្រូវរបស់ព្រះអង្គឡើយ ប៉ុន្តែបាននិរទេសព្រះកាយទៅទីឆ្ងាយ ។ ព្រះភិក្ខុ យស់ ហ៊ុត សំណូមពរចំពោះរដ្ឋាភិបាលកម្ពុជាឲ្យប្រើប្រាស់វិធីកណ្តាលដើម្បីដោះស្រាយជាមួយមេដឹកនាំខ្មែរក្រហម ។ ព្រះភិក្ខុបន្ថែមថា ការយកវិធីកណ្តាលមកដោះស្រាយអាចធ្វើឲ្យប្រទេសជាតិមានសេចក្តីសុខ ហើយប្រជាជនអាចរស់នៅក្នុងសន្តិភាពយូរអង្វែង ។

### ខ) គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជា

មានអង្គការក្រៅរដ្ឋាភិបាលនិងមជ្ឈមណ្ឌលជាច្រើនបាននិងកំពុងបំពេញការងារជំរុញឲ្យមានការផ្សះផ្សានិងបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជា ប៉ុន្តែមជ្ឈមណ្ឌលដែលលេចធ្លោក្នុងការស្វែងរកការពិត ការអប់រំ ហើយដែលអាចធ្វើការងារបានទាំងជាមួយគណៈកម្មការស្វែងរកការពិតនិងគោលគំនិតផ្លូវកណ្តាលរបស់ព្រះពុទ្ធគឺ មជ្ឈមណ្ឌលឯកសារកម្ពុជា ។

គម្រោងការងារនិងកម្មវិធីជាច្រើនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមមានកម្មវិធីស្វែងរកគ្រួសារ ទស្សនាវដ្តី ការសិក្សាស្រាវជ្រាវ ការថែរក្សាឯកសារ សុទ្ធតែដើរតួយ៉ាងសំខាន់ក្នុងការជួយប្រជាជនកម្ពុជាឲ្យមានការយល់ដឹងអំពីហេតុការណ៍ដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម ហើយបានជួយប្រជាជនឲ្យស្ងប់អារម្មណ៍បន្ទាប់ពីបានដឹងអំពីការពិត ។ ឧទាហរណ៍ កម្មវិធីស្វែងរកគ្រួសារអាចជួយផ្តល់ព័ត៌មានដល់បងប្អូនកូនចៅឲ្យបានដឹងអំពីហេតុការណ៍និងមូលហេតុផ្សេងៗទៀតដែលកើតឡើងចំពោះឪពុកម្តាយរបស់ខ្លួន ។ តាមរយៈទស្សនាវដ្តី ប្រជាជនកម្ពុជាបានយល់ដឹងអំពីព្រឹត្តិការណ៍ជាច្រើននៅក្នុងរបបខ្មែរក្រហម ។ លើសពីនេះទៀតទស្សនាវដ្តីក៏បានបំពេញតួនាទីជាអ្នកនាំសារដោយបាននាំពាក្យសុំទោសពីជនដៃដល់ទៅជនរងគ្រោះនិងពីកន្លែងមួយទៅកន្លែងមួយទៀតជុំវិញប្រទេស ។ ពីមួយថ្ងៃទៅមួយថ្ងៃ ការពិតបានធ្វើឲ្យជនរងគ្រោះរសាយចិត្ត យល់ព្រមអធ្យាស្រ័យនិងអត់ឱនឲ្យជនដៃដល់ថ្នាក់ក្រោមដែលរស់នៅក្នុងភូមិស្រុកជាមួយខ្លួន ។ ការងារនិងទិសដៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអាចមើលឃើញច្បាស់តាមរយៈចំណងជើងរបស់ទស្សនាវដ្តី "ស្វែងរកការពិត" ។ វិធីសាស្ត្រស្រាវជ្រាវរបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជាការធ្វើដំណើរទៅកាន់គ្រប់ទិសទីទូទាំងប្រទេសដើម្បីជួបសម្ភាសជាមួយប្រជាជនហើយផ្សព្វផ្សាយតាមរយៈទស្សនាវដ្តី គឺជាវិធីសាស្ត្រផ្លូវកណ្តាលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាជ្រើសរើស ។

ជាក់ស្តែង មជ្ឈមណ្ឌលឯកសារកម្ពុជាមានចំណុចបីខុសពីគណៈកម្មការស្វែងរកការពិត ។ ទីមួយ ៖ គណៈកម្មការស្វែងរកការពិតមានលក្ខណៈបណ្តោះអាសន្ន ប៉ុន្តែមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងរៀបចំខ្លួនទៅជាវិទ្យាស្ថានអចិន្ត្រៃយ៍ ។ ទីពីរ ៖ ជាទូទៅគណៈកម្មការស្វែងរកការពិតគឺជាភ្នាក់ងារសាធារណៈ និងមានលក្ខណៈផ្លូវការ ផ្ទុយទៅវិញមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាអង្គការក្រៅរដ្ឋាភិបាល ។ ទីបី ៖ គណៈកម្មការស្វែងរកការពិតដូចករណីនៅប្រទេសអាហ្វ្រិកខាងត្បូងមានសិទ្ធិបញ្ជូនឧក្រិដ្ឋជនដែលមិនព្រមសារភាពការពិតទៅឲ្យតុលាការដើម្បីកាត់ទោស ប៉ុន្តែមជ្ឈមណ្ឌលឯកសារកម្ពុជាពុំមានអំណាចធ្វើបែបនេះឡើយ ។



ហាកិម ភួន ទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (អតីតមន្ទីរសន្តិសុខស-២១)

នៅពេលដែលមានសំណួរថា ប្រជាជនកម្ពុជាមួយចំនួនជាអនក្ខរជនឬចេះអក្សរបន្តិចបន្តួច តើប្រជាជនទាំងនោះមិនមែនជាជនរងគ្រោះនៃរបបខ្មែរក្រហមទេឬ? តើប្រជាជនទាំងនោះមិនចាំបាច់សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាទេឬ? គួរតែពិចារណាកត្តានេះ ហើយវិទ្យុអាចជាមធ្យោបាយជួយសម្រួលនិងដោះស្រាយបញ្ហានេះបាន ។ វិទ្យុផ្សព្វផ្សាយការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជូនដល់ប្រជាជនដែលមិនចេះអានអក្សរ ។ ប៉ុន្តែសំណួរសួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានលទ្ធភាពធ្វើការងារនិងបានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុយូរអង្វែងប៉ុនណា? តើមជ្ឈមណ្ឌលឯកសារកម្ពុជាអាចពង្រីកការបោះពុម្ពនិងបន្ថែមកម្មវិធីផ្សាយតាមវិទ្យុបានទូលំទូលាយយ៉ាងណា? តើនរណាជាអ្នកឧបត្ថម្ភហិរញ្ញវត្ថុឲ្យចុងក្រោយ? តើរាជរដ្ឋាភិបាលកម្ពុជាមានសុឆន្ទៈអនុវត្តតាមសំណើរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

តាមរយៈការពិភាក្សាខាងលើ ខ្ញុំជឿថា មជ្ឈមណ្ឌលឯកសារកម្ពុជាអាចក្លាយទៅជាគណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជា ។ វគ្គបន្ទាប់នេះនឹងសិក្សាអំពីប្រតិបត្តិការរបស់គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជា និងអត្ថប្រយោជន៍របស់គណៈកម្មការនេះក្នុងការផ្សះផ្សាបង្រួបបង្រួមជាតិ ។

### ក) ប្រតិបត្តិការរបស់គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជា

គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជាត្រូវតែបង្កើតឡើងឲ្យបានឆាប់រហ័ស ហើយធ្វើប្រតិបត្តិការបំពេញបន្ថែមរាល់ចំណុចខ្វះខាតរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ គណៈកម្មការនេះគួរតែបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា គ្រប់គ្រងដោយបុគ្គលិកកម្ពុជា និងមានការជួយឧបត្ថម្ភផ្នែកថវិកាពីអង្គការសហប្រជាជាតិ ។ កត្តាទាំងអស់ ជាពិសេសពេលវេលា ថវិកា និងទីតាំងមានសារសំខាន់ជួយឲ្យការងាររបស់គណៈកម្មការលឿនទៅមុខនិងមានប្រសិទ្ធភាពខ្ពស់ ។

ឧក្រិដ្ឋជនដែលយល់ព្រមរៀបរាប់ការពិត សារភាពទោសកំហុសរបស់ខ្លួន ហើយសុំការលើកលែងទោសគួរតែទទួលបាននូវការលើកលែងទោស ។ ការអធ្យាស្រ័យចំពោះឧក្រិដ្ឋជនអាចធ្វើឲ្យប្រជាជនដឹងអំពីការពិតនិងបានរសាយចិត្ត ។ លើសពីនេះទៀត វិធីនេះសមស្របនឹងពុទ្ធឱវាទមួយឃ្លាថែងថា "ពៀររំងាប់ដោយការមិនចងពៀរ" ដែលមានន័យអប់រំឲ្យមានការអធ្យាស្រ័យនិងអត់ឱនឲ្យគ្នាទៅវិញទៅមក ។

### ឃ) អត្ថប្រយោជន៍របស់គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជា

គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជាត្រូវប្រឈមមុខនឹងការលំបាកជាច្រើន ប៉ុន្តែគណៈកម្មការនេះក៏ផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់សង្គមកម្ពុជាដែរ ។ ទីមួយ ៖ គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជាអាចជួយផ្តល់ការ

ពិត និងកសាងមេរៀនប្រវត្តិសាស្ត្រសម្រាប់យុវវ័យជំនាន់ក្រោយ ។ ទីពីរ ៖ ការយល់ដឹងអំពីការពិតអាចធ្វើឲ្យប្រជាជនយល់ព្រមអត់ឱននិងអធ្យាស្រ័យដល់ជនដែលល់ខ្មែរក្រហមថ្នាក់ក្រោមនិងមានលទ្ធភាពផ្សះផ្សាបង្រួបបង្រួមគ្នាឡើងវិញ ។ ទីបី ៖ គណៈកម្មការស្វែងរកការពិតប្រើប្រាស់ផ្លូវកណ្តាលដែលមានលក្ខណៈសមស្របតាមឱវាទរបស់ព្រះពុទ្ធ អាចជួយឲ្យប្រជាជនចូលរួមនៅក្នុងដំណើរការរបស់គណៈកម្មការ ហើយជួយជំរុញឲ្យប្រជាជនមានសេចក្តីក្លាហានក្នុងការដោះស្រាយជម្លោះដោយខ្លួនឯងនៅថ្ងៃអនាគត ។

ដំណើរការរបស់គណៈកម្មការស្វែងរកការពិតអាចធ្វើឲ្យប្រជាជនដឹងច្បាស់អំពីមូលហេតុដែលនាំឲ្យមានការកាប់សម្លាប់ ។ ការដឹងអំពីមូលហេតុគឺជាឱសថជួយព្យាបាលជំងឺផ្លូវចិត្តរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ។ ម្យ៉ាងទៀត ការដឹងអំពីមូលហេតុនៃការសម្លាប់ក៏មានប្រយោជន៍ចូលរួមទប់ស្កាត់មិនឲ្យអំពើនេះកើតឡើងជាថ្មីម្តងទៀត ។

អត្ថប្រយោជន៍មួយទៀតរបស់គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជាគឺជួយបញ្ចប់ភាពសោកសៅរបស់ប្រជាជននិងបិទប្រវត្តិសាស្ត្រដ៏ជូរចត់ពីអតីតកាល ។ ការបញ្ចប់ការឈឺចាប់និងការបិទទំព័រប្រវត្តិសាស្ត្រនេះកើតឡើងតាមរយៈការទទួលស្គាល់ការឈឺចាប់របស់ជនរងគ្រោះ និងការសុំទោសជាផ្លូវការពីសំណាក់ឧក្រិដ្ឋជន ។ ការរៀបរាប់ការពិតនិងការសុំអភ័យទោសអាចជំរុញឲ្យជនរងគ្រោះនិងជនដែលល់ថ្នាក់ក្រោមយល់ព្រមរស់នៅក្នុងភូមិស្រុកជាមួយគ្នាដោយសន្តិភាព ។ ផ្ទុយទៅវិញ ការមិនទទួលស្គាល់ឬបដិសេធការឈឺចាប់របស់ជនរងគ្រោះអាចបន្តឲ្យមានការគុំគួននិងការសងសឹកគ្នាមិនចេះចប់មិនចេះហើយ ។

ទោះបីជាគណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជាអាចជួយបំពេញកង្វះខាតរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជាក៏ដោយ ក៏ដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនេះត្រូវការចាំបាច់នូវកិច្ចសហការរបស់រដ្ឋាភិបាល សហគមន៍អន្តរជាតិនិងការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ក៏ដូចជាមហាជនទូទៅ លើកម្មវិធីទ្រទ្រង់ផ្សេងៗទៀតដែរ ។ កម្មវិធីទ្រទ្រង់ទាំងនោះរួមមាន ÷

### ឃ១) ផ្តល់ការអប់រំដល់សាធារណជន

ការអប់រំដល់យុវវ័យជំនាន់ក្រោយអំពីមូលហេតុដែលនាំឲ្យមានការកាប់សម្លាប់គឺជាប្រធានបទសំខាន់បំផុតដើម្បីទប់ស្កាត់ការកើតមានជាថ្មីនូវអំពើបែបនេះទៀត ។ ជាមួយគ្នានេះដែរ យុវវ័យជំនាន់ក្រោយក៏ត្រូវការចាំបាច់នូវចំណេះដឹងអំពីការផ្សះផ្សាបង្រួបបង្រួមជាតិនិងការយល់អធ្យាស្រ័យដែរ ។ សាស្ត្រាចារ្យ អេនឌ្រូ រីដប៊ី បានពន្យល់ថា មូលហេតុដែលនាំឲ្យមានអំពើហិង្សា ការកាប់សម្លាប់និងការសងសឹកដែលមានពីជំនាន់មួយទៅជំនាន់មួយមានឫសគល់មកពីជីវភាពប្រចាំថ្ងៃ ហើយវាឆ្លងទៅជំនាន់មួយទៀតតាមរយៈផ្ទះសម្បែង សាលារៀន និងការិយាល័យ ។ សាស្ត្រាចារ្យ រីដប៊ី បន្ថែមទៀតថា ÷



ជុំ ម៉ី អតីតអ្នកទោសនៅមន្ទីរស-២១ កំពុងសាកសួរឯកឧត្តម ស៊ាន វិសុទ្ធ អំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម

ដើម្បីទប់ស្កាត់ការរីករាលដាលនូវអំពើទាំងនេះ ចាំបាច់ត្រូវតែមានការអប់រំដើម្បីជុសខាត់គំនិតឲ្យមានការអធ្យាស្រ័យ និងផ្សះផ្សាបង្រួបបង្រួមនៅគ្រប់ទីកន្លែងទាំងអស់ ។ ការអប់រំកុមារឲ្យមានអត្តចរិតល្អចេះយោគយល់អត់ឱនឲ្យគ្នាគឺជាមូលដ្ឋានគ្រឹះដែលអាចកសាងសង្គមឲ្យមានការផ្សះផ្សាបង្រួបបង្រួមជាតិមានសន្តិភាពនិងភាពរីកចម្រើនជឿនលឿន ។

### ឃ២) សុខភាពផ្លូវចិត្ត

បច្ចុប្បន្ននេះមានការសិក្សាស្រាវជ្រាវតិចតួចបំផុតអំពីបញ្ហាសុខភាពផ្លូវចិត្តរបស់ប្រជាជនកម្ពុជាដែលប៉ះពាល់ដោយសារសង្គ្រាមនិងការកាប់សម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បញ្ហាសុខភាពផ្លូវចិត្តគឺជាការសំខាន់ដែលទាមទារការសិក្សាស្រាវជ្រាវនិងស្វែងរកដំណោះស្រាយឲ្យបានសមស្រប ។

### ឃ៣) បង្កើតកម្មវិធីសមាហរណកម្ម

កម្មវិធីសមាហរណកម្មនិងកម្មវិធីទ្រទ្រង់ជនរងគ្រោះនៃរបបខ្មែរក្រហមអាចជួយឲ្យប្រជាជនរស់នៅក្នុងសន្តិភាព ។ ការទម្លាក់អាវុធធ្វើសមាហរណកម្មកម្លាំងខ្មែរក្រហមជួយធ្វើឲ្យប្រជាជនគ្មានការរើសអើងថាអ្នកនេះជាខ្មែរក្រហមឬជាជនដែលធ្លាប់ជាជនរងគ្រោះ ពីព្រោះប្រជាជនគ្រប់រូបបានវិលមករួមរស់ជាមួយគ្នា មានឱកាសធ្វើការរួមគ្នា និងទទួលបានការយកចិត្តទុកដាក់ដូចៗគ្នា ។

### ឃ៤) បង្កើតគម្រោងការងាររួមគ្នា

ការបង្កើតឱកាសឲ្យប្រជាជនដែលរស់នៅក្នុងទឹកដីកាន់កាប់ដោយខ្មែរក្រហមនិងប្រជាជនដែលរស់នៅក្រោមការកាន់កាប់ដោយរដ្ឋាភិបាលបានធ្វើការរួមគ្នា អាចជួយធ្វើឲ្យប្រជាជនទាំងនោះកាន់តែយល់អំពីគ្នា ចេះស្រលាញ់គ្នា និងមានជំនឿចិត្តលើគ្នាទៅវិញទៅមក ។

### ឃ៥) ការវិភាគប្រវត្តិសាស្ត្រ

បច្ចុប្បន្ននេះមានសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជាតិចតួចប៉ុណ្ណោះដែលសរសេរឡើងដោយប្រជាជនកម្ពុជា ។ សៀវភៅភាគច្រើនសរសេរដោយជនបរទេស ។ គួរតែជំរុញនិងលើកទឹកចិត្តឲ្យមានការស្រាវជ្រាវប្រវត្តិសាស្ត្រ ការសរសេររឿងរ៉ាវផ្ទាល់ខ្លួន និងការតាំងបង្ហាញរូបថតនិងវត្ថុសិល្បៈជាប្រវត្តិសាស្ត្រ ឲ្យបានខ្លាំងក្លាថែមទៀត ។ ការនិពន្ធនិងស្រាវជ្រាវទាំងនេះគឺដើម្បីអប់រំនិងទុកជាមេរៀនរក្សាសម្រាប់មនុស្សជំនាន់ក្រោយ ។

### ឃ៦) ថែរក្សាសន្តិភាព

ការថែរក្សាសន្តិភាពជាកាតព្វកិច្ចរបស់រដ្ឋាភិបាល ។ ការថែរក្សាសន្តិភាព ការគោរពសិទ្ធិមនុស្ស និងអប់រំអំពីមធ្យោបាយដោះស្រាយជម្លោះដោយសន្តិវិធី គឺជាសញ្ញាបញ្ជាក់ថារដ្ឋាភិបាលបានប្រឹងប្រែងរក្សាសេចក្តីសុខដូនប្រជាជន ហើយអំពើកាប់សម្លាប់នឹងមិនអាចវិលត្រឡប់មកជាថ្មីម្តងទៀតឡើយ ។ សន្តិភាពអាចជួយធ្វើឲ្យប្រទេសជាតិរីកចម្រើនប្រជាជនមានឱកាសរៀនសូត្រជ្រៅជ្រះ និងបានចូលរួមយ៉ាងសស្រាក់សស្រាំក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិ ។ ម៉ៃឃើល អ៊ីកណាទីវ បកស្រាយដូចខាងក្រោម ÷

លទ្ធិប្រជាធិបតេយ្យធ្វើឲ្យដំណើរការផ្សះផ្សាបង្រួបបង្រួមជឿនលឿននិងស្ថិតស្ថេរ ពីព្រោះការផ្តល់សិទ្ធិសេរីភាពក្នុងការជជែកតវ៉ាគឺជាសញ្ញាបញ្ជាក់ថា ប្រជាជនមានឱកាសជជែកពិភាក្សារកដំណោះស្រាយដោយសន្តិវិធី ដោយមិនចាំបាច់កាន់អាវុធដើម្បីកាប់សម្លាប់គ្នា ហើយការកាប់សម្លាប់សងសឹកមិនអាចដោះស្រាយបញ្ហានិងមិនអាចធ្វើឲ្យអ្នកដែលបាត់បង់ជីវិតហើយរស់ឡើងវិញទេ ។

### ឃ៧) ការកសាងបូជនីយដ្ឋាន

គួរតែកសាងបូជនីយដ្ឋានឲ្យបានគ្រប់ខេត្តក្រុងទូទាំងប្រទេសដើម្បីទុកជាទីកន្លែងគោរពវិញ្ញាណក្ខន្ធនិងរំឭកដល់ប្រជាជនដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ បូជនីយដ្ឋានមួយៗត្រូវតែមានអ្នកថែរក្សានិងសម្អាតជាប្រចាំសម្រាប់ឲ្យប្រជាជនចូលទស្សនានិងប្រារព្ធពិធីបុណ្យផ្សេងៗ ជាពិសេសបូជនីយដ្ឋានជើងឯកនិងបូជនីយដ្ឋានក្រាំងតាចាន់ ។ ការសាងសង់និងថែរក្សាបូជនីយដ្ឋានអាចជួយធ្វើឲ្យជនរងគ្រោះមានអារម្មណ៍ធូរស្បើយមួយកម្រិត ។

## ៣) សរុប

អំណះអំណាងរបស់ខ្ញុំនៅក្នុងជំពូកនេះគឺចាំបាច់ត្រូវតែបង្កើតគណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជាហើយសហការជាមួយតុលាការខ្មែរក្រហមក្នុងដំណើរការផ្សះផ្សា

បង្រួបបង្រួមជាតិនៅប្រទេសកម្ពុជា ។ គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជានឹងជួយបំពេញចន្លោះខ្វះខាតរបស់តុលាការខ្មែរក្រហម ជាពិសេសជួយស្វែងរកការពិត និងធ្វើឲ្យជនរងគ្រោះអាចស្ងប់អារម្មណ៍ និងយល់អធ្យាស្រ័យចំពោះជនដៃដល់ថ្នាក់ក្រោម ។ ការអត់ឱនរវាងជនរងគ្រោះនិងជនដៃដល់អាចធ្វើឲ្យប្រជាជនយល់ចិត្តគ្នា ហើយសុខចិត្តរួមរស់និងធ្វើការជាមួយគ្នាឡើងវិញ ។

ទន្ទឹមនឹងនេះ តាមរយៈការសិក្សាប្រៀបធៀបរវាងការងាររបស់គណៈកម្មការស្វែងរកការពិតនិងការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងឃើញថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានបទពិសោធន៍និងធនធានសមល្មមអាចបំពេញតួនាទីជាគណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជា ។ ឧទាហរណ៍ កម្មវិធីស្វែងរកគ្រួសារ ការសិក្សាស្រាវជ្រាវ និងទស្សនាវដ្ដី គឺជាកម្មវិធីដែលបានចូលរួមនិងបម្រើដល់ដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិឡើងវិញ ។ ក្រៅពីនេះ ការសិក្សាអប់រំអំពីប្រវត្តិសាស្ត្រ ការថែរក្សាសុខភាពផ្លូវចិត្ត ការធ្វើសមាហរណកម្ម និងការបង្កើតកម្មវិធីទ្រទ្រង់ជនរងគ្រោះ សុទ្ធសឹងតែមានតួនាទីសំខាន់ក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិ ។ កម្មវិធីនិងជោគជ័យរបស់គណៈកម្មការស្វែងរកការពិត គឺពឹងផ្អែកទាំងស្រុងលើការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជា សហគមន៍អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ។

## សេចក្ដីបញ្ចប់

យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមជាតិមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ។ ការស្វែងរកយុត្តិធម៌គឺជាជំហានដំបូងដែលជួយជនរងគ្រោះឲ្យមានអារម្មណ៍ធូរស្បើយ ដោយសារ ទីមួយ ការឈឺចាប់របស់ខ្លួនត្រូវបានទទួលដឹងឮ ទីពីរ ភាពអយុត្តិធម៌ដែលខ្លួនទទួលរងត្រូវបានដោះស្រាយ ហើយជនរងគ្រោះរស់នៅដោយសង្ឃឹមថាប្រទេសជាតិមានច្បាប់ទម្លាប់ត្រឹមត្រូវឡើងវិញ ។

ទោះបីជាយ៉ាងណាក្ដី កត្តាយុត្តិធម៌តែមួយមិនអាចគ្រប់គ្រាន់សម្រាប់ដំណើរការផ្សះផ្សាបង្រួបបង្រួមសម្រាប់ប្រទេសដែលទើបឆ្លងផុតពីសង្គ្រាមឡើយ ។ម្យ៉ាងទៀត ដំណើរការស្វែងរកយុត្តិធម៌រមែងគំរាមកំហែងដល់សន្តិសុខសង្គមនិងការពិត ។ ចនប៉ូល ឡឺដារ៉ាក ពណ៌នាថា ការផ្សះផ្សាបង្រួបបង្រួមជាតិគឺជាការដាក់បញ្ចូលគ្នារវាងយុត្តិធម៌ ការពិត សន្តិភាព និងការយល់អធ្យាស្រ័យ ។ ការផ្សះផ្សាបង្រួបបង្រួមអាចសម្រេចទៅបានលុះត្រាតែកត្តាទាំង៤នេះរួបរួមទៅជាកត្តាតែមួយ ប៉ុន្តែនៅក្នុងការងារជាក់ស្ដែង កត្តាទាំង៤នេះតែងមានការប្រទាញប្រទង់គ្នាជានិច្ច ។ ឡឺដារ៉ាក ពន្យល់បន្ថែមថា ÷

*ការពិតគឺសំដៅដល់ការដឹងអំពីអ្វីដែលបានកើតឡើង ហើយអ្នកដែលធ្វើខុសទទួលស្គាល់កំហុសរបស់ខ្លួន ។ ក៏ប៉ុន្តែ បន្ទាប់ពីដឹងការពិតគឺត្រូវតែមានការអាណិតអាសូរនិងអធ្យាស្រ័យចំពោះអ្នកដែលបានធ្វើខុសហើយបានសារភាពកំហុសរបស់ខ្លួន ។ យុត្តិធម៌គឺសំដៅដល់សិទ្ធិរបស់បុគ្គលឬក្រុម ដើម្បីស្ដាបនាឲ្យមានច្បាប់ទម្លាប់ ឬទាមទារសំណងអំពីការខូចខាតរបស់ខ្លួន ប៉ុន្តែការស្វែងរកយុត្តិធម៌ត្រូវតែសមស្របជាមួយកាលៈទេសៈនិងស្ថានភាពប្រទេស ។*

តាមការពន្យល់បកស្រាយរបស់ ឡឺដារ៉ាក ភាពប្រទាញប្រទង់របស់កត្តាទាំង៤និងភាពមិនស្រុះស្រួលគ្នានៅក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមរវាងកត្តាទាំង៤មានលក្ខណៈដូចរឿងនិទានមួយក្រោមចំណងជើងថា "ខ្ញុំសំខាន់ជាងគេ" ÷

*ថ្ងៃមួយ មាត់ ជើង និងក្បាលបានជុំគ្នា ហើយពិភាក្សាអំពីថាតើនរណាមានតួនាទីសំខាន់ជាងគេសម្រាប់ខ្លួនមនុស្ស ។ មាត់បញ្ចេញយោបល់មុនថា "ខ្ញុំសំខាន់ជាងគេ" ។ មាត់ពន្យល់អំពីការងារដ៏លំបាករបស់ខ្លួនក្នុងការទំពារអាហារដើម្បីចិញ្ចឹមសព៌ាង្គកាយ "បើគ្មានខ្ញុំ ខ្លួនប្រាណទាំងមូលនឹងត្រូវស្លាប់" ។ ក្បាលយល់ស្រប ប៉ុន្តែជើងបញ្ចេញប្រតិកម្មភ្លាមថា "ខ្ញុំសំខាន់ជាងគេ" ។ ជើងរៀបរាប់បន្តថា "បើគ្មានខ្ញុំ មាត់មិនអាចមានអ្វីសម្រាប់ហូបឡើយ ។ គឺខ្ញុំជាអ្នកដើរស្វែងរកចំណី" ។ ភ្លាមនោះ ក្បាលនិយាយកាត់ដោយសម្ដីម៉ឺងម៉ាត់ថា "ខ្ញុំសំខាន់ជាងគេ ។ ខ្ញុំគឺជាអ្នករិះគិតនិងបញ្ជាគ្រប់គ្នាឲ្យធ្វើការ" ។*

គ្រប់ផ្នែកនៃសព៌ាង្គកាយមើលឃើញភាពសំខាន់របស់ខ្លួនដោយភ្លេចគិតឬមិនទទួលស្គាល់ភាពសំខាន់របស់អ្នកដទៃ ទីបំផុតខ្លួនប្រាណទាំងមូលចុះខ្សោយនិងស្លាប់បាត់បង់ជីវិត ។ ដូចគ្នានេះដែរ កត្តាយុត្តិធម៌តែមួយមិនអាចគ្រប់គ្រាន់សម្រាប់ទ្រទ្រង់សព៌ាង្គកាយឬគ្រប់គ្រាន់សម្រាប់ដំណើរការផ្សះផ្សាបង្រួបបង្រួម

ជាតិឡើយ ។ សព៌ាន្តកាយក៏ដូចការផ្សះផ្សាបង្រួបបង្រួមជាតិដែរ គឺសុទ្ធតែត្រូវការចូលរួមនិងកិច្ចសហការពីគ្រប់ផ្នែកនិងមជ្ឈដ្ឋាន ។

នៅប្រទេសរ៉្វាន់ដា ការពឹងផ្អែកទាំងស្រុងលើកត្តាយុត្តិធម៌ដើម្បីលុបបំបាត់អំពើហិង្សានិងទប់ស្កាត់ការកើតឡើងជាថ្មីនៃអំពើកាប់សម្លាប់ទទួលបានលទ្ធផលតិចតួចបំផុត ។ ផ្ទុយទៅវិញ តុលាការប្រជាជនកាឆាឆាដែលប្រើប្រាស់វិធីសាស្ត្រដែលប្រជាជនស្គាល់ច្បាស់បានបំពេញតួនាទីយ៉ាងសំខាន់ក្នុងការនាំមកនូវសន្តិភាពនិងធ្វើឲ្យប្រជាជនជឿទុកចិត្តគ្នាទៅវិញទៅមក ។

ប្រជាជនកម្ពុជាក៏មិនខុសពីប្រជាជនរ៉្វាន់ដាដែរ គឺសុទ្ធតែទាមទារឲ្យមានតុលាការកាត់ទោសមេដឹកនាំដែលបានប្រព្រឹត្តខុស ។ បន្ទាប់ពីពិភាក្សាអំពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់តុលាការខ្មែរក្រហមនិងការសិក្សាអំពីបទពិសោធន៍របស់ប្រទេសរ៉្វាន់ដា យើងឃើញថា តុលាការខ្មែរក្រហមនឹងមិនគ្រប់គ្រាន់សម្រាប់ដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជាឡើយ ។ គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជាអាចជួយបំពេញកង្វះខាតរបស់តុលាការក្នុងដំណើរការនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាអាចបំពេញតួនាទីជាគណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជាបានដោយសារ ទីមួយ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធីដែលបម្រើដល់ការងារនេះ ។ ទីពីរ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជាខិតខំស្វែងរកការពិតយកការពិតជាធំ និងប្រើប្រាស់ផ្លូវកណ្តាលក្នុងការធ្វើការងារនិងដោះស្រាយបញ្ហាដែលបន្សល់ទុកពីរបបខ្មែរក្រហម ។ ទោះបីជាគណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជាមានអត្ថប្រយោជន៍ច្រើនយ៉ាងណាក្តី ការអប់រំ ការថែរក្សាសុខភាព និងកម្មវិធីទ្រទ្រង់ជនរងគ្រោះនៃរបបខ្មែរក្រហម នៅតែមិនអាចខ្វះបាន ។

មូលហេតុសំខាន់ដែលខ្ញុំសម្រេចចិត្តសិក្សាអំពីប្រធានបទ "យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា" ទីមួយដោយសារប្រធានបទនេះបាននិងកំពុងត្រូវពិភាក្សាយ៉ាងផុលផុសហើយត្រូវការគំនិតថ្មីសម្រាប់ដោះស្រាយបញ្ហាខ្មែរក្រហមជាចាំបាច់ ។ ផលវិបាកចំនួនពីរបានកើតឡើងនៅក្នុងពេលសិក្សាស្រាវជ្រាវប្រធានបទនេះ គឺកង្វះខាតឯកសារនិងពេលវេលាខ្លី ។ ផលវិបាកទាំងនេះអនុញ្ញាតឲ្យខ្ញុំប្រើប្រាស់ត្រឹមតែករណីប្រទេសពីរប៉ុណ្ណោះ គឺប្រទេសរ៉្វាន់ដានិងប្រទេសកម្ពុជាធ្វើជាឧទាហរណ៍បង្ហាញ ។

ជាចុងក្រោយ ការផ្សះផ្សាបង្រួបបង្រួមអាចកើតឡើងបានលុះត្រាតែភាគីជម្លោះយល់ព្រមផ្លាស់ប្តូរឥរិយាបថ ហើយយល់អធ្យាស្រ័យគ្នាទៅវិញទៅមក មានជំនឿចិត្តលើគ្នា និងសម្លឹងមើលទៅអនាគតទាំងអស់គ្នា ។ ដូចដែលបានបង្ហាញខាងដើម តុលាការអាចជួយទប់ស្កាត់មិនឲ្យមានអំពើហិង្សានិងកាប់សម្លាប់ជាថ្មី ប៉ុន្តែយុត្តិធម៌ដែលផ្តល់ដោយតុលាការមិនអាចគ្រប់គ្រាន់នឹងធ្វើឲ្យប្រជាជនគ្រប់រូបសប្បាយចិត្តនិងយល់ព្រមផ្សះផ្សាបង្រួបបង្រួមឡើយ ។ គណៈកម្មការស្វែងរកការពិតអាចជួយបំពេញកង្វះខាតរបស់តុលាការតាមរយៈការផ្សព្វផ្សាយឲ្យប្រជាជនបានដឹងអំពីការពិតនូវអ្វីដែលបានកើតឡើង ។ គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជាដែលសមស្របនឹងប្រពៃណីវប្បធម៌ខ្មែរ នឹងមានការគាំទ្រច្រើនពីប្រជាជន ហើយទទួលបានជោគជ័យធំធេងក្នុងការធ្វើឲ្យមានការយល់អធ្យាស្រ័យនិងផ្សះផ្សាបង្រួបបង្រួមរវាងជនរងគ្រោះនិងជនដៃដល់ថ្នាក់ក្រោម ។ ការអប់រំអំពីប្រវត្តិសាស្ត្រ ការជួយឧបត្ថម្ភផ្នែកសុខភាពជូនដល់ប្រជាជនក៏មានលក្ខណៈចាំបាច់ដែរ ជាពិសេស ដូចជា ករណី ភុំ, ដុច និង សំ ។ អ្នកទាំងបីមិនត្រឹមតែទាមទាររកយុត្តិធម៌ ប៉ុន្តែថែមទាំងចង់ដឹងអំពីការពិតនិងចង់ឲ្យមានការអប់រំអំពីរបបខ្មែរក្រហមដល់មនុស្សជំនាន់ក្រោយទៀតផង ។ ដូច្នេះ ការផ្តល់យុត្តិធម៌តែមួយមុខដល់អ្នកទាំងបី (ភុំ, ដុច និង សំ) ពិតជាមិនគ្រប់គ្រាន់សម្រាប់ធ្វើឲ្យគាត់យល់ព្រមអត់ឱននិងរស់នៅក្នុងភូមិជាមួយគ្នាដោយសុខស្រួលឡើយ ។

ការផ្សះផ្សាបង្រួបបង្រួមគឺជាទិសដៅនិងជាដំណើរការ ។ ដូច្នេះយើងមិនទាន់អាចដឹងច្បាស់អំពីលទ្ធផលនៃដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជានៅឡើយទេ ។ ទោះបីជាយ៉ាងណាក្តី ដំណើរការផ្សះផ្សាបង្រួបបង្រួមដែលមានទាំងតុលាការខ្មែរក្រហមនិងគណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជាពិតជាទទួលបានលទ្ធផលល្អប្រសើរជាងដំណើរការផ្សះផ្សាបង្រួបបង្រួមដែលមានតែតុលាការខ្មែរក្រហមមួយ ។ **(ចប់)**

**អៀ ម៉េងទ្រី**

# សមមិត្ត នួន ជា : ការកសាងអ្នកដើរតាមមនោគមវិជ្ជាខ្មែរក្រហម



នួន ជា

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា ដែលបច្ចុប្បន្នមានវ័យ៨០ឆ្នាំ ជាអនុលេខាបក្សកុម្មុយនិស្តកម្ពុជា និងជាមនុស្សសំខាន់មួយរូបដែលនឹងប្រឈមមុខនឹងការកាត់ទោសនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាសម្រាប់ការកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលគាំទ្រដោយអង្គការសហប្រជាជាតិ និងដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំជាយូរឆ្នាំមកហើយ ។ ពេលថ្មីៗនេះ អង្គជំនុំជម្រះនេះត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ជាចុងក្រោយ នួន ជា ត្រៀមបង្ហាញខ្លួននៅចំពោះមុខតុលាការ និងបកស្រាយរឿងរ៉ាវរបស់ខ្លួនថាតើហេតុអ្វីបានជាប្រជាជនខ្មែរជិតពីរលាននាក់ត្រូវសម្លាប់យ៉ាងសាហាវព្រៃផ្សៃក្នុងរយៈពេលតែជាងបីឆ្នាំប៉ុណ្ណោះក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ហើយតើប្រជាជនខ្មែរជិតពីរលាននាក់នោះត្រូវសម្លាប់តាមរបៀបណា ។ អ្នកនិពន្ធជាន់ខ្ពស់ម្នាក់របស់កាសែតបាងកកប៉ុស្តិ៍ឈ្មោះ នូសារ៉ា ថៃជាវ៉ាត់ បានជួបសម្ភាសន៍ជាមួយសមមិត្ត នួន ជា ។ នួន ជា និយាយប្រាប់អំពីកាលដែលគាត់នៅជានិស្សិតសាកលវិទ្យាល័យធម្មសាធ ជាមន្ត្រីស៊ីវិលនៃក្រសួងហិរញ្ញវត្ថុនិងក្រសួងការបរទេសប្រចាំនៅក្នុងទីក្រុងបាងកក និងជាសមាជិកបក្សកុម្មុយនិស្តថៃ ព្រមទាំងមូលហេតុដែលជំរុញឲ្យគាត់ដើរតាមមាគ៌ាខ្មែរក្រហម ។ ប្រជាជនកម្ពុជារង់ចាំរឿងរ៉ាវនេះអស់រយៈពេល៣១ឆ្នាំហើយចាប់តាំងពីខ្មែរក្រហមចូលគ្រប់គ្រងប្រទេសក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ។

នួន ជា និយាយថា "សាកលវិទ្យាល័យធម្មសាធបង្រៀនខ្ញុំឲ្យចេះបម្រើប្រជាជននិងចេះលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួនដើម្បីផលប្រយោជន៍សាធារណៈ ។ ខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើគោលការណ៍យុត្តិធម៌ សមភាព និងប្រជាធិបតេយ្យដែលសាកលវិទ្យាល័យធម្មសាធប្រកាន់យក" ។ អង្គុយជាមួយនឹងប្រពន្ធគាត់នៅក្នុងផ្ទះដ៏សាមញ្ញមួយធ្វើពីឈើជាប់ព្រំដែនថៃក្នុងទីក្រុងប៉ៃលិនភាគខាងលិចប្រទេសកម្ពុជា បុរសចំណាស់រូបនេះនៅចងចាំយ៉ាងច្បាស់យុវវ័យរបស់គាត់កាលរៀននៅសាកលវិទ្យាល័យធម្មសាធជាមួយនឹងមិត្តរួមថ្នាក់ជាជនជាតិថៃនៅក្នុងទសវត្សរ៍ឆ្នាំ១៩៤០ ។ ភាសាថៃរបស់ នួន ជា ស្តាប់ទៅដូចជាអ្នកចេះដឹងជ្រៅជ្រះជាតិថៃ ហើយជាញឹកញាប់ គាត់ដកស្រង់សម្តីរបស់អ្នកនយោបាយដែលទទួលការគោរពបំផុតនៅក្នុងប្រទេសថៃ ។

នួន ជា បន្ថែមទៀតថា "កម្ពុជាគឺជាអ្នកផ្តល់ជីវិតឲ្យខ្ញុំតាមធម្មជាតិ ចំណែកសាកលវិទ្យាល័យធម្មសាធផ្តល់ជីវិតឲ្យខ្ញុំខាងនយោបាយ ។ ខ្ញុំតែងតែដឹងគុណសាកលវិទ្យាល័យធម្មសាធ" ។

នួន ជា ចាំឈ្មោះសាកលវិទ្យាល័យធម្មសាធ ក៏ប៉ុន្តែ សាកលវិទ្យាល័យធម្មសាធបែរជាភ្លេចថា នួន ជា ធ្លាប់ជាសិស្សម្នាក់នៃសាកលវិទ្យាល័យធម្មសាធទៅវិញ ។ ពុំមានកំណត់ហេតុសិក្សាណាមួយរបស់ នួន ជា ត្រូវបានរកឃើញឡើយ ។ ជាងនេះទៅទៀតមានការខិតខំប្រឹងប្រែងតិចតួចបំផុតពីសាកលវិទ្យាល័យធម្មសាធក្នុងការជួយដល់អ្នកស្រាវជ្រាវអំពើប្រល័យពូជសាសន៍ដែលមកពីប្រទេសកម្ពុជា និងដែលបានស្នើសុំឲ្យមានកិច្ចសហប្រតិបត្តិការបញ្ចប់សំណុំឯកសាររបស់ នួន ជា មុនការបើកអង្គជំនុំជម្រះក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលគាំទ្រដោយអង្គការសហប្រជាជាតិដែលត្រូវធ្វើឡើងនៅក្នុងប្រទេសកម្ពុជានាឆ្នាំក្រោយនេះ ។

ប្រសិនបើមានការអះអាងបញ្ជាក់ជាថ្មីណាមួយដែលថាសាកលវិទ្យាល័យធម្មសាធអាចមានបុគ្គានហេតុផលផ្ទាល់ខ្លួនចំពោះភាពមិនអាចស្វែងរកកំណត់ហេតុសិក្សារបស់អតីតសិស្សដែលមានឈ្មោះម្នាក់មែននោះ នួន ជា បានពន្យល់ប្រាប់ថា អ្វីដែលកំណត់ឲ្យគាត់សម្រេចចិត្តជ្រើសរើសយកផ្លូវដែលឆ្ពោះទៅរកជីវិតជាអ្នកនយោបាយគឺអាណានិគមនិយមបារាំង ភាពក្រីក្រដែលចេះតែរីកធំឡើងៗ និងភាពខុសគ្នារវាងអ្នកមាននិងអ្នកក្រនៅក្នុងខេត្តបាត់ដំបងដែលជាទីកន្លែងកំណើតរបស់ខ្លួន ។ ភាពតានតឹងក្នុង

អារម្មណ៍បណ្តាលមកពីការបោកប្រាស់ក្នុងសង្គម ។ សាកលវិទ្យាល័យធម្មសាធគ្រាន់តែបង្ហាញ នួន ជា ថាអាចប្រយុទ្ធប្រឆាំងដើម្បីផ្លាស់ប្តូរអ្វីៗទាំងនោះបាន ។

នួន ជា និយាយថា "ជីបូនខ្ញុំរស់នៅក្នុងភូមិកំណើតរបស់ខ្ញុំក្នុងខេត្តបាត់ដំបង ។ កាលពីជំនាន់ ខ្ញុំមិនដឹងថាតើ "ជាតិ"មានន័យដូចម្តេចនោះទេ ។ ប្រទេសថៃជាអ្នកបង្រៀនខ្ញុំឲ្យយល់អត្ថន័យនៃពាក្យនេះ ពីព្រោះប្រទេសថៃជាប្រទេសឯករាជ្យមួយ ហើយកម្ពុជានៅក្រោមនឹមត្រួតត្រារបស់អាណានិគមនិយមបារាំង ។ ម្យ៉ាងវិញទៀត ខ្ញុំមានបំណងចង់ទៅសិក្សានៅប្រទេសថៃ ក៏ប៉ុន្តែនៅពេលដែលខ្ញុំមកដល់ប្រទេសថៃ ខ្ញុំឃើញជនបរទេសជាច្រើនកំពុងរស់នៅនិងធ្វើការក្នុងប្រទេសនេះ ។ ខ្ញុំគិតថាប្រទេសថៃក៏ដូចជាប្រទេសកម្ពុជាដែរ មិនមែនជាប្រទេសឯករាជ្យទេ ។ ខ្ញុំឃើញប្រជាជនថៃជាច្រើននាក់ (ខុសពីអ្វីដែលខ្ញុំធ្លាប់គិតថាប្រទេសថៃជាប្រទេសអ្នកមាន) ។ ខ្ញុំចោទសួរខ្លួនឯងថាតើខ្ញុំត្រូវជ្រើសរើសយកផ្លូវមួយណា ។ ខ្ញុំពិតជាធុញទ្រាន់នឹងសង្គមណាស់ តើហេតុអ្វីបានជាខ្ញុំត្រូវបន្តការសិក្សានៅប្រទេសថៃ ហើយបន្តការសិក្សាដើម្បីនរណា? ខ្ញុំគិតពិចារណាលើជម្រើសពីរ តើត្រូវបួសជាសង្ឃ ឬត្រូវតស៊ូរំដោះប្រជាជនចេញពីភាពក្រីក្រនិងការគាបសង្កត់របស់បារាំង ។

នួន ជា មានប្រសាសន៍ថា "នយោបាយរបស់ខ្ញុំនៅពេលនោះមានដំណើរឆ្ពោះទៅមុខបន្តិចម្តងៗ ដោយសារតែព្រឹត្តិការណ៍ជុំវិញខ្លួនខ្ញុំ ។ នៅពេលយប់ ខ្ញុំគិតអំពីអត្ថន័យនៃពាក្យ "ជាតិ" ។ ខ្ញុំសម្រេចចិត្តជ្រើសរើសយកផ្លូវមួយសម្រាប់ខ្លួនខ្ញុំផ្ទាល់" ។

បន្ទាប់ពីបានរៀនចប់នៅសាលាភាសាបារាំងមួយនៅក្នុងខេត្តបាត់ដំបង នួន ជា ដែលពេលនោះមានអាយុ១៦ឆ្នាំនិងមិនចេះភាសាថៃសូម្បីតែមួយម៉ាត់ បានស្តាប់តាមដំបូន្មានរបស់ព្រះសង្ឃមួយអង្គនៅក្នុងខេត្តបាត់ដំបងហើយទៅបន្តការសិក្សានៅទីក្រុងបាងកក ។

តាមពិត នួន ជា ជាប្រជាពលរដ្ឋថៃដែរ ពីព្រោះក្នុងពេលនោះខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណ ស្ថិតនៅក្រោមការត្រួតត្រារបស់ថៃ (ឆ្នាំ១៩៤១-៤៦) ក្រោមកិច្ចព្រមព្រៀងវ៉ាស៊ីនតោន/ក្រុងបាងកកនិងជប៉ុនក្នុងសម័យសង្គ្រាមលោកលើកទីពីរ ។

នួន ជា ត្រូវព្រះសង្ឃនៅខេត្តបាត់ដំបងដាក់ឈ្មោះជាភាសាថៃថា រុងឡឺត ឡាវឌី ហើយស្នាក់នៅរៀនសូត្រជាមួយនឹងសិស្សវត្តផ្សេងៗទៀតនៅក្នុងវត្ត បិណ្ឌចាម៉ាបូពិត នៅក្នុងទីក្រុងបាងកក ។ មិត្តភក្តិម្នាក់របស់ នួន ជា គឺសង្ឃនិយមស្តាំមួយអង្គព្រះនាម ប្រាវឌ្ឍនាវ៉ាត ដែលនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ល្បីល្បាញខាងទេសនាថា "ការសម្លាប់កុម្មុយនីស្តមិនមែនជាអំពើបាប" ។ យើងនៅមិនទាន់ដឹងច្បាស់ថាតើ នួន ជា និងនេនមួយអង្គនោះរក្សាទំនាក់ទំនងជាមួយគ្នាបានយូរប៉ុនណាទេ ពីព្រោះក្នុងពេលសម្ភាសន៍ នួន ជា បានរំឭកឈ្មោះសង្ឃអង្គនោះនិងបាននិយាយថាសង្ឃអង្គនោះបានសុគតទៅហើយ ។

នួន ជា នៅចាំបានថា "ក្នុងឆ្នាំ១៩៤៤មានទឹកជំនន់ធំបានបំផ្លិចបំផ្លាញទីក្រុងបាងកក ។ នៅពេលនោះ ខ្ញុំជាក្មេងវត្តដូចនឹងក្មេងវត្តដទៃទៀតនិងធ្វើការដើម្បីដោះដូរយកបាយស៊ី ។ ថ្លៃសាលា គឺ៣បាតក្នុងមួយឆមាស ។ ដូច្នេះក្នុងឆ្នាំសិក្សា១៩៤២-៤៣ ខ្ញុំរៀននៅថ្នាក់ ម.៥ (ថ្នាក់ទី១១) ឆ្នាំសិក្សា១៩៤៣-៤៤ ខ្ញុំរៀនថ្នាក់ ម.៦ (ថ្នាក់ទី១២) ហើយក្នុងឆ្នាំ១៩៤៤ខ្ញុំចុះឈ្មោះរៀនត្រៀមចូលសាកលវិទ្យាល័យធម្មសាធ" ។ នួន ជា និយាយថា "ខ្ញុំរៀននៅថ្នាក់ទី៧ បន្ទប់លេខ៩ និងជាប្រធានថ្នាក់ ។ ខ្ញុំចាំថា ក្នុងសម័យសង្គ្រាមលោកលើកទីពីរមានភាពតានតឹងយ៉ាងខ្លាំង សាកលវិទ្យាល័យធម្មសាធត្រូវបិទទ្វារមួយរយៈដើម្បីសុវត្ថិភាព ។ សិស្សទាំងអស់ត្រូវរត់ភៀសខ្លួនទៅតាមខេត្ត ។ ហេតុដូចនេះ សាកលវិទ្យាល័យត្រូវផ្ញើកិច្ចការសាលានិងមេរៀនទៅឲ្យសិស្សតាមប៉ុស្តិ៍ប្រៃសណីយ៍ ។ ខ្ញុំអាចជួបមិត្តរួមថ្នាក់របស់ខ្ញុំតែក្នុងពេលប្រឡងប៉ុណ្ណោះ ។ ខ្ញុំស្នាក់នៅវត្តបិណ្ឌចាម៉ាបូពិត ។ នៅពេលដែលស្ថានភាពវិលមករកភាពល្អប្រសើរវិញ សាកលវិទ្យាល័យធម្មសាធបានបើកដំណើរការឡើងវិញ ហើយខ្ញុំក៏ត្រឡប់ទៅរៀន" ។

នួន ជា និយាយថា គាត់ត្រូវសិក្សា៧ឬ៨មុខវិជ្ជា ហើយភាគច្រើនមុខវិជ្ជាទាំងនេះទាក់ទិននឹងច្បាប់ ក៏ប៉ុន្តែមិនបានបញ្ចប់ឆ្នាំសិក្សាដំបូងឡើយ ពីព្រោះពេលនោះគាត់ធ្វើការបណ្តើររៀនបណ្តើរ ។ នួន ជា ធ្វើការមួយរយៈខ្លីនៅនាយកដ្ឋានធនធានទឹកនិងក្រោយមកផ្លាស់ទៅនាយកដ្ឋានត្រួតពិនិត្យនៃក្រសួងហិរញ្ញវត្ថុ ។

នួន ជា ធ្វើការនៅនាយកដ្ឋានត្រួតពិនិត្យបានបីឆ្នាំមុននឹងដាក់ច្បាប់ឈប់សម្រាកបីខែដើម្បីបួសជាសង្ឃនៅក្នុងខេត្តឆាឌឹងសាវ ។

នៅពេលដែល នួន ជា វិលត្រឡប់ទៅទីក្រុងបាងកកវិញ គាត់បានប្រលងចូលជាមន្ត្រីរាជការក្នុងក្រសួងមួយទៀត ប៉ុន្តែលើកនេះគឺចូលបម្រើក្នុងក្រសួងការបរទេស ។ នួន ជា ត្រូវបានចាត់ឲ្យទៅកាន់ការិយាល័យឥណ្ឌូចិន ប៉ុន្តែមុខនាទីរបស់គាត់ត្រូវបានបដិសេធចោល ។ ផ្ទុយទៅវិញ គាត់ត្រូវបានផ្តល់តួនាទីជាស្មៀនផ្នែកលក់នៅក្នុងក្រសួងហិរញ្ញវត្ថុដោយទទួលបានប្រាក់បៀវត្សរ៍ ២៨បាត្រក្នុងមួយខែ ។ នួន ជា និយាយថា ប្រជាជនថៃដែលមកប្រទេសថៃ ដែលមានសមត្ថភាពស្មើនឹងគាត់ដែរ ត្រូវបានផ្តល់ការងារជំនាញ ។ មិនដល់មួយខែផង នួន ជា បានឈប់ពីការងារនៅប្រទេសថៃមកចូលរួមចលនាគាំទ្រលទ្ធិប្រជាធិបតេយ្យដោយមិនបានពន្យល់ចៅហ្វាយអំពីហេតុមូលនៃការលាឈប់នេះឡើយ ។

នួន ជា និយាយថា "នៅឆ្នាំនោះ សេនាប្រមុខ ពិន ឈូហាវ៉ាន់ធ្វើរដ្ឋប្រហារដោយជោគជ័យ និងបានចាប់ខ្លួនរដ្ឋមន្ត្រីសំខាន់ៗរបស់រដ្ឋាភិបាលចំនួនបួនរូប ។ រដ្ឋមន្ត្រីបួនរូបនេះជាអតីតសាស្ត្រាចារ្យនៅសាកលវិទ្យាល័យធម្មសាធ ។ ខ្ញុំគិតថា ខ្ញុំត្រូវតែចូលរួមចលនានិស្សិតដើម្បីទាមទារឲ្យមានការដោះលែងរដ្ឋមន្ត្រីទាំងបួនរូបនេះ ។ លួង ថាំរុង ណាវ៉ាសាម៉ាក ជាអតីតនាយករដ្ឋមន្ត្រី, អាចានព្រីឌី ផាណុំយ៉ុង អ្នកផ្តួចផ្តើមគំនិតបង្កើតសាកលវិទ្យាល័យធម្មសាធ ប្រមុខរដ្ឋស្តីទី និងរាជវង្សានុវង្ស ត្រូវនិរទេសទៅប្រទេសស៊ីស ។ នៅពេលនោះ មានចលនាមួយប្រឆាំងនឹងការដាក់អាណានិគមលើកទីពីររបស់បារាំងមកលើប្រទេសកម្ពុជាដែលប្រតិបត្តិចេញពីព្រំដែនកម្ពុជា-ថៃ ។ ខ្ញុំគាំទ្រយុត្តិធម៌ ។ នៅពេលដែលខ្ញុំធ្វើការនៅក្រសួងការបរទេស ខ្ញុំឃើញរបាយការណ៍ពីប្រទេសឡាវថាបារាំងបាញ់សម្លាប់ប្រជាជនស្លូតត្រង់ជាច្រើននាក់ដែលប្រើប្រាស់ទឹកពីទន្លេក្នុងខេត្តប៉ាក់សេ ។ នៅពេលនោះខ្ញុំគិតថាតើខ្ញុំរៀនច្បាប់សម្រាប់បម្រើឲ្យអ្នកណា? តើត្រូវបម្រើឲ្យថ្នាក់ដឹកនាំឬ? មានភាពអយុត្តិធម៌ច្រើនណាស់កើតមានឡើងនៅក្នុងសង្គម ។ កាលដែលខ្ញុំនៅបួសជាព្រះសង្ឃ កសិករជាច្រើនមករកខ្ញុំសុំជួយផ្តល់ពាក្យទូន្មានខ្លះៗ ។ កសិករទាំងនេះប្រាប់ខ្ញុំថាគាត់ក្រីក្រណាស់ ហើយត្រូវគណៈស្រុកដណ្តើមយកដីអស់ ។ ក្រោយពីខ្ញុំស្តាប់ការរៀបរាប់របស់កសិករទាំងនោះរួចមក ខ្ញុំពិតជាមានអារម្មណ៍ធុញទ្រាន់នឹងអំពើអយុត្តិធម៌ក្នុងសង្គមខ្លាំងណាស់" ។

ក្នុងពេលសម្ភាសន៍ នួន ជា ព្យាយាមលាបពណ៌វិធីដែលឆ្ពោះទៅរកគំនិតប្រឆាំងនឹងវណ្ណៈដូចគ្នានិងមេដឹកនាំកុម្មុយនិស្តដទៃទៀត ដូចជាភាពក្រីក្រអំពើអយុត្តិធម៌ក្នុងសង្គមនិងគំនិតដែលស្រដៀងនេះ ។ ការដែលក្រសួងការបរទេសថៃបដិសេធមិនផ្តល់តំណែងជំនាញឲ្យ នួន ជា ហើយបែរជាផ្តល់ឲ្យតែជនជាតិថៃនោះ បានបិទផ្លូវជីវិតនយោបាយរបស់ នួន ជា ។ នួន ជា ក៏ជាប្រជាពលរដ្ឋថៃម្នាក់ដែរ ក៏ប៉ុន្តែគាត់មិនមែនជាប្រជាពលរដ្ឋថៃពិតប្រាកដទេ ហើយគាត់គ្មានសិទ្ធិដូចជាប្រជាពលរដ្ឋថៃដែរ ។ ប្រហែលជាកត្តានេះហើយដែលជំរុញឲ្យគាត់សម្រេចចិត្តវិលត្រឡប់មកប្រទេសកម្ពុជាវិញ ។

នួន ជា ចូលរួមក្នុងបក្សកុម្មុយនិស្តថៃ ក្នុងគោលបំណងសិក្សាពី"វិធីដែលបក្សកុម្មុយនិស្តថៃរំដោះប្រទេសថៃ" ។ មិនយូរប៉ុន្មានបន្ទាប់ពីគាត់ចុះឈ្មោះរៀននៅសាកលវិទ្យាល័យធម្មសាធ នួន ជា ចូលជាសមាជិកយុវជនដើម្បីលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសថៃក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តថៃ ។ ពេលនោះ នួន ជា និងក្រុមនិស្សិតថៃរាប់ពាន់នាក់ត្រូវរដ្ឋាភិបាលថៃចាត់ទុកថាជាក្រុមកុម្មុយនិស្តដែលទាមទារឲ្យមានលទ្ធិប្រជាធិបតេយ្យនិងយុត្តិធម៌សង្គម ។

នួន ជា និយាយថា "ខ្ញុំចងចាំអ្វីដែលខ្ញុំបានពិភាក្សាជាមួយមិត្តភ័ក្តិរបស់ខ្ញុំ ។ យើងសួរខ្លួនឯងថា តើជាតិនិយមមានន័យដូចម្តេច? តើជាតិនិយមមានន័យថាការស្រឡាញ់ប្រជាជនឬ? តើប្រជាជនជានរណា? សម្តេងភាគច្រើន? ប្រជាជនក្រីក្រ? ខ្ញុំគិតថា ការពិភាក្សារបស់យើងត្រឹមត្រូវណាស់ ពីព្រោះខ្ញុំបានប្រៀបធៀបប្រទេសកម្ពុជានិងថៃ ។ មូលដ្ឋានគ្រឹះសំខាន់ៗក្នុងសង្គមទាំងពីរគឺមានលក្ខណៈប្រហាក់ប្រហែលគ្នា" ។

នួន ជា ចាកចេញពីប្រទេសថៃមកចូលរួមការតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំងនៅកម្ពុជាក្នុងឆ្នាំ១៩៥០ ។ ការចាកចេញនេះត្រូវបានសម្រួលដោយការផ្ទេរសមាជិកភាពពីបក្សកុម្មុយនិស្តថៃទៅឲ្យបក្សកុម្មុយនិស្តឥណ្ឌូចិនដឹកនាំដោយវៀតណាមដែលបានខិតខំជួយសម្របសម្រួលដល់ការតស៊ូនៅក្នុងប្រទេស

កម្ពុជា ឡាវ និងថៃ ។

យោងតាមកំណត់ហេតុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាគ្រឹះស្ថានស្រាវជ្រាវឯករាជ្យ មិនរកប្រាក់ចំណូលក្នុងការស្វែងរកការពិត យុត្តិធម៌ ការទទួលខុសត្រូវ និងការផ្សះផ្សាជាតិ នួន ជា ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចក្នុងរណសិរ្សខ្មែរឥស្សរៈប្រឆាំងនឹងអាណានិគមបារាំងក្នុងឆ្នាំ១៩៥១ ។ នួន ជា ចូលរួមក្នុងវគ្គបណ្តុះបណ្តាលមួយនៅប្រទេសវៀតណាម និងផ្តោតជាសំខាន់លើវគ្គបណ្តុះបណ្តាលមនោគមវិជ្ជាក្នុងតំបន់ផ្សេងៗនៃប្រទេសវៀតណាមនៅក្នុងឆ្នាំ១៩៥៤ ។

នៅពេលបក្សកុម្មុយនិស្តកម្ពុជាត្រូវបានបង្កើតក្នុងឆ្នាំ១៩៦០ នួន ជា មានតួនាទីជាអនុលេខាធិការគណៈកម្មាធិការមជ្ឈិមនិងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ដែលជាអង្គការសំខាន់បំផុតទទួលខុសត្រូវលើគោលនយោបាយរបស់បក្ស ។ នួន ជា មានតួនាទីអនុលេខាធិការរហូតតាំងពីពេលនោះមក ។

ភ្លាមៗបន្ទាប់ពីបក្សកុម្មុយនិស្តកម្ពុជាចូលកាន់អំណាចក្នុងខែមេសា ឆ្នាំ១៩៧៥ និងចាប់ផ្តើមអនុវត្តគោលនយោបាយរបស់ខ្លួនដើម្បីបោសសម្អាតកម្ពុជា និងកសាងឡើងវិញនូវកិត្តិនាមរបស់ខ្មែរ នួន ជា (ដែលអ្នកសារព័ត៌មានបស្ចិមប្រទេសស្គាល់ថាជា"បងធំទីពីរ") ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីនៅក្នុងឆ្នាំ១៩៧៦ ក៏ប៉ុន្តែ គាត់កាន់តំណែងនេះបានត្រឹមតែពីរបីខែប៉ុណ្ណោះ ក៏ត្រូវ ប៉ុល ពត (ដែលអ្នកសារព័ត៌មានលោកខាងលិចស្គាល់ថាជា "បងធំទី១") ចូលជំនួសតំណែងវិញ ។

យោងតាមក្រុមអ្នកជំនាញច្បាប់ មានភស្តុតាងសំខាន់ៗគួរឲ្យចាប់អារម្មណ៍ដែលបង្ហាញថា នួន ជា មានតួនាទីបង្កើតគោលនយោបាយសម្លាប់សម្រាប់បក្សកុម្មុយនិស្តកម្ពុជា ។ ភស្តុតាងសំខាន់ៗខ្លះទៀតបង្ហាញថា នួន ជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយនេះ ។ ឧទាហរណ៍ នួន ជា ត្រូវបានជឿថាបានធ្វើទារុណកម្មនិងសម្លាប់កម្មាភិបាលខ្មែរក្រហមដែលជាអ្នកទោសប្រុសស្រីនិងកុមារ១ម៉ឺន៤ពាន់នាក់នៅមន្ទីរសន្តិសុខ ស-២១ ដែលត្រូវបានស្គាល់ថាជា "គុកទួលស្លែង" នៅក្នុងទីក្រុងភ្នំពេញ ។


ប៉ុល ពត ស្លាប់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨

អ្នកជំនាញច្បាប់ក៏បានបង្ហាញអំពីឥទ្ធិពលនៃគំនិតនយោបាយរបស់ថៃមកលើជីវិតរបស់ នួន ជា ដែរ ។ ការសិក្សាស្រាវជ្រាវបានធ្វើឡើងដោយប្រើប្រាស់ពាក្យពេចន៍ដែលខ្មែរក្រហមខ្ចីពីភាសាថៃ ពីព្រោះអ្នកស្រាវជ្រាវជឿថា នួន ជា បានប្រើពាក្យពេចន៍ទាំងនោះជាភាសាថៃដែលមានប្រភពដើមចេញពីភាសាខ្មែរ ជាការសងសឹកនឹងប្រជាជនថៃដែល នួន ជា និយាយសរសើរផងនិងនិយាយដោយស្អប់ខ្ពើមផងក្នុងពេលជាមួយគ្នា ។

ក្នុងអាយុ៧៦ឆ្នាំ (ពេលដែលបទសម្ភាសន៍នេះកំពុងតែប្រព្រឹត្តទៅ) នួន ជា សម្រេចចិត្តមករស់នៅជាមួយប្រពន្ធរបស់គាត់ក្នុងផ្ទះឈើដ៏តូចមួយខុសពីមិត្តរួមការងារជាមួយគាត់ដែលពេញចិត្តជីវិតរស់នៅក្នុងភាពសុខស្រួលក្នុងផ្ទះដ៏ស្រស់ស្អាត ។ នួន ជា បាននិយាយថា អ្វីដែលគាត់ភ័យខ្លាច បំផុតមិនមែនការប្រឈមមុខនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ក៏ប៉ុន្តែគាត់ខ្លាចភ្នែកទាំងពីររបស់គាត់ព្រិលមិនអាចអានសៀវភៅ

បានដោយសារតែវ័យចំណាស់របស់គាត់ទៅវិញទេ ។

បើទោះបីជាគាត់មានការបារម្ភបន្តិចបន្តួចក៏ដោយ នួន ជា និយាយថា គាត់ជាមនុស្សចាស់ ហើយគំនិតរបស់គាត់លែងសំខាន់សម្រាប់គាត់ទៀតហើយ ។

"ខ្ញុំនៅតែជឿជាក់លើគំនិតបម្រើប្រជាជនខ្មែរដែលជាគំនិតមួយកំពុងតែបាត់បង់នៅក្នុងប្រទេសកម្ពុជា ។ ខ្ញុំបារម្ភអំពីក្មេងៗជំនាន់ក្រោយ ពីព្រោះកម្ពុជាទទួលរងការឈឺចាប់យ៉ាងខ្លាំងរហូតដល់ពេលសព្វថ្ងៃនេះ ។ ខ្ញុំដឹងថាយើងមិនអាចទាមទារឲ្យការធូរស្បើយឆាប់ៗនោះទេ ព្រោះយើងត្រូវតែប្រឈមមុខនឹងការពិតដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ អ្វីដែលខ្ញុំសង្ឃឹមគឺប្រជាជនឡាវ កម្ពុជា ថៃ និងវៀតណាម នឹងអាចដោះស្រាយបញ្ហាការប្រកាន់ពូជសាសន៍ និងរស់នៅជាមួយគ្នា ក្នុងនាមជាប្រទេសជិតខាងល្អនឹងគ្នា ។ ប្រជាជនវៀតណាមមើលងាយតំបន់ឥណ្ឌូចិនទាំងមូល ប្រជាជនថៃមើលងាយប្រជាជនខ្មែរ ហើយប្រជាជនខ្មែរមើលងាយប្រជាជនឡាវ ។ ហេតុដូច្នេះ យើងទាំងអស់គ្នាមិនគួររស់នៅក្នុងគំនិតបែបហួសសម័យនោះទេ ព្រោះនេះជាសម័យសកលភាវូបនីយកម្មទៅហើយ ។ សូម្បីតែសហរដ្ឋអាមេរិកត្រូវតែផ្លាស់ប្តូរដែរ ពីព្រោះសហរដ្ឋអាមេរិកមិនអាចចាត់ទុកខ្លួនថាជាប្រទេសមហាអំណាចដែលអាចប្រមាថពិភពលោកទាំងមូលបានឡើយ ។ សកលភាវូបនីយកម្មមិនមែនកើតឡើងដោយសារបច្ចេកទេសគ្មានព្រំដែននោះទេ ប៉ុន្តែកើតចេញពីទឹកចិត្តគ្មានព្រំដែនទៅវិញទេ" ។

នួន ជា និយាយថា "សព្វថ្ងៃខ្ញុំគ្រាន់តែជាមនុស្សចាស់ម្នាក់តែប៉ុណ្ណោះ ។ ខ្ញុំភ្ញាក់ពីព្រលឹម ព្រោះខ្ញុំពិបាកដេក ។ ពេលខ្លះខ្ញុំក្រោកនៅម៉ោង៣ៈ៣០ព្រឹកនិងបើកវិទ្យុស្តាប់ធម៌ទេសនា ។ ខ្ញុំតាមដានព័ត៌មានដែលផ្សាយចេញពីប្រទេសថៃនិងព័ត៌មានពិភពលោកតាមរយៈការអានកាសែត ស្តាប់វិទ្យុ និងតាមប្រភពផ្សេងៗទៀត" ។

នួន ជា បានសម្តែងការកោតសរសើរចំពោះអតីតនាយករដ្ឋមន្ត្រីថៃ ថាក់ស៊ីន ស៊ីណាវ៉ាត់ត្រា ដែលបានខិតខំប្រឹងប្រែងរៀបចំសណ្តាប់ធ្នាប់ក្នុងសង្គមថៃឡើងវិញ ។ នួន ជា បាននិយាយថា "ខ្ញុំមានជំនឿថា មធ្យោបាយតែមួយគត់ដែលនាំមានការផ្លាស់ប្តូរគឺរៀបចំរចនាសម្ព័ន្ធសង្គមឡើងវិញ ។ ប្រសិនបើគ្មានការរៀបចំរចនាសម្ព័ន្ធសង្គមឡើងវិញ តើប្រជាជនអាចផ្លាស់ប្តូរទៅរក សង្គមមួយដែលល្អប្រសើរយ៉ាងម៉េច បើរចនាសម្ព័ន្ធសង្គមចាស់នៅតែបន្តមាន? បើគិតអំពីផ្ទះដែលចាស់ទ្រុឌទ្រោមវិញ ក៏យើងត្រូវការផ្លាស់ប្តូរគ្រឿងចាស់ៗដែរ ។ ផ្ទះបែបនេះមិនអាចតម្រូវចិត្តគ្រួសារដែលចង់រស់នៅយ៉ាងសុខសប្បាយបានទេ ពីព្រោះនៅពេលណាមួយវានឹងរលំ ហើយអ្នកដែលរស់នៅក្នុងផ្ទះនេះនឹងត្រូវរបួស" ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៦នេះ មានចំណុចគួរឲ្យចាប់អារម្មណ៍ខុសពីថ្ងៃទី១៧ ខែមេសា កាលពី៣០ឆ្នាំមុន ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការមួយចំនួនទៀតដែលទទួលបន្ទុកជួយជនរងគ្រោះកំពុងតែត្រៀមរៀបចំឲ្យប្រជាជនចូលរួមយ៉ាងសកម្មក្នុងតុលាការនាពេលខាងមុខ ដោយបាននាំប្រជាជនរាប់ពាន់នាក់ ជនរងគ្រោះ កម្មាភិបាលខ្មែរក្រហម និងក្រុមគ្រួសារគាត់ ទៅទស្សនាអគារតុលាការនិងបូជនីយដ្ឋានប្រវត្តិសាស្ត្រដូចជាគុកទួលស្លែងជាដើម ។ យុទ្ធនាការផ្តល់ការអប់រំក៏កំពុងតែធ្វើដើម្បីត្រៀមរៀបចំឲ្យប្រជាជនចូលរួមតុលាការតាមដែលអាចធ្វើទៅបាន ។

នួន ជា ដែលមានឈ្មោះជាភាសាថៃ រុងឡឹត ឡាវឌី បានសម្រេចចិត្តធ្វើដំណើរទៅកាន់ទីក្រុងបាងកកដូចយុវជនក្មេងៗជាច្រើននាក់ទៀតដែលរស់តាមជនបទទាំងក្នុងប្រទេសថៃនិងកម្ពុជា ដោយស្រមៃថាជីវិតរបស់ខ្លួននឹងល្អប្រសើរជាងមុនសម្រាប់ក្រុមគ្រួសារ ប្រទេសជាតិ និងខ្លួនឯង ។ យើងមិនអាចដឹងថាមាគ៌ានោះនាំឆ្ពោះទៅរកឧក្រិដ្ឋកម្មដែលមិនអាចរៀបរាប់បានដូច្នេះនោះទេ ។ ជាមួយនឹងការចាប់ផ្តើមដំណើរការយ៉ាងល្អរបស់តុលាការនិងព័ត៌មានដែល នួន ជា និយាយប្រាប់អ្នកយកព័ត៌មានថាគាត់ត្រៀមបង្ហាញខ្លួននៅចំពោះមុខតុលាការនិងបកស្រាយរឿងរ៉ាវរបស់គាត់ នៅទីបំផុតយើងនឹងទទួលបាននូវចម្លើយខ្លះៗសម្រាប់ជីវិតមនុស្សរាប់លាននាក់ស្លាប់ក្រោមក្តីស្រមៃកាលនៅជាយុវវ័យរបស់ នួន ជា និងមិត្តរួមការងាររបស់គាត់ជាប្រាកដ និងជាចុងក្រោយចម្លើយរបស់អ្នកទាំងនេះនឹងបិទទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនេះរបស់កម្ពុជាជាមិនខាន ។

**ឆូសារ៉ា ថៃថាខាត់**

# កាលប្បវត្តិរបស់ នួន ជា

◆ **ឆ្នាំ១៩២៦** កើតនៅខេត្តបាត់ដំបងភាគខាងលិចប្រទេសកម្ពុជា ។ ក្នុងពេលដែលប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាណានិគមបារាំង ប្រទេសថៃកាន់កាប់ខេត្តចំនួនបី គឺខេត្តបាត់ដំបង សៀមរាប និងស៊ីសុផុន ពីឆ្នាំ១៩៤១រហូតដល់ឆ្នាំ១៩៤៦ ។

◆ **មុនឆ្នាំ១៩៤២** សិក្សានៅសាលាភាសាបារាំងមួយក្នុងខេត្តបាត់ដំបង ។

◆ **ឆ្នាំ១៩៤២** អាយុ១៦ឆ្នាំ ធ្វើដំណើរទៅទីក្រុងបាងកក ដើម្បីបញ្ចប់មធ្យមសិក្សាកម្រិតទី២ នៅនិងរស់នៅក្នុងវត្តបិណ្ឌចាម៉ាបូពិត នៅប្រទេសថៃ ។

◆ **ឆ្នាំ១៩៤៤** សិក្សាផ្នែកច្បាប់នៅសាកលវិទ្យាល័យធម្មសាធ ដោយប្រើឈ្មោះជាភាសាថៃ រ៉ុងឡឹត ឡាវឌី ហើយភ្លាមៗបន្ទាប់ពីនោះបានចូលរួមចលនាយុវជនដើម្បីលទ្ធិប្រជាធិបតេយ្យថៃតាមរយៈបក្សកុម្មុយនិស្តថៃ ។

◆ **ឆ្នាំ១៩៤៥** បញ្ចប់ការសិក្សានៅសាកលវិទ្យាល័យធម្មសាធ ហើយមកធ្វើការនៅនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងហិរញ្ញវត្ថុថៃ ។

◆ **ឆ្នាំ១៩៤៧** បួសបានមួយវស្សានៅវត្តសំរោង ខេត្តឆាឆឹងសាវ (ភាគខាងកើតទីក្រុងបាងកក) បន្ទាប់មកត្រឡប់ទៅទីក្រុងបាងកក ក្នុងបំណងធ្វើការនៅក្នុងក្រសួងការបរទេស ប៉ុន្តែត្រូវបានបដិសេធ ហើយទទួលបានតំណែងជាស្មៀនដូចតំណែងដែលទទួលបាននៅក្រសួងហិរញ្ញវត្ថុដែរ ។ បន្ទាប់ពីធ្វើការបានមួយខែ ក៏លាឈប់ពីការងារមកចូលរួមចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យដែលទើបតែលូតលាស់នៅក្នុងប្រទេសថៃ និងបានចូលរួមជាមួយបក្សកុម្មុយនិស្តថៃ ។

◆ **ឆ្នាំ១៩៥០** វិលត្រឡប់មកប្រទេសកម្ពុជាវិញហើយចូលរួមចលនាប្រឆាំងនឹងបារាំង ។ ផ្ទេរពីបក្សកុម្មុយនិស្តថៃមកបក្សកុម្មុយនិស្តឥណ្ឌូចិន មានតួនាទីជាអ្នកអប់រំមនោគមវិជ្ជា ។

◆ **ឆ្នាំ១៩៥១** ជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសេដ្ឋកិច្ចក្នុងរណសិរ្សរួបរួមឥស្សរៈ ។

◆ **ឆ្នាំ១៩៥៤** ចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសវៀតណាម និងត្រូវបានតែងតាំងជាលេខានៃសាខាភ្នំពេញនៃរណសិរ្សរួបរួមឥស្សរៈ ។

◆ **ឆ្នាំ១៩៥៩** ជាអនុលេខាបក្សពលករកម្ពុជា ។

◆ **ឆ្នាំ១៩៦០** បក្សកុម្មុយនិស្តកម្ពុជាត្រូវបានបង្កើតឡើង ។ នួន ជា ត្រូវបានតែងតាំងជាអនុលេខាធិការគណៈកម្មាធិការមជ្ឈិម និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជា ដែលជាអង្គការជាន់ខ្ពស់ទទួលបន្ទុកគោលនយោបាយបក្ស ។

◆ **ឆ្នាំ១៩៦២-១៩៦៣** ចូលរួមអង្គប្រជុំប្រចាំឆ្នាំរបស់សមាជមជ្ឈិមនៅមូលដ្ឋានភូមិភាគបូព៌ា ។ ឆ្នាំ១៩៦៣ ជាលេខានាយកដ្ឋាននៃគណៈកម្មាធិការមជ្ឈិម ។

◆ **ឆ្នាំ១៩៦៥** ភៀសខ្លួនទៅរស់នៅជួរភ្នំក្រវាញក្នុងខេត្តបាត់ដំបង ។

◆ **ឆ្នាំ១៩៦៦-១៩៦៧** ទៅភូមិបុស្សជាមួយ ប៉ុល ពត ។

◆ **ឆ្នាំ១៩៧១** ចូលរួមសមាជបក្សកុម្មុយនិស្តកម្ពុជា ។

◆ **ឆ្នាំ១៩៧២** ជាអនុមេបញ្ជាការយោធាជាន់ខ្ពស់ ។

◆ **ឆ្នាំ១៩៧៥** បក្សកុម្មុយនិស្តកម្ពុជាឈ្នះសង្គ្រាមស៊ីវិលដែលមានរយៈពេល៥ឆ្នាំនិងបានបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ ។

◆ **ថ្ងៃទី២០-២៥ ខែឧសភា ឆ្នាំ១៩៧៥** ដឹកនាំការប្រជុំថ្នាក់ជាតិអំពីផែនការបក្សកសាងសង្គមនិយមនៅកម្ពុជាដោយប្រព័ន្ធកសិកម្មនិងឧស្សាហកម្មនិងបាននិយាយអំពីគោលការណ៍៨យ៉ាងក្នុងការរៀបចំសង្គមឡើងវិញ ។

◆ **ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥** ជាអ្នកទទួលការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ ។

◆ **ខែវិច្ឆិកា-ធ្នូ ឆ្នាំ១៩៧៥** ថ្លែងសុន្ទរកថាក្នុងអង្គប្រជុំនយោបាយមួយនៅក្រុងភ្នំពេញ ។

◆ **ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦** ចូលរួមប្រជុំគណៈអចិន្ត្រៃយ៍ស្តីពីបញ្ហាការពារប្រទេស ជំនួយរបស់ប្រទេសចិនទាក់ទងខាងអាកាសនិងខាងជើងទឹក ។

◆ **ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦** ត្រូវបានជ្រើសតាំងជាប្រធានសភាតំណាងប្រជាជននៃរបបកម្ពុជាប្រជាធិតេយ្យ ។

◆ **ខែកញ្ញា ឆ្នាំ១៩៧៦** ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី

បណ្ដោះអាសន្នជំនួស ប៉ុល ពត ។

◆ **ឆ្នាំ១៩៧៦** ជាប្រធានសភាតំណាងរាស្ត្រកម្ពុជានៃគណៈកម្មាធិការអចិន្ត្រៃយ៍ ។

◆ **ឆ្នាំ១៩៧៧** បង្រៀនអំពីគោលនយោបាយសំខាន់ៗ នៅក្នុងវគ្គអប់រំនយោបាយមួយ នៅទីក្រុងភ្នំពេញ ។

◆ **ឆ្នាំ១៩៧៥-៧៩** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃកងទ័ពបដិវត្តន៍បក្សកុម្មុយនិស្តកម្ពុជា និងលេខាធិការរងបក្សកុម្មុយនិស្តកម្ពុជា ។

◆ **ឆ្នាំ១៩៧៩** កងទ័ពវៀតណាមចូលលុកលុយប្រទេសកម្ពុជានិងផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ហើយបង្កើតរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

◆ **ឆ្នាំ១៩៨០** កម្ពុជាប្រជាធិបតេយ្យបានរស់ឡើងវិញ ដោយទទួលជំនួយពីសមាគមន៍ប្រជាជាតិ អាស៊ី-អាគ្នេយ៍ ប្រទេសចិន អង្គការសហប្រជាជាតិ និងបស្ចិមប្រទេស ។ រដ្ឋាភិបាលត្រីភាគីត្រូវបានបង្កើតឡើងដើម្បីប្រឆាំងនឹងកងកម្លាំងវៀតណាមនិង "រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា" នៅទីក្រុងភ្នំពេញ ។ នួន ជា នៅតែមានសកម្មភាពសកម្មក្នុងរដ្ឋាភិបាលត្រីភាគី ។

◆ **ឆ្នាំ១៩៩១** ក្រុមចលនាតស៊ូដែលមានជម្លោះនៅកម្ពុជាចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពបញ្ចប់សង្គ្រាមស៊ីវិល ។ អង្គការសហប្រជាជាតិបានបញ្ជូនកងកម្លាំងថែរក្សាសន្តិភាពមកប្រទេសកម្ពុជាដើម្បី រៀបចំការបោះឆ្នោត ហើយបេសកកម្មថែរក្សាសន្តិភាពនេះជាបេសកកម្មធំបំផុតរបស់អង្គការសហប្រជាជាតិ ។

◆ **ឆ្នាំ១៩៩៣** ការបោះឆ្នោតនៅកម្ពុជាប្រព្រឹត្តឡើងក្រោមការគាំទ្ររបស់អង្គការសហប្រជាជាតិ ។ ខ្មែរក្រហមបានធ្វើពហិការមិនចូលរួមក្នុងការបោះឆ្នោត ហើយត្រឡប់ទៅតស៊ូទ័ពក្នុងព្រៃវិញ ។

◆ **ឆ្នាំ១៩៩៨** នួន ជា និង ខៀវ សំផន បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាបន្ទាប់ពីការស្លាប់របស់ ប៉ុល ពត នៅថ្ងៃទី ១៥ ខែមេសា ឆ្នាំ១៩៩៨ និងទទួលបានការលើកលែងទោស ។ អ្នកទាំងពីរបានថ្លែងការសុំទោសនៅក្នុងសន្និសីទកាសែតចំពោះរឿងរ៉ាវដែលបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៥-៧៩ ។ នួន ជា បានតាំងទៅទីលំនៅក្នុងទីក្រុងប៉ៃលិនដែលជាអតីតមូលដ្ឋានទ័ពរបស់ខ្មែរក្រហម ។

**ឆ្សាំង ថៃចាវ៉ាត និង ប៉ាន់ចំរើន**

# កាលប្បវត្តិរបស់ ប៉ុល ពត

◆ **ឆ្នាំ១៩២៥** កើតនៅភូមិព្រែកស្បូវ សង្កាត់លេខ៤ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ។

◆ **អាយុ៦ឆ្នាំ** ត្រូវឪពុកម្តាយបញ្ជូលទៅទីក្រុងភ្នំពេញបួសជានេនបានមួយព្រះវស្សានៅវត្តបទុមវតី ។

◆ **ឆ្នាំ១៩៤០** រៀននៅសាលាកាតូលិក ។

◆ **ឆ្នាំ១៩៤៤** បញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ ។

◆ **ឆ្នាំ១៩៤៨** មកទីក្រុងភ្នំពេញដើម្បីសិក្សាមុខជំនាញជាងឈើនៅសាលាបច្ចេកទេសឫស្សីកែវ ។

◆ **ឆ្នាំ១៩៤៩** បានទទួលអាហាររូបករណ៍ទៅសិក្សាបច្ចេកទេសនៅទីក្រុងប៉ារីស ប៉ុន្តែប្រឡងធ្លាក់នៅឆ្នាំទី៣ ហើយត្រូវបញ្ជូនមកប្រទេសកម្ពុជាវិញនៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥៣ ។

◆ **ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៥០** បង្រៀននៅសាលាឯកជន «កម្ពុជបុត្រ» នៅទីក្រុងភ្នំពេញ ។ សាលានេះជាសាខារបស់បក្សកុម្មុយនិស្តកម្ពុជា ។

◆ **ឆ្នាំ១៩៥៣** លេខារបស់ ទូ សាមុត ។

◆ **ឆ្នាំ១៩៥៤** ត្រូវបានចាប់ខ្លួនអស់រយៈពេលបួនខែ ។ ពេលនោះ គាត់គ្រាន់តែជាស្មៀនម្នាក់សម្រាប់គណៈកម្មាធិការខេត្តកំពង់ចាម ។

◆ **ឆ្នាំ១៩៦០** មានឋានៈទី៣នៅក្នុងបក្សពលករកម្ពុជា ក្រោយមកជាលេខាបក្សពលករកម្ពុជា ។

◆ **ឆ្នាំ១៩៦២** បង្រៀននៅសាលាបក្ស (ជិតមន្ទីរពេទ្យព្រះសង្ឃ) ក្រុងភ្នំពេញ ។

◆ **ឆ្នាំ១៩៦៣** ក្លាយជាលេខាបក្សកុម្មុយនិស្តកម្ពុជា និងបានរត់គេចខ្លួនចូលព្រៃនៅភូមិភាគឦសាន ។

◆ **ឆ្នាំ១៩៦៦** កែប្រែថ្ងៃបង្កើតបក្សទៅជាឆ្នាំ១៩៦០ ។

◆ **ឆ្នាំ១៩៦៧** ធ្វើដំណើរទៅដល់មន្ទីរ១០២ ។ ក្នុងរយៈពេលនោះ ប៉ុល ពត មានជំងឺគ្រុនជាញឹកញាប់ ។ គ្រុនម្តងៗមានសភាពធ្ងន់ធ្ងរ ។

◆ **ឆ្នាំ១៩៦៨** លេខាបក្សនៅក្នុងភូមិភាគឦសាន ។

◆ **ឆ្នាំ១៩៧០** ធ្វើដំណើរទៅទីក្រុងប៉េកាំង ហើយបានត្រឡប់មកវិញ រួចបន្តដំណើរទៅភូមិភាគឦសាន ។ (ប៉ុល ពត ត្រូវបានសមាជិកបក្សពលករកម្ពុជាបោះឆ្នោតជ្រើសរើសជាលេខារបស់បក្សពលករកម្ពុជា) ។ មេដឹកនាំចលនាទ័ពព្រៃផ្ទៃក្នុង ។ កាលនោះ ប៉ុល ពត មានឈ្មោះថា សាឡុត ស ។

◆ **ឆ្នាំ១៩៧៣** បដិសេធសំណើរបស់ សោ ភឹម ដែលសុំឲ្យតែងតាំង ម៉ែន ឆាយ ជាបក្សស្តីទីក្នុងភូមិភាគបូព៌ា ។

◆ **ឆ្នាំ១៩៧៤** ប៉ុល ពត ឈឺធ្ងន់ក្រោយពីប្រជុំចប់បាន៣ថ្ងៃ ។ ប៉ុល ពត ឈឺរាល់ឆ្នាំ ។ យប់មួយនោះ ប៉ុល ពត ឈឺស្ពឹកមួយចំហៀងខ្លួននិងមួយចំហៀងក្បាល ហើយខ្លួនរបស់គាត់ត្រជាក់ស្រឹប ។

◆ **ខែកក្កដា ឆ្នាំ១៩៧៥** ចុះទៅចាត់តាំងគណៈភូមិភាគឧត្តរ ដែលមាន កែ ពក ជាលេខា, ស្រេង ជាអនុលេខា, គុល ជាសមាជិកអចិន្ត្រៃយ៍, ហើយ ងិន, ស៊ី, និង ចន ជាសមាជិក ។ ពេលនោះ ប៉ុល ពត ត្រូវបានស្គាល់ថា បងទីមួយ ។

◆ **ពីថ្ងៃទី២០ដល់២១ ខែសីហា ឆ្នាំ១៩៧៥** ធ្វើដំណើរទៅទស្សនកិច្ចភូមិភាគពាយ័ព្យ ។

◆ **ខែកញ្ញា ឆ្នាំ១៩៧៥** ស្ថិតនៅក្នុងគណៈកម្មាធិការមជ្ឈិម ។

◆ **ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥** ត្រូវបានអង្គប្រជុំអចិន្ត្រៃតែងតាំងឲ្យទទួលបន្ទុកខាងយោធានិងសេដ្ឋកិច្ច ។

◆ **ឆ្នាំ១៩៧៦** សមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជា ជាប្រធានគណៈកម្មាធិការយោធារបស់បក្សកុម្មុយនិស្តកម្ពុជា និងជាអគ្គលេខាធិការរបស់បក្សកុម្មុយនិស្តកម្ពុជា ។

◆ **ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦** ត្រូវបានអង្គប្រជុំរបស់មជ្ឈិមបក្សតែងតាំងជានាយករដ្ឋមន្ត្រី (ប៉ុន្តែពេលនោះ ប៉ុល ពត នៅលាក់មុខនៅឡើយ) ។

◆ **ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦** ចេញមុខជាចំហជានាយករដ្ឋមន្ត្រីរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

◆ **ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦** បើកសម័យប្រជុំគណៈរដ្ឋមន្ត្រីជាលើកទីមួយ ដែលប្រកាសធាតុពិតរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

◆ **ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧** ប្រកាសជាផ្លូវការថាខ្លួនជាមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ។

◆ **ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៧** ធ្វើទស្សនកិច្ចនៅប្រទេសចិន និងកូរ៉េខាងជើង ។

◆ **ឆ្នាំ១៩៧៧** បញ្ជូនកងទ័ពទៅវាយប្រយុទ្ធជាមួយវៀតណាម ។

◆ **ថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៨** មន្ទីរ៨៧០ (របស់ ប៉ុល ពត) ចេញសេចក្តីណែនាំអំពីទស្សនៈគោលជំហរនិងមាគ៌ាវាយខ្មាំងឈ្លានពានលេបទឹកដី ។

◆ **ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៨** ថ្លែងសុន្ទរកថាដោយសង្កត់ធ្ងន់ទៅលើតម្រូវការធ្វើឲ្យប្រទេសកម្ពុជាក្លាយទៅជារដ្ឋស្វ័យតមួយ ។

◆ **ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩** ប្រកាសអំពីភាពចាំបាច់និងដាច់ខាតក្នុងការប្រយុទ្ធប្រឆាំងនឹងខ្មាំងយួនឈ្លានពានវាតទីលេបទឹកដី ។

◆ **ខែសីហា ឆ្នាំ១៩៧៩** ត្រូវតុលាការប្រជាជនបដិវត្តកម្ពុជាកាត់ទោសប្រហារជីវិតដោយកំបាំងមុខជាមួយ អៀង សារី និង ខៀវ សំផន ។

◆ **ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧** សុន សេន អតីតរដ្ឋមន្ត្រីក្រសួងសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវបានសម្លាប់ជាមួយក្រុមគ្រួសារ ។ ប៉ុល ពត ត្រូវបានចោទប្រកាន់ថា ទទួលខុសត្រូវបញ្ហានេះ ។

◆ **ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧** ប៉ុល ពត ត្រូវតុលាការប្រជាជន (នៅអន្លង់វែង) កាត់ទោសពីបទសម្លាប់ សុន សេន និង ក្រុមគ្រួសារ ។

◆ **ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨** ប៉ុល ពត ស្លាប់នៅលើភ្នំដងរែក ជាប់ព្រំដែនកម្ពុជា-ថៃ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ខ្មែរក្រហមក្នុងពេលអតីតកាលនិងបច្ចុប្បន្នកាល
# រូបថតប្រវត្តិសាស្ត្រ

### *ការតាំងពិព័រណ៍រូបថតស្តីអំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម នៅសាកលវិទ្យាល័យរ៉ាត់ហ្គើត សហរដ្ឋអាមេរិក*
### *ពីថ្ងៃទី២៨ ខែមីនា ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៦*
### *រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដឹកនាំការងារដោយសាស្ត្រាចារ្យ អាឡិច ហ៊ីនតុន នៅវិទ្យាស្ថានសិក្សាសង្គមនិងនរវិទ្យា*

បក្សកុម្មុយនិស្តកម្ពុជា (ប្រជាជនហៅថាខ្មែរក្រហម) បានកាន់កាប់ប្រទេសកម្ពុជាចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ក្រោយការដឹកនាំរបស់ ប៉ុល ពត គណៈកម្មាធិការមជ្ឈិមបក្ស និងគណៈកម្មាធិការអចិន្ត្រៃយ៍ ។ មិនដល់បួនឆ្នាំផង ប្រជាជនកម្ពុជាប្រមាណពីរលាននាក់ត្រូវបានប៉ាន់ស្មានថាបាត់បង់ជីវិតដោយសារកង្វះអាហារ ធ្វើការហួសកម្លាំង ជំងឺគ្មានថ្នាំសង្កូវព្យាបាល និងការសម្លាប់ ។ មួយភាគបួននៃប្រជាជនសរុបបានបាត់បង់ជីវិតក្នុងរបបនោះ ។ នេះគឺអំពើប្រល័យពូជសាសន៍ដ៏ធំបំផុតនៅក្នុងប្រវត្តិសាស្ត្របើគិតពីអត្រាមនុស្សស្លាប់ធៀបនឹងចំនួនប្រជាជនសរុប ។

រូបថតដែលបន្សល់ទុកពីទសវត្សរ៍ឆ្នាំ១៩៧០ ដែលកំពុងតែដាក់បង្ហាញនៅទីនេះ ត្រូវបានយកចេញពីបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាអង្គការស្រាវជ្រាវឯករាជ្យមិនមែនរដ្ឋាភិបាលដែលរក្សាទុកសំណៅឯកសារដើមពីរបបកម្ពុជាប្រជាធិបតេយ្យច្រើនបំផុតនៅលើពិភពលោក ។ រូបថតទាំងនេះគឺជារូបបុរសនិងស្ត្រីចំនួន១២នាក់អាយុចន្លោះពី១៤ទៅ២៩ឆ្នាំ ដែលសុទ្ធតែធ្លាប់បានចូលរួមបម្រើបដិវត្តន៍ខ្មែរក្រហម ។ អ្នកទាំង១២នាក់ជាអតីតយុទ្ធជន យុទ្ធនារី ឬជាអ្នកបម្រើការនៅក្នុងមន្ទីរសន្តិសុខមជ្ឈិម ស-២១ ។ តាមការប៉ាន់ស្មាន ក្នុងចំណោមអ្នកទោសជាងមួយម៉ឺនបួនពាន់នាក់ដែលជាប់នៅក្នុងមន្ទីរសន្តិសុខនោះ មានតែ១២នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត ។

រូបថតកម្មាភិបាលខ្មែរក្រហមថតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភាគច្រើនមានភ្ជាប់មកជាមួយនូវ“ប្រវត្តិរូប”ដែលកម្មាភិបាលម្នាក់ៗបានធ្វើយ៉ាងតិចក៏ម្តងដែរ ។ នៅក្នុងប្រវត្តិរូបមានកត់ត្រាព័ត៌មានអំពីអាយុ ភូមិកំណើត សមាជិកគ្រួសារ វណ្ណៈសង្គម និងមូលហេតុដែលកម្មាភិបាលរូបនេះចូលបម្រើបដិវត្តន៍ ។ ដោយប្រើប្រាស់ព័ត៌មាននៅក្នុងប្រវត្តិរូប បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្រាវជ្រាវរកឃើញអតីតកម្មាភិបាលខ្មែរក្រហមទាំង១២រូប និងបានថតរូបនិងធ្វើសម្ភាសន៍អំពីបទពិសោធន៍និងទស្សនៈរបស់គាត់ជុំវិញការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ពិព័រណ៍នេះត្រូវបានរៀបចំឡើងដោយសមាជិកនៃសិក្ខាសាលាជាន់ខ្ពស់ស្តីអំពីយុត្តិធម៌អន្តរកាលរបស់មហាវិទ្យាល័យអនទើ ក្រោមការដឹកនាំរបស់លោកសាស្ត្រាចារ្យ អាឡិច ហ៊ីនតុន ។ សាកលវិទ្យាល័យរ៉ាត់ហ្គើត-ញូវវឺក បានរក្សាទុកឯកសារនិងសម្ភារផ្សេងៗទៀតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឯកសារទាំងនោះរួមមានឯកសារខ្មែរក្រហម ម៉ៃក្រូហ្វីល ខ្សែភាពយន្ត ផែនទីប៉ាណូ រូបថត និងឯកសារដែលបោះពុម្ពផ្សាយដោយរបបខ្មែរក្រហម ឬនៅក្នុងអំឡុងពេលខ្មែរក្រហមកាន់អំណាច ។

យើងសង្ឃឹមថា ចំណេះដឹងអំពីបទពិសោធន៍របស់ប្រជាជនកម្ពុជាអាចយកទៅអនុវត្តជាមួយអំពើប្រល័យពូជសាសន៍ដែលកើតមាននៅទីកន្លែងផ្សេងទៀតជុំវិញពិភពលោក ។ សាស្ត្រាចារ្យ អាឡិច ហ៊ីនតុន មានប្រសាសន៍ថា “ជនដែលមិនមែនជាប្រជាជនកម្ពុជាមិនអាចយល់ច្បាស់ថាតើការឆ្លងកាត់អំពើប្រល័យពូជសាសន៍មានន័យដូចម្តេចទេ ក៏ប៉ុន្តែនេះមិនមែនមានន័យថាអ្នកទាំងនោះនឹងមិនយល់អំពីមូលហេតុដែលនាំឲ្យមានអំពើប្រល័យពូជសាសន៍ឡើយ ។ យើងរៀបចំការតាំងពិព័រណ៍រូបថតនេះពីព្រោះកិច្ចការនេះមានសារសំខាន់ចំពោះយើង ។ ការសិក្សាពីអំពើប្រល័យពូជសាសន៍ក៏បានផ្តល់ជាមេរៀនដល់យើងអំពីជីវិតរបស់យើង និងអំពីពិភពលោកដែលនៅជុំវិញយើង” ។

ការតាំងពិព័រណ៍នេះប្រព្រឹត្តទៅក្រោមក្រោមការគាំទ្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បណ្ណាល័យ ចន កូថិន ខែនណា និងសមាគមអតីតនិស្សិតនៃសាកលវិទ្យាល័យរ៉ាត់ហ្គើត-ញូវវឺក និង មូនិធិរ៉ាត់ហ្គើត ។

**ប្រែសម្រួលដោយ ប៉ាន់ ស៊ីម៉ាឡា**

# រកឃើញរូបថតបងស្រីនៅលើទំព័រទស្សនាវដ្ដីស្វែងរកការពិត

“រូបថតនេះគឺជាបងស្រីខ្ញុំយ៉ាងពិតប្រាកដ” ។ រស់ ស៊ុយ និយាយយ៉ាងមានជំនឿចិត្ត ដោយចង្អុលរូបថតអ្នកទោសស្ត្រីម្នាក់នៅលើទំព័រទស្សនាវដ្ដីស្វែងរកការពិតលេខ៣១ ខែកក្កដា ឆ្នាំ២០០២ ។

រស់ ស៊ុយ គឺជាសិក្ខាកាមម្នាក់នៅក្នុងវគ្គហ្វឹកហ្វឺនច្បាប់ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ជារៀងរាល់ថ្ងៃ ស៊ុយ មកដល់មជ្ឈមណ្ឌលឯកសារកម្ពុជាមុនម៉ោងរៀន ហើយអង្គុយនៅក្នុងបន្ទប់ព័ត៌សាធារណៈអានទស្សនាវដ្ដីស្វែងរកការពិតយ៉ាងស្ងៀមស្ងាត់ ។ បន្ទាប់ពីអានអស់រយៈពេលជាច្រើនថ្ងៃ ស៊ុយ កាន់ទស្សនាវដ្ដីមួយច្បាប់មកបង្ហាញបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បង្ហាញរូបអ្នកទោសស្ត្រីម្នាក់ ហើយនិយាយថា “នេះគឺជាបងស្រីរបស់ខ្ញុំ ។ ពិតណាស់ ពិតជាបងស្រីរបស់ខ្ញុំ” ។



ព្រាហ្ម នួន



ដាន់ សាយ

បងស្រីរបស់ ស៊ុយ ឈ្មោះ ព្រាហ្ម នួន ត្រូវខ្មែរក្រហមចាប់ដាក់មន្ទីរ ស-២១ និងសម្លាប់ចោល ។ តាមរយៈឯកសារអំពី ព្រាហ្ម នួន យើងបានស្រាវជ្រាវរកឃើញឯកសារប្ដីរបស់គាត់ឈ្មោះ ដាន់ សាយ ដែលត្រូវចាប់ខ្លួននិងសម្លាប់ជានៅមន្ទីរ ស-២១ជាមួយគ្នា ។

ស៊ុយ បានរំឭកឡើងវិញអំពីបងស្រីដែលគាត់ចងចាំជានិច្ច ។ ព្រាហ្ម នួន ជាបងស្រីច្បងដែលមានចរិតស្លូតបូត និងមិនសូវបានរៀនហារ ។ នួន បានរៀបការជាមួយ ដាន់ សាយ ហៅ អ៊ុត សាយ នៅឆ្នាំ១៩៧៣ នៅក្នុងពេលដែល សាយ ជាកងទ័ពខ្មែរក្រហមនិងកំពុងតែនៅសមរភូមិ ។ សាយ បានចូលបម្រើបដិវត្តន៍ដែរ ហើយបានទៅរស់នៅជាមួយប្ដី ។ ស៊ុយ ក៏លែងបានជួបអ្នកទាំងពីរតាំងពីពេលនោះមក ។

ស៊ុយ បានចូលបម្រើបដិវត្តន៍តាំងពីឆ្នាំ១៩៧១ ។ បន្ទាប់ពីថ្ងៃជ័យជម្នះរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ អង្គភាពរបស់ ស៊ុយ ត្រូវអង្គការបញ្ជូនមកធ្វើជាកម្មករឃ្លាំងរដ្ឋកំពង់ទឹកកក (ខាងកើតផ្សារថ្មី) ហើយ ស៊ុយ មានតួនាទីដឹកទំនិញពីរោងចក្រទាំងអស់មកដាក់នៅឃ្លាំង ។

នៅឆ្នាំ១៩៧៦ ស៊ុយ ទៅដឹកទំនិញនៅរោងចក្រតម្បាញ គ្រឿងបរិក្ខារពេទ្យ ក-៥ ហើយបានជួបបងស្រីដែលគាត់កំពុងធ្វើការនៅទីនោះ ។ ក្នុងពេលដែលកម្មករកំពុងបញ្ជូនទំនិញទៅដាក់នៅឃ្លាំង ស៊ុយ មានឱកាសបានជជែកជាមួយបងស្រីប្រហែលជាកន្លះម៉ោង ។ បន្ទាប់ពីនោះ គាត់បានស្នើសុំប្រធានរោងចក្រដើម្បីជួបកូនពីរនាក់របស់ នួន ដោយយកស្ករក្រាមនិងអាហារកំប៉ុងទៅឲ្យក្មួយ ។

នួន ត្រូវអង្គការបញ្ជូនឲ្យមកធ្វើការនៅរោងតម្បាញ ចំណែក សាយ ត្រូវអង្គការចាត់តាំងឲ្យធ្វើជាប្រធានក្រុមចាំចម្ការនៅមន្ទីរ ក-២១ ជិតបឹងជើងឯក ។

ថ្ងៃក្រោយមកទៀត ពេលដែល ស៊ុយ កំពុងជិះម៉ូតូទៅដឹកសម្ភារនៅរោងចក្រកង់ឡានតាខ្មៅ គាត់ក៏បានជួបបងថ្លៃនៅក្បាលថ្នល់កំពុងជិះកង់ដើរលេងជាមួយមិត្តភក្តិ ។ ស៊ុយ បានណែនាំបងថ្លៃឲ្យបញ្ឈប់ការដើរលេងរហេតរហូតនិងសេរីទៀត ។ បន្ទាប់ពី

និយាយជាមួយបងថ្លៃហើយ ស៊ុយ បានជួបបងស្រី ក៏បានប្រាប់បងស្រីឲ្យណែនាំប្តីកុំឲ្យដើរលេងច្រើនពេក ។ ដើម្បីរក្សាជីវិតឲ្យ រស់ ស៊ុយ បានណែនាំបងស្រីឲ្យប្តូរនាមត្រកូល ពោលគឺបងស្រីដាក់ឈ្មោះ ព្រាហ្ម នួន រីឯ ស៊ុយ ខ្លួនឯងដាក់ឈ្មោះ រស់ ស៊ុយ ។ ស៊ុយ និយាយថា ធ្វើបែបនេះគឺដើម្បីកុំឲ្យមានការពាក់ព័ន្ធគ្នានៅពេលដែលអង្គការចាប់នរណាម្នាក់ ។ ស៊ុយ បន្ថែមថា "បើអង្គការចាប់គាត់នៅសល់ខ្ញុំ បើអង្គការចាប់ខ្ញុំនៅសល់គាត់" ។

ដោយជាប់រវល់ទៅដឹកទំនិញនៅខាងពោធិចិនតុង ស៊ុយ មិនបានទាក់ទងជាមួយបងស្រីអស់មួយរយៈ ។ ចុងឆ្នាំ១៩៧៦ ស៊ុយ ឮដំណឹងថាក្មួយម្នាក់បានស្លាប់ ។ ស៊ុយ យកលេសទៅដឹកទំនិញនៅរោងចក្រតម្បាញដើម្បីបានជួបបងស្រី ។ គ្រាន់តែឃើញមុខប្អូនភ្លាម នួន យំហើយនិយាយប្រាប់ថា កូនរបស់គាត់ម្នាក់ទៀតក៏ស្លាប់ហើយដែរ ។ ស៊ុយ នៅចាំពាក្យសម្តីរបស់បងស្រីដែលថា "កូនក៏ស្លាប់ ចំណែកប្តីនិយាយមិនស្តាប់ទៀត" ។ ស៊ុយ សម្គាល់ឃើញថា សភាពរបស់ នួន នៅពេលនោះខុសពីមុន ។ នួន មានទឹកមុខស្រងូតស្រងាត់ រូបរាងស្គមស្គាំងជាងមុន ។ មុនពេលលាគ្នា ស៊ុយ បាននិយាយប្រាប់បងស្រីថា បើមិនឃើញប្តីមកលេងក្នុងរវាង១០ថ្ងៃឬមួយខែម្តងទេ នោះបានន័យថា ប្តីរបស់គាត់ត្រូវអង្គការចាប់ខ្លួនហើយ ។ នួន បានឮដូច្នោះគ្មានពាក្យអ្វីក្រៅពីសម្រក់ទឹកភ្នែកតែប៉ុណ្ណោះ ។

ស៊ុយ ត្រឡប់មកអង្គភាពវិញ ព្យាយាមរកមធ្យោបាយជួយបងស្រី ។ នៅដើមឆ្នាំ១៩៧៧ ស៊ុយ ទៅរកបងស្រីម្តងទៀត ប៉ុន្តែ នួន បានបាត់ខ្លួនទៅហើយ ។ អ្នកគ្រប់គ្រងនៅរោងចក្របានប្រាប់ ស៊ុយ ថា នួន ផ្លាស់ទៅធ្វើការនៅកន្លែងផ្សេង ។ ស៊ុយ ដឹងច្បាស់ថា នួន និងប្តី ពិតជាត្រូវអង្គការសម្លាប់ចោល ។

ចាប់តាំងពីនោះមក ស៊ុយ មានអារម្មណ៍មិននឹងនរ ចេះតែបារម្ភខ្លាចក្រែងអង្គការចាប់ខ្លួន ។ ស៊ុយ ប្រុងប្រយ័ត្នគ្រប់ពេលវេលានិងខំធ្វើការងារមិនឲ្យឃើញមួយជំហាន ។

ស៊ុយ សម្តែងក្តីរីករាយដោយបានរកឃើញដំណឹងអំពីបងស្រីរបស់គាត់ ។ រូបថតបងស្រីរបស់គាត់អាចឲ្យគាត់រំឭកការចងចាំអំពីមនុស្សជាទីស្រលាញ់ដែលគាត់ខំស្វែងរកអស់រយៈជិត៣០ឆ្នាំមកហើយ ។ ជាពិសេសគាត់បានរូបថតរបស់បងទាំងពីរផ្ញើទៅឲ្យឪពុកម្តាយនិងបងប្អូនកូនក្មួយរបស់គាត់បានស្គាល់និងមើលមុខម្តងទៀត ។

តាមឯកសារប្រវត្តិរូបអ្នកទោសនៅមន្ទីរ ស-២១ ព្រាហ្ម នួន និង ដាន់ សាយ ត្រូវចាប់ខ្លួនជាមួយគ្នានៅរោងចក្រតម្បាញ ក-៥ នៅថ្ងៃទី១៩ ខែ២ ឆ្នាំ១៩៧៧ ។ សាយ ត្រូវអង្គការកម្ទេចនៅថ្ងៃទី៣ ខែ៧ ឆ្នាំ១៩៧៧ ។

**លី សុផល**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុ FM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង ៧ៈ៣០-៧ៈ៤៥ល្ងាច ។
- វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង ៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង ៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០ រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ឡាត់ សោភ័ណ និង ឡេង រតនៈ**

# រកឃើញរូបថតប្អូនប្រុសនៅក្នុងដំណើរទស្សនកិច្ច អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

ហង់ យឹម រស់នៅស្រុកបារាយណ៍ ខេត្តកំពង់ធំ បានរកឃើញរូបថតប្អូនប្រុសរបស់គាត់ ឈ្មោះ ហង់ ហាក់ នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ខណៈពេលដែលគាត់ចូលរួមដំណើរទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ហង់ យឹម មានបងប្អូនបីនាក់ ហើយ ហង់ ហាក់ គឺជាប្អូនបន្ទាប់ ។ ហាក់ បួសរៀននៅវត្តនៅស្រុកកំណើត ហើយនៅអាយុ ២៣ឆ្នាំ ហាក់ បានសុំម្តាយស្ម័គ្រចិត្តចូលធ្វើកងទ័ពខ្មែរក្រហម និងបានចាកចេញទៅសមរភូមិមុខនៅឆ្នាំ១៩៧៥ ។ មួយឆ្នាំក្រោយមក ហាក់ មកលេងផ្ទះបានមួយភ្លែតក៏ប្រញាប់ប្រញាល់ត្រឡប់ទៅវិញ ។ តាំងពីពេលនោះមក ក្រុមគ្រួសាររបស់ យឹម បាត់ដំណឹង ហាក់ រហូត ។




នៅឆ្នាំ១៩៧៩ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរំលំមិត្តរបស់ ហាក់ បានមករកសាច់ញាតិរបស់ ហាក់ នៅភូមិកំណើតដើម្បីប្រាប់ថា ហាក់ ត្រូវអង្គការអារ-កសម្លាប់នៅ ក្នុងគុកហើយ ។

ក្រុមគ្រួសាររបស់ យឹម តក់ស្លុតជាខ្លាំងចំពោះដំណឹងនេះ ។ ម្តាយរបស់ យឹម សម្រាន្តមិនលក់ហើយកើតទុក្ខរីងរៃធ្លាក់ខ្លួនឈឺជាទម្ងន់រហូតដល់ស្លាប់ ។

យឹម មិនដែលមកមើលសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងទេ ។ នេះជាលើកទីមួយដែល យឹម បានមកឃើញនិងស្វែងយល់អំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ យឹម ក៏មិនដឹងថាមានរូបថតប្អូនរបស់គាត់នៅគុកទួលស្លែងនេះដែរ ។ នៅពេលឃើញរូបថតប្អូនរបស់គាត់ យឹម តក់ស្លុត ឈឺចាប់ និងអាណិតប្អូនជាខ្លាំង ។ យឹម និយាយថា "ខ្ញុំអាណិតប្អូនខ្ញុំណាស់ ។ មិនដឹងជាប្អូនខ្ញុំវេទនាយ៉ាងណាទេមុននឹងស្លាប់" ។

នេះគឺជាលើកទី៣ហើយ តាំងពីដើមឆ្នាំ២០០៦ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំដំណើរទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាតជើងឯក ។

ដំណើរទស្សនកិច្ចនេះមានគោលបំណងផ្តល់ឱកាសជូនប្រជាជនកម្ពុជាឲ្យទទួលបានព័ត៌មានអំពីដំណើរការស្វែងរកយុត្តិធម៌របស់អង្គជំនុំជម្រះវិសាមញ្ញ និងបានបានចូលរួមក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ ។ នៅក្នុងដំណើរទស្សនកិច្ចមួយលើកៗ មានការចូលរួមពីដូនជី ហាគីម គួន និងប្រជាជនអ៊ីស្លាម អតីតកម្មាភិបាលយុទ្ធជនខ្មែរក្រហម ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ និងនិស្សិត ជាមធ្យមប្រាំរយនាក់មកពីគ្រប់ខេត្តក្រុងទូទាំងប្រទេស ។

**ឈាយ សុផារី**

# រូបថតរំឭកអតីតកាល

*ជារៀងរាល់ខែ មានដូនជីចំនួន៩០នាក់មកចូលរួមក្នុងទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាជាមួយនឹងជនជាតិឥស្លាមនិងប្រជាជនកម្ពុជាដទៃទៀតប្រមាណជាង៤០០នាក់។ នៅក្នុងដំណើរទស្សនកិច្ចក្នុងខែមេសានេះ ដូនជីម្នាក់ឈ្មោះ អៀវ ម៉ៅ អាយុ៧៩ឆ្នាំ បានបង្ហាញរូបថតប្តីរបស់គាត់ដែលតាំងនៅក្នុងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។ ប្តីរបស់គាត់ជាអ្នកទោសនៅគុកទួលស្លែង និងស្លាប់ដោយការធ្វើទារុណកម្ម។*



**អៀវ ម៉ៅ និងរូបថតប្តីរបស់គាត់នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង**

*នេះគឺជាលើកទី២ដែល អៀវ ម៉ៅ មកទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។ គាត់បានមកលើកទីមួយនៅឆ្នាំ១៩៧៩ ក្រោយពេលគាត់បានទទួលដំណឹងពីបុរសម្នាក់ដែលបានធ្វើការនៅភ្នំពេញជាមួយប្តីរបស់គាត់នៅក្នុងរបបខ្មែរក្រហមថាប្តីរបស់គាត់ត្រូវខ្មែរក្រហមព្យួរនៅគុកទួលស្លែង។ កាលណោះ អៀវ ម៉ៅ រន្ធត់ចិត្តរហូតដល់សន្លប់បាត់ស្មារតី ហើយត្រូវកងទ័ពវៀតណាមដឹកទៅមន្ទីរពេទ្យ។ តាំងពីពេលនោះមកគាត់មិនដែលមកមើលទៀតទេ។ ការមកឃើញរូបថតម្តងនេះ អៀវ ម៉ៅ អាចទប់ចិត្តបាន ក៏ប៉ុន្តែអារម្មណ៍ឈឺចាប់របស់គាត់ចំពោះខ្មែរក្រហមនៅតែមាន។ យាយមានប្រសាសន៍ថា "ពេលឃើញរូបថតនេះ យាយនៅតែឈឺចាប់ណាស់ការឈឺចាប់នោះរកកន្លែងនិយាយមិនបានទេ"។*

*ប្តីរបស់ អៀវ ម៉ៅ ជាអតីតទាហានហ្លួងពាក់ស័ក្តិបី ចំណែកគាត់គឺជាអតីតអ្នករាំល្ខោនហ្លួង។ នៅឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់គាត់ត្រូវជម្លៀសទៅខេត្តកំពង់ធំ។ ទៅដល់ទីនោះបានពីរខែ ខ្មែរក្រហមបានយកប្តីរបស់គាត់មកធ្វើការនៅភ្នំពេញ។ គាត់ដឹងថាខ្មែរក្រហមបោកប្រាស់។ អៀវ ម៉ៅ រំឭកថា "គេ (ខ្មែរក្រហម) សួរថាបើនរណាធ្លាប់ធ្វើបុណ្យស័ក្តិណាប្រាប់ឲ្យត្រង់ៗ គេឲ្យទៅធ្វើការវិញ។ ស្រាប់តែគាត់ប្រាប់ថា គាត់ស័ក្តិបីទាហានហ្លួងក្នុងវាំង។ ខ្ញុំឃាត់គាត់កុំឲ្យឆ្លើយ តែគាត់នៅតែឆ្លើយអីចឹង"។*

*ក្រោយពេលយកប្តីរបស់ អៀវ ម៉ៅ ទៅបាត់ ខ្មែរក្រហមបានមកចាប់គាត់ដាក់ច្រវាក់ជើង ហើយបញ្ជូនឲ្យទៅរស់នៅកណ្តាលព្រៃជ្រៅអស់រយៈពេលពីរឆ្នាំ។ អៀវ ម៉ៅ រស់នៅយ៉ាងវេទនាតែម្នាក់ឯងរហូតដល់ឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមរំដោះប្រទេស ទើបគាត់បានវិលត្រឡប់ទៅស្រុកកំណើតវិញ។ កូនចៅនិងបងប្អូនសាច់ញាតិទាំងប៉ុន្មានរបស់ អៀវ ម៉ៅ បានស្លាប់អស់នៅក្នុងរបបខ្មែរក្រហម សព្វថ្ងៃគាត់រស់នៅតែម្នាក់ឯងប៉ុណ្ណោះ។*

*នៅគ្រប់ដំណើរទស្សនកិច្ចទៅកាន់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងនិងវាលពិឃាតជើងឯក ដូនជីសូត្រធម៌បង្សុកូលឧទ្ទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានស្លាប់នៅទីនោះ។ អៀវ ម៉ៅ ក៏បានសូត្រធម៌ជូនដល់វិញ្ញាណក្ខន្ធជនរងគ្រោះដទៃទៀតក៏ដូចជាវិញ្ញាណក្ខន្ធប្តីរបស់គាត់ដែរ។*

**លី សុផល**

# សេចក្តីប្រកាសរកប្រពន្ធនិងកូន

ខ្ញុំបាទឈ្មោះ លឹម ឈីសុង ស្រុកកំណើតនៅទីក្រុងភ្នំពេញ សូមប្រកាសសួររកប្រពន្ធនិងកូនបួននាក់ ដែលមានឈ្មោះដូចខាងក្រោម ÷



◆ប្រពន្ធឈ្មោះ លឹម លីដួ សព្វថ្ងៃអាយុប្រហែល៦២ឆ្នាំ ស្រុកកំណើតនៅខេត្តក្រចេះ

◆កូនស្រីទី១ឈ្មោះ លឹម ភិចសួង សព្វថ្ងៃអាយុប្រហែល៤២ឆ្នាំ (មានប្រជ្រុយក្រហមលើថ្ពាល់ខាងឆ្វេង)

◆កូនស្រីទី២ឈ្មោះ លឹម ភិចអេង សព្វថ្ងៃអាយុប្រហែល៤០ឆ្នាំ

◆កូនស្រីទី៣ឈ្មោះ លឹម ភិចហុង សព្វថ្ងៃអាយុប្រហែល៣៨ឆ្នាំ

◆កូនស្រីទី៤ឈ្មោះ លឹម ភិចស្រួយ សព្វថ្ងៃអាយុប្រហែល៣៦ឆ្នាំ

កាលពីមុនឆ្នាំ១៩៧៥ អ្នកទាំងអស់គ្នារស់នៅទីក្រុងភ្នំពេញ ។ បន្ទាប់ពីត្រូវខ្មែរក្រហមជម្លៀសចេញពីក្រុងភ្នំពេញ ក្នុងអំឡុងខែ៨ ឬខែ៩ ឆ្នាំ១៩៧៥ បានទទួលដំណឹងថា ម្តាយនិងកូនស្រីទាំងបួននាក់ត្រូវជម្លៀសទៅខេត្តកំពង់ឆ្នាំងនិងជិះរថភ្លើងបន្តទៅកាន់ខេត្តពោធិសាត់ ហើយក៏បានបាត់ដំណឹងតាំងពីពេលនោះមក ។

ដូចនេះបើមានបងប្អូនណាបានស្គាល់ ឬបានជួប ឬមានដំណឹង ឬបានជួយយកទៅចិញ្ចឹម សូមមេត្តាអាណិតជួយផ្តល់ដំណឹងដល់ខ្ញុំបាទផង ខ្ញុំបាទនឹងជូនសគុណជាទីគាប់ចិត្ត ។ សូមមេត្តាទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៤១ ៨០៣ (នៅភ្នំពេញ), ០១១ ៩៣៨ ៣២២ (សមាគមខ្មែរ-ចិននៅខេត្ត ពោធិសាត់), ០១១ ៨៣៨ ៤១២ (សមាគមខ្មែរ-ចិននៅខេត្តប៉ោយប៉ែត), ០១២ ៨៤៨ ៦៥៦ (សមាគមខ្មែរ-ចិននៅស្រុកសិរីសោភ័ណ) ។ បើមានបងប្អូនណាបានជួយយកទៅចិញ្ចឹម ខ្ញុំបាទនឹងចាត់ទុកគ្រួសារនោះជាគ្រួសារតែមួយ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកក្មួយឈ្មោះ សេង វុទ្ធី

ខ្ញុំបាទឈ្មោះ ស៊ូ កាន់យ៉ា អាយុ៥៧ឆ្នាំ បច្ចុប្បន្នរស់នៅ ភូមិថ្ពងក្រៅ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ សូមប្រកាសរកក្មួយឈ្មោះ សេង វុទ្ធី (ម្តាយឈ្មោះ សេង វ៉ាន់ដន) យុទ្ធជននៅមន្ទីរកាណូតយន្តនៅក្នុងរបបខ្មែរក្រហម ។ វុទ្ធី បានបាត់ខ្លួនតាំងពីពេលរត់ទៅជាមួយឈ្មោះ ភាព គណៈតំបន់៥០៥ ក្នុងពេលផ្ទុះឃ្លាំងគ្រាប់ ។ ប្រសិនបើក្មួយ សេង វុទ្ធី បានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តបានស្គាល់ឈ្មោះខាងលើនេះ សូមទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានផ្ទះលេខ ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកកូនប្រុសឈ្មោះ ម៉ាន ម៉ុន

យស ផេង អាយុ៧២ឆ្នាំ ត្រូវជាម្តាយ ព្រមទាំងកូនស្រី ម៉ាន ម៉ន អាយុ៤៥ឆ្នាំ សូមប្រកាសសួររកកូនប្រុសឈ្មោះ ម៉ាន ម៉ុន ដែលបានចេញពីផ្ទះតាំងពីឆ្នាំ១៩៧៦ បាត់ដំណឹងរហូតដល់សព្វថ្ងៃ ។ ដើមឆ្នាំ១៩៧៦ ម៉ាន ម៉ុន ត្រូវខ្មែរក្រហមបង្ខំឲ្យសឹក បន្ទាប់មកត្រូវបានបញ្ជូនទៅធ្វើការក្នុងកងជំឡូងនៅម្តុំភ្នំពាមជាំង ស្រុកព្រះស្តេច ។ តាំងពីពេលនោះមក ម៉ាន់ ម៉ុន មិនបានត្រឡប់មកផ្ទះវិញទេ ។

ប្រសិនបើកូនបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានស្គាល់ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ព័ត៌មានមកនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬទូរស័ព្ទលេខ ៨៥៥ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 76, April 2006 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.